ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការគាបសង្កត់បង្កើតឲ្យមានការរើបម្រះ
- កំណត់ត្រាប្រវត្តិសាស្ត្រ៖ ទំនាក់ទំនងរវាងប្រទេសសិង្ហបុរី និងកម្ពុជាប្រជាធិបតេយ្យ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣៥ ខែកក្កដា ឆ្នាំ២០១៩

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២៣៥ ខែកក្កដា ឆ្នាំ២០១៩

## មាតិកា

**សំបុត្រ**
- ការគាបសង្កត់បង្កើតឲ្យមានការរើបម្រះ ....................................១

**ផ្នែកឯកសារ**
- អ៊ុម ឆន ត្រូវបានចាប់ខ្លួនពីបទប្រឆាំងនឹងបដិវត្តន៍....................... ៥

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**
- ដើមស្រឡៅ.......................................................................... ៧
- ព្រៃឈើ និងយោធាខ្មែរក្រហម........................................... ១១
- ព្រះសង្ឃជួយជីវិតមនុស្ស សត្វ និងព្រៃឈើ......................... ១៤
- ចំណាប់អារម្មណ៍អ្នកទស្សនាចំពោះខ្សែភាពយន្តរឿង«ឆ្នាំព្រៃ»... ១៧
- សិស្សានុសិស្សវិទ្យាល័យប្រម៉ោយសិក្សាអំពី ......................... ២០
- កងរកខ្លឹមចន្ទន៍ក្រឹស្នា ជ័រវ៉ុង និង បេះផ្លែក្រវាញ .................២៣
- រឿងរ៉ាវរំលោភស្ត្រី នៅក្នុងល្ខោននិយាយ ............................ ២៥
- ភូមិក្រពើពីរ.......................................................................... ២៨
- មនោគមន៍វិជ្ជាខ្មែរក្រហមបានធ្វើឲ្យខ្ញុំលែងគិតពីជីវិតផ្ទាល់ខ្លួន.....៣១
- ទីតាំងប្រវត្តិសាស្ត្រ និងហេតុការណ៍រន្ធត់ ...............................៣៣
- ខ្ញុំហៀបនឹងជាប់ទោសដោយសារក្រមា.................................. ៣៦
- សិក្ខាសាលាស្តីអំពីៈ ប្រវត្តិសាស្ត្រខ្មែរក្រហម និង ................ ២៩

**ផ្នែកច្បាប់**
- អង្គជំនុំជម្រះសាលាដំបូង ................................................. ៤២

**វេទិកាពិភាក្សាសាធារណៈ**
- ការអន្តរាគមន៍របស់កងទ័ពវៀតណាមដើម្បីផ្តួលរំលំ................៤៥
- កេរដំណែលរបស់ជនភៀសខ្លួនឥណ្ឌូចិននៅប្រទេសហ្វីលីពីន ......៤៧
- ការចងចាំនៅតែមាន តម្រូវការនៃយុត្តិធម៌នៅតែបន្ត ...............៤៩
- កំណត់ត្រាប្រវត្តិសាស្ត្រៈ ទំនាក់ទំនងរវាងប្រទេសសិង្ហបុរី ........៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**
- បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម .............៥៧



បណ្ឌិត ហ័ង ធីហ៊ុងធ៉ា គឺជាសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ ដែលជាសាកលវិទ្យាល័យជាតិនៃប្រទេសវៀតណាមស្ថិតនៅក្នុងទីក្រុងហាណូយ ធ្វើបទបង្ហាញលើប្រធានបទ «អន្តរាគមន៍របស់វៀតណាមចូលមកប្រទេសកម្ពុជា»

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ៣៧៥ ព.មប្រក
ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះៈ** លី សុខឃាង, ដាត ចាន់សុនិតា, សុខ វណ្ណៈ, សួត វិចិត្រ, ឡុង ដានី, វ៉ាន់ថាន់ ពៅដារ៉ា **អ្នកនិពន្ធ និងស្រាវជ្រាវៈ** ហូ ថុនា, អ៊ុន សុដារី និង ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែៈ** អ៊ុន សុដារី **និពន្ធនាយកទូទៅៈ** សោម ប៊ុនថន **ជំនួយការនិពន្ធនាយកៈ** ហូ ថុនា **ក្រាហ្វិកកុំព្យូទ័រៈ** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយៈ** ផេង ពង្ស

**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ការគាបសង្កត់បង្កើតឲ្យមានការរើបម្រះ

ខាវ ចន្ទឡា មានអាយុ១៨ឆ្នាំ បានជំធាត់និងសិក្សារៀនសូត្រនៅវិទ្យាល័យអន្លង់វែង ដែលជាវិទ្យាល័យដំបូងបង្អស់នៅក្នុងតំបន់កាន់កាប់ចុងក្រោយនៃចលនាខ្មែរក្រហម នៅក្នុងស្រុកអន្លង់វែង។ ចន្ទឡា កើតនៅក្នុងគ្រួសារមួយដែលមានឪពុកជាជនជាតិភាគតិចទំពួន និងម្តាយជាជនជាតិឡាវ។ ចន្ទឡា បាននិយាយដោយមិនស្ទាក់ស្ទើរថា ខ្លួនមិនមានទទួលរងស្លាកស្នាមអសោច ឬមានភាពខ្មាស់អៀន ដោយសារតែឪពុកម្តាយរបស់ខ្លួនធ្លាប់បម្រើឲ្យរបបខ្មែរក្រហមឡើយដែលរបបនេះមានឈ្មោះផ្លូវការថា «របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។

បច្ចុប្បន្ន ចន្ទឡា ជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យអន្លង់វែង ដែលជាអតីតសាលាបឋមសិក្សារបស់ តាម៉ុក កាលពីឆ្នាំ១៩៩៣ ហើយបានប្រែក្លាយជាវិទ្យាល័យនៅដើមទសវត្សរ៍ឆ្នាំ២០០០។ ចន្ទឡា គឺជាសិស្សម្នាក់ក្នុងចំណោមសិស្សចំនួន១០៣នាក់ ដែលបានចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពីអំពើប្រល័យពូជសាសន៍ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩។ សិស្សានុសិស្សមកពីវិទ្យាល័យអន្លង់វែង និងវិទ្យាល័យត្រពាំងតាវ បានចូលរួមនៅក្នុងវេទិកាថ្នាក់រៀននេះ។ គម្រោងនេះជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការរៀបចំវេទិកាប្រភេទនេះ នៅតាមបណ្តាវិទ្យាល័យ ដើម្បីបង្រៀនអំពីប្រវត្តិសាស្ត្ររបបកម្ពុជាធិបតេយ្យ។ ជារៀងរាល់ខែ សិស្សានុ



សិស្សានុសិស្សវិទ្យាល័យត្រពាំងតាវកំពុងធ្វើការងារជាក្រុម

សិស្សរាប់រយនាក់បានចូលរួមនៅក្នុងវេទិកាបែបនេះ។ ទោះបីជាយ៉ាងណាក្តី មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលជាគម្រោងមួយផ្តួចផ្តើមដោយមជ្ឈមណ្ឌលឯកសារកម្ពុជា មានមោទកភាពក្នុងការផ្តោតជាពិសេសលើវិទ្យាល័យ និងអនុវិទ្យាល័យក្នុងស្រុកអន្លង់វែង។

ចន្ទឡា គឺជាសិស្សម្នាក់ក្នុងចំណោមសិស្សជាច្រើននាក់ផ្សេងទៀត ដែលមានឪពុកម្តាយបានគេចខ្លួនទៅកាន់ព្រំដែនកម្ពុជា-ថៃ ជាមួយនឹងខ្មែរក្រហម នៅក្នុងឆ្នាំ១៩៧៩ និងរស់នៅក្នុងស្រុកអន្លង់វែង។ ប្រជាជនខ្លះបានលើកឡើងថាការតាំងទីលំនៅក្នុងស្រុកអន្លង់វែងរបស់ខ្លួន ត្រូវបានធ្វើឡើងដោយសារតែសង្គ្រាមដែលកើតមានខណៈពេលដែលកងទ័ពអាវុធវៀតណាម បានបណ្តេញខ្មែរក្រហមចេញពីអំណាច ហើយសង្គ្រាមនេះពុំអនុញ្ញាតឲ្យអ្នកទាំងនោះ ស្នាក់អាស្រ័យនៅស្រុកកំណើតរបស់ខ្លួនឡើយ។ កត្តានេះក៏បានកើតមានលើឪពុកម្តាយរបស់ ចន្ទឡា ដែលបានចាកចេញពីខេត្តមណ្ឌលគិរីទៅកាន់ជំរំជនភៀសខ្លួននៅប្រទេសថៃ។ នេះសបញ្ជាក់ថា ប្រជាជនមួយចំនួនពុំមានជម្រើស គឺត្រូវផ្លាស់ទីនិងចូលរួមនៅក្នុងចលនាខ្មែរក្រហម ក្នុងនោះប្រជាជនភាគច្រើនជាអ្នកគាំទ្រដ៏ស្មោះស្ម័គ្រ។ ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលនាំឲ្យមានការគាំទ្រនេះ គឺថាប្រជាជនជាច្រើនត្រូវបានបំពាក់បំប៉នឲ្យប្រឆាំងនឹងសត្រូវប្រវត្តិសាស្ត្ររួមគឺវៀតណាម និងបន្តភាពស្មោះស្ម័គ្រចំពោះបុព្វហេតុនេះរហូតដល់ខ្មែរក្រហមរំសាយនៅក្នុងឆ្នាំ១៩៩៨។ នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ខ្មែរក្រហមត្រូវបានជឿជាក់ថាបានបង្កឲ្យប្រជាជនប្រមាណជាង១.៧លាននាក់ បាត់បង់ជីវិត ដោយសារតែការធ្វើការហួសកម្លាំង ជំងឺ ការបង្អត់អាហារ និងការសម្លាប់រង្គាល។

ក្រៅពីសិក្សាអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យពីសមាជិកគ្រួសាររបស់ខ្លួន ចន្ទឡា បានចូលរួមនៅក្នុងវេទិកានេះជាលើកដំបូង ដែលផ្តល់ឱកាសឲ្យខ្លួនអាចយល់ដឹងស៊ីជម្រៅ ចំពោះប្រធានបទពិភាក្សានៅក្នុងវេទិកាថ្នាក់រៀននេះ។ ទន្ទឹមនឹងនេះដែរ ចន្ទឡា បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចពិភាក្សាផ្ទាល់ជាមួយនឹងមិត្តរួមថ្នាក់ និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

វេទិកាថ្នាក់រៀន ត្រូវបានរៀបចំឡើងនៅក្នុងស្រុកអន្លង់វែង ដែល៨០ភាគរយនៃប្រជាជនសរុបចំនួន៦ម៉ឺននាក់គឺជាអតីតសមាជិកខ្មែរក្រហម។ ជាក់ស្តែង មនោគមវិជ្ជាកុម្មុយនីស្ត ដែលដក់ជាប់ក្នុងផ្នត់គំនិតរបស់ប្រជាជនក្នុងតំបន់នេះ អស់រយៈពេលយ៉ាងយូរនៅតែបន្ត និងមានឥទ្ធិពលលើបែបបទរស់នៅរបស់អ្នកទាំងនេះ ក៏ដូចជាសហគមន៍រហូតមកទល់បច្ចុប្បន្ន។ ប្រជាជនមូលដ្ឋាននិយាយរៀបរាប់អំពីប្រវត្តិសាស្ត្រទៅតាមបែបផែនរបស់ខ្លួន នៅក្នុងចលនានេះ។ ជាលទ្ធផល ការបង្រៀនប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងស្រុកអន្លង់វែង គឺជាការខិតខំប្រឹងប្រែងថ្មីសន្ធាងមួយ។ នេះគឺជាឧបសគ្គមួយដែរ ព្រោះថាឪពុកម្តាយរបស់សិស្សានុសិស្សភាគច្រើនបានបម្រើចលនានេះ រហូត


សិស្សានុសិស្សវិទ្យាល័យត្រពាំងតាវឡើងធ្វើបទបង្ហាញពីមេរៀ

ដល់ឆ្នាំ១៩៩៨។

ចន្ទឡា ពុំបានពើបប្រទះនឹងបញ្ហាក្នុងការសិក្សាអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈវេទិការបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ព្រោះថាវេទិកានេះមានសារប្រយោជន៍ណាស់ក្នុងការផ្តល់ចំណេះដឹងដល់ខ្លួន។ ចន្ទឡា បានលើកឡើងថា៖ «វេទិកានេះ គឺជាវិធីសាស្ត្រមួយដែលខ្ញុំអាចយល់ដឹងអំពីប្រវត្តិសាស្ត្របានកាន់តែច្បាស់»។ ចន្ទឡា បានឲ្យដឹងថា ឪពុកម្តាយរបស់ខ្លួនបានភៀសខ្លួនពីភូមិកំណើត


នប្រវត្តិកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ «១៩៧៥-១៩៧៩» ជាក្រុម

នៅក្នុងខេត្តមណ្ឌលគិរី ដែលស្ថិតនៅប៉ែកឦសាននៃប្រទេសកម្ពុជា និងបានបម្រើដល់ខ្មែរក្រហម ដោយសារតែសង្គ្រាមជាមួយវៀតណាម។ ឪពុកម្តាយរបស់ ចន្ទឡា បានរៀបរាប់ប្រាប់គេថា គាត់ចង់រស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ព្រោះ តាម៉ុក មើលថែទាំអ្នកក្រោមបង្គាប់បានយ៉ាងល្អ។ តាម៉ុក បានផ្តល់ឲ្យអ្នករាល់គ្នានូវតម្រូវការមូលដ្ឋាន ដូចជាស្បៀងអាហារជាដើម។

ពាក្យថា «ខ្មែរក្រហម» បង្កប់អត្ថន័យដ៏ខ្លាំងក្លាមួយ។ ពាក្យនេះអាចត្រូវបានចាត់ទុកថាជា «ការរើសអើង និងការបែងចែក» ដែលរារាំងដល់សន្តិភាព និងស្ថិរភាព។ ចំពោះ ចន្ទឡា និងឪពុកម្តាយរបស់ខ្លួន ពាក្យនេះតំណាងឲ្យចលនាទាំងមូល គឺមិនមែនសំដៅលើបុគ្គលទេ។ ចន្ទឡា បានសិក្សាអំពីអត្ថន័យនៃពាក្យនេះពីវេទិកាថ្នាក់រៀនថាជា ឈ្មោះដែលសម្តេចព្រះ នរោត្តម សីហនុ ដាក់ឲ្យសត្រូវរបស់ព្រះអង្គ គឺក្រុមកុម្មុយនីស្ត។

ប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់ទុកថា ជាផ្នែកដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្រកម្ពុជា។ ដោយសារមូលហេតុនេះហើយ ចន្ទឡា មិនអាចបំភ្លេចប្រវត្តិសាស្ត្រនេះបានទេ។ ផ្ទុយទៅវិញ ប្រវត្តិសាស្ត្រនេះត្រូវតែកត់ត្រាទុក និងចងចាំ ព្រោះថារបបនេះជារបបផ្តាច់ការដែលបង្កទៅជាអំពើប្រល័យពូជសាសន៍។ របបនេះបានលុបបំបាត់រាល់សិទ្ធិមូលដ្ឋានរបស់ប្រជាជន ជាពិសេស គឺសិទ្ធិរស់រានមានជីវិត។

ការពិភាក្សាជាក្រុម និងការធ្វើបទបង្ហាញ នាំឲ្យ ចន្ទឡា និងមិត្តរួមថ្នាក់យល់បានកាន់តែច្បាស់អំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ។ ចន្ទឡា បានពោលថា «បរិយាកាសអប់រំបែបនេះ ជំរុញចិត្តឲ្យខ្ញុំ និងមិត្តរួមថ្នាក់ឲ្យបណ្តុះការគិតត្រិះរិះពិចារណា។ ជាឧទាហរណ៍ យើងបានចាប់ផ្តើមពិចារណាថាតើការដឹកនាំបែបផ្តាច់ការគឺ ល្អ ឬយ៉ាងណា។ នេះពឹងផ្អែកលើយើងដែលជាមនុស្សជំនាន់ថ្មី ក្នុងការរារាំងប្រវត្តិសាស្ត្រដ៏ខ្លោចផ្សានេះពីការកកើតមាន»។

នៅពេលត្រូវបានសួរថា តើការសិក្សាអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ អាចចូលរួមចំណែកនៅក្នុងដំណើរការកសាងសន្តិភាពឬទេ ចន្ទឡា បានងក់ក្បាលយល់ស្រប ព្រមទាំងលើកឡើងថា សកម្មភាពនេះអាចជួយដល់ការអភិវឌ្ឍប្រទេសរបស់យើង។ របបខ្មែរក្រហមគឺជាឧទាហរណ៍មួយបញ្ជាក់ថា របបមួយមិនអាចសម្រេចបានសន្តិភាពទេប្រសិនបើប្រជាជនត្រូវបានគាបសង្កត់។ នេះ

ស្របទៅនឹងពាក្យមួយឃ្លាដែលតែងត្រូវបានលើកឡើង គឺ «ការគាបសង្កត់បង្កើតឲ្យមានការរើបម្រះ»។ ប្រជាជនត្រូវទទួលបានសិទ្ធិសេរីភាពរបស់ខ្លួន។ មតិយោបល់របស់ប្រជាជនត្រូវតែទទួលបានការស្តាប់ និងការគោរព។ បុគ្គលម្នាក់ៗមានអាចចូលរួមចំណែក នៅក្នុងការអភិវឌ្ឍប្រទេសជាតិរបស់យើងទៅតាមលទ្ធភាពរបស់គេ។ អ្នកដឹកនាំខ្មែរក្រហមត្រូវតែទទួលខុសត្រូវ ចំណែកអ្នកនៅក្រោមបង្គាប់ធ្វើទៅតាមបញ្ជាថ្នាក់លើប៉ុណ្ណោះ។ ចន្ទឡា បាននិយាយថា «អ្នកត្រូវធ្វើតាមបញ្ជា បើមិនដូច្នេះទេ អ្នកនឹងត្រូវសម្លាប់»។

ចំពោះបដិវត្តន៍ខ្មែរក្រហម ប្រជាជនតំបន់ភ្នំត្រូវបានចាត់ទុកថា «ស្មោះស្ម័គ្រ និងស្មោះត្រង់» ចាប់តាំងពីដើមដំបូង។ នៅដំណាក់កាលបន្ទាប់នៃរបបនេះ ប្រជាជនក្រុមនេះត្រូវប្រឈមនឹងបន្សុទ្ធកម្មជាប្រព័ន្ធនិងរីករាលដាល។ ចន្ទឡា យល់ថា នេះពិតជាសោកសង្រេងចំពោះប្រជាជនព្រោះថាអ្នកទាំងនេះត្រូវបានកំណត់មុខសញ្ញា ហើយសម្លាប់ចោល។ នេះគឺជាបញ្ហានៃអ្នកដឹកនាំខ្មែរក្រហម និងគោលនយោបាយដែលរបបបានប្រើប្រាស់ដើម្បីគ្រប់គ្រងប្រទេស ហើយរបបនេះធ្វើឲ្យប្រជាជនបាត់បង់ភាពជាមនុស្ស និងមិនត្រូវបានផ្តល់តម្លៃ។

ចន្ទឡា បានលើកឡើងអំពីសារសំខាន់នៃការសិក្សាអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ។ ចន្ទឡា បាននិយាយថា «វាពិតជាមានសារសំខាន់ណាស់ចំពោះយើងក្នុងការឆ្លុះបញ្ចាំង និងគិតថ្មីងថ្លៃងសម្រាប់អនាគតកាល។ កាលបើយើងសិក្សាអំពីប្រវត្តិសាស្ត្របានកាន់តែច្រើន យើងអាចបណ្តុះការត្រិះរិះពិចារណា ដែលអាចជំរុញឲ្យការរស់នៅប្រចាំថ្ងៃរបស់យើងមានភាពប្រសើរឡើង និងអាចធ្វើការសម្រេចចិត្តបានឈ្លាសវៃជាងមុន»។ ចន្ទឡា លើកទឹកចិត្តឲ្យអ្នកចូលរួមទាំងអស់គិត និងសម្រេចចិត្តអំពីអ្វីដែលក្នុងនាមជាបុគ្គលដែលអាចសម្រេចអនាគតរបស់ប្រទេសកម្ពុជា យើងគួរឬមិនគួរធ្វើនាពេលបច្ចុប្បន្នក៏ដូចជាពេលអនាគត។ ចន្ទឡា ក៏បានគូសបញ្ជាក់ថា ការដឹកនាំប្រទេសជាតិមិនគួរបង្កហានិភ័យលើអ្នកដទៃទាំងផ្នែកផ្លូវកាយ និងផ្លូវស្មារតីឡើយ។

លី សុខឃាង


សិស្សានុសិស្សវិទ្យាល័យត្រពាំងតាវ ថតរូបជុំគ្នាជាមួយបុគ្គលិក និងនាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

# អ៊ុម ឆន ត្រូវបានចាប់ខ្លួនពីបទប្រឆាំងនឹងបដិវត្តន៍
# ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D07380

ខ្ញុំឈ្មោះ អ៊ុម ឆន អាយុ២៩ឆ្នាំ (នៅឆ្នាំ១៩៧៨) មានស្រុកកំណើតនៅភូមិព្រែកផ្កាំឃុំព្រែកអន្ទរ ស្រុកពាមរ ភូមិភាគបូព៌ា ខេត្តព្រៃវែង។ នៅឆ្នាំ១៩៦០ ខ្ញុំបានចូលរៀននៅសាលាព្រែកផ្កាំ។ ក្រោយមក ខ្ញុំបានផ្លាស់ទៅរៀននៅសាលាព្រែកអន្ទះរហូតដល់ថ្នាក់ទី៧។ នៅឆ្នាំ១៩៦៧ ខ្ញុំបានឈប់រៀនមកជួយរកស៊ីឪពុក។ ក្រោយមកបានពីរឆ្នាំ ខ្ញុំផ្លាស់មកធ្វើជាកម្មករនៅរោងចក្រសិប្បកម្មដែក។ នៅពាក់កណ្ដាលឆ្នាំ១៩៦៩ ថន ដែលជាជាងស្លរដែកនៅរោងសិប្បកម្មតំបន់២៤ បានអប់រំខ្ញុំឲ្យចូល សេ.អ៊ី.អា ដោយមានឈ្មោះ ផុំ និងឈ្មោះ ស៊ឹម ជាអ្នកទទួលស្គាល់។

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ថន បានចាត់តាំងខ្ញុំឲ្យទៅបង្កប់ខ្លួននៅស្រុកកំណើតដើម្បីស៊ើបរកខ្មែរបណ្ដាញ និងកសាងកម្លាំង សេ.អ៊ី.អា។ នៅឆ្នាំ១៩៧១ ថន ចេញពីភ្នំពេញទៅនៅស្រុកកំណើតវិញ ហើយខ្ញុំក៏ទាក់ទងគាត់ជាប់រហូត។ ពីរឆ្នាំក្រោយមក ខ្ញុំបានភ្ជាប់ខ្សែបណ្ដាញជាមួយ បងមាក លេខាស្រុកពាមរ និងបងធឿនប្រធានសន្តិសុខស្រុកពាមរ។ ខ្ញុំបានទាក់ទងជាមួយអ្នកទាំងពីរនេះរហូតដល់ក្រោយរំដោះ ឆ្នាំ១៩៧៥។ កម្លាំងដែលខ្ញុំកសាងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មានឈ្មោះដូចជា ឌីថូ, សៅបែម, ហ៊ឹម, អ៊ុន និង យឿន។

ក្រោយរំដោះឆ្នាំ១៩៧៥ ខ្ញុំមានតួនាទីជាអនុប្រធានសេដ្ឋកិច្ច ឃុំព្រែកអន្ទះ ស្រុកពាមរ។ បន្ទាប់មកទៀត នៅខែមិថុនា ឆ្នាំ១៩៧៥ដដែល បងយេន ដែលជាខ្សែចាត់តាំងរបស់បង មាក បានឧទ្ទេសនាមខ្ញុំឲ្យស្គាល់ឈ្មោះ ប្រាក់ ឌុក និង ទូច ថុន។ បក្ខពួករបស់ខ្ញុំបានរៀបចំផែនការបំផុសប្រជាជនឲ្យប្រឆាំងនឹងបដិវត្តន៍ចំពោះការដាក់បញ្ចូលទ្រព្យសម្បត្តិផ្សេងៗជារបស់សហករណ៍រួម និងទាមទារយកទ្រព្យសម្បត្តិឯកជនមកវិញ។ ចុងឆ្នាំ១៩៧៥ បងយេន ទទួលបានផែនការពីបងមាកឲ្យលាក់អាណិកជនយួនទុកនៅឃុំព្រែកអន្ទះ ព្រោះពេលនោះអង្គការមានផែនការត្រូវប្រមូលជនជាតិយួន។ ជនជាតិយួនដែលលាក់ទុកទាំងនោះមានឈ្មោះ ដូចជា៖ ផល្លា, អេង, អឿន, កែវ មឿង, ធិញ, កាម៉ាង, កាឃាន, នឿង, ង៉ៀង ធីឡាយ, តឹកង៉ើ, តឹកវ៉ានថា និង យ៉ាំង ឡាយ។

ដើមឆ្នាំ១៩៧៦ បងយេន ឡើងមកកាន់កសិកម្មស្រុកពាមរ បងយួស ឡើងជាប្រធានឃុំវិញ។ ក្រោយមកទៀត បងយួស បានប្រាប់ខ្ញុំឲ្យទាក់ទងជាមួយឈ្មោះ យ៉ន ជាប្រធានភូមិពោធិ៍រាម ស្រុកព្រៃវែង, ផា ជាប្រធានឈ្លបភូមិ និង ឈុន អនុប្រធានភូមិ។ ខែមិថុនា ឆ្នាំ១៩៧៥ បងយួស បានឲ្យខ្ញុំយកសំបុត្រមួយទៅឲ្យបងយ៉ននិងបងឈុន។ អត្ថន័យរបស់សំបុត្រមានខ្លឹមសារប្រាប់ឲ្យ បងយ៉ន និង បងឈុន ធ្វើបាបប្រជាជននៅឃុំពោធិ៍រាម កុំឲ្យប្រជាជនទាំងនោះពេញចិត្តនឹងមាគ៌ាបដិវត្តន៍។ បក្ខពួករបស់ខ្ញុំបានធ្វើសកម្មភាពបន្តរហូតដល់ឆ្នាំ១៩៧៦ ដោយបានបំភ្លើសមាគ៌ាធ្វើស្រែក្នុង ១ហិកតា ៣តោន ទៅ៦តោន។ តាមរយៈផែនការនេះបក្ខពួកខ្ញុំបានយកសំណាប៦ខែទៅស្ទូងធ្វើឲ្យលិចទឹកអស់។ ពេលប្រជាជនដាច់បាយ ក្រុមរបស់ខ្ញុំបានចោទប្រជាជនថា មិនខិតខំធ្វើការស្អឹកទម្រន់បានជាអត់បាយ។

នៅខែមីនា ឆ្នាំ១៩៧៧ ខ្ញុំ និង បងឌុក បានទាក់ទងជាមួយខ្សែបណ្ដាញនៅឃុំព្រែកអន្ទះ។ ចំណែក បងយ៉ននិងបងឈុន ទាក់ទងគ្នាជាមួយអ្នកនៅឃុំពោធិ៍រាម ដើម្បីសហការគ្នាធ្វើសកម្មភាពបំផុសប្រជាជនឲ្យមានទំនាស់នឹងអង្គការ និងបំផ្លាញផលដំណាំរួម។ ក្រៅពីនេះ ខ្ញុំបានធ្វើសកម្មភាពផ្សេងៗជាច្រើនទៀតដែលប្រឆាំងនឹងបដិវត្តន៍ដូចជា ចាត់តាំងឲ្យខ្សែបណ្ដាញឈ្មោះ ពួន នៅឃុំព្រែកជ្រៃ ស្រុកពាមរ ដុតស្រូវឆេះ

អស់មួយធ្នឹម។ លើសពីនេះទៅទៀតខ្ញុំបានចាត់តាំងបងទេស ធ្វើការខាងសេដ្ឋកិច្ចនៅឃុំព្រៃ កណ្ដៀងធ្វើឲ្យលិចទូកដឹកអំបិលរលាយអស់៥០បាវ។ ក្រោយមក ក្រុមខ្ញុំបានប្រមូលពូជស្រូវនៅឃុំព្រែកអន្ទះ ដែលធ្លាប់ធ្វើម្ដងទទួលបានផលមួយហិកតា ៣តោនទៅ៤តោន ដូរដាក់ពូជស្រូវមួយហិកតាទទួលបានផលត្រឹមតែ៥០០ ទៅ៦០០គីឡូប៉ុណ្ណោះ។

បន្ទាប់ពីធ្វើសកម្មភាពនៅឃុំព្រែកអន្ទះហើយ ខ្ញុំ, បងយូស និង បងឌុក បានយកផែនការនេះមកពិភាក្សាជាមួយ បងអ៊ុត នៅឃុំព្រែកជ្រៃទៀត ដើម្បីយកមកអនុវត្តនៅព្រែកជ្រៃម្ដង។ បងអ៊ុត បានឯកភាពតាមផែនការនេះ ហើយខ្ញុំបានណែនាំ បងអ៊ុតឲ្យប្រាប់ប្រជាជនថា នេះជាផែនការរបស់អង្គការ បើអ្នកណាតវ៉ាត្រូវចាប់ខ្លួនពីបទប្រឆាំងជាមួយអង្គការ។ ក្នុងខែមករា ឆ្នាំ១៩៧៨ បងម៉ុន បានហៅខ្ញុំ និង បងឌុក ទៅជួបនៅផ្ទះរបស់គាត់។ ពេលនោះ បងម៉ុន បានប្រាប់ខ្ញុំអំពីផែនការធ្វើរដ្ឋប្រហារក្នុងខែ៤នៅភូមិភាគបូព៌ា។ បងម៉ុន បានប្រាប់ បងឌុក ឲ្យឃោសនាបំភ័ន្តកម្លាំងនៅការដ្ឋានមួយចំនួន ដើម្បីកាន់អាវុធធ្វើរដ្ឋប្រហារ ដោយប្រាប់អ្នកទាំងនោះថា កាន់អាវុធការពារការដ្ឋាន។

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៨ ខ្ញុំបានមកសួរ បងម៉ុន ដែលជាគណៈក្រុងព្រៃវែងពីសភាពការណ៍នានាដែលកំពុងកើតឡើង។ គាត់ប្រាប់ខ្ញុំវិញថា ឥឡូវមិនអីទេ ប៉ុន្ដែគាត់បានប្រាប់ឲ្យប្រមូលអីវ៉ាន់យកលាក់ទុកឲ្យហើយទៅតែពួកកងទ័ពមជ្ឈិមមកដល់ច្បាស់ជាយកអស់ជាមិនខាន។ ក្រោយមក បានមួយថ្ងៃខ្ញុំបានជួប មិត្តជី និង មិត្តសឿន។ អ្នកទាំងពីរប្រាប់ខ្ញុំថា អង្គការបានចាប់ខ្លួនខ្សែបណ្ដាញរបស់ខ្ញុំអស់ពីរបីនាក់ហើយ។ ពេលនោះបក្ខពួកខ្ញុំបាននាំគ្នាប្រមូលកងទ័ពស្រុកពាមរ និងបុគ្គលិកសន្ដិសុខទាំងអស់ ដើម្បីសហការរួមគ្នាទប់ទល់ជាមួយកងទ័ពអង្គការ។ បងម៉ុន ប្រាប់ខ្ញុំថា «សភាពការណ៍តានតឹងណាស់ ឯងត្រូវប្រយ័ត្នខ្លួនឲ្យមែនទែន ព្រោះកងទ័ពអង្គការចុះមកច្រើនណាស់»។

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨ កងទ័ពរបស់អង្គការ បានវាយលុកយ៉ាងខ្លាំង ជាហេតុបណ្ដាលឲ្យកងទ័ពស្រុកពាមរ និងកងសន្ដិសុខដាក់អាវុធចុះចូល។ បងម៉ុន និង បងសំ ត្រូវបានកងទ័ពអង្គការចាប់យកទៅក្រុងព្រៃវែង។ ចំណែកខ្ញុំ និង បងឌុក រត់មកបន្លំខ្លួនជាមួយប្រជាជនក្នុងឃុំព្រែកអន្ទះ បានរយៈពេលបីយប់បីថ្ងៃ។ បន្ទាប់ពីកើតមានព្រឹត្តិការណ៍នេះហើយ តាឈួន ដែលជាអនុលេខាស្រុកពាមរ តំបន់២៤ បានហៅខ្ញុំមកមន្ទីរស្រុក ដោយគាត់បានប្រាប់ខ្ញុំឲ្យប្រមូលកម្លាំងបងប្អូន ដែលរតាត់រតាយឲ្យមកនៅអង្គភាពវិញ។ ក្នុងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧៨ តាឈួន បានចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានកងចល័តស្រុកពាមរ នៅការដ្ឋានជ្រោយផល។ ខ្ញុំគ្រប់គ្រងទីនោះបានមួយរយៈ តាឈួនបានហៅខ្ញុំមកជួប ហើយប្រាប់ថា ប៉ុន្មានថ្ងៃនេះសភាពការណ៍តានតឹងណាស់ កងទ័ពមជ្ឈិមក្ដាប់ជាប់គ្រប់ទីកន្លែង សូម្បីតែតាមផ្លូវក៏មានទ័ពមជ្ឈិមយាមដែរ។ បន្ទាប់មកទៀត នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៨ តាឈួនប្រាប់ខ្ញុំថា «បក្ខពួកយើងបែកគ្នាអស់ហើយ ឯងទៅនៅសហករណ៍ឃុំព្រែកអន្ទះវិញទៅ ក្រែងបានគេចផុតពីការចាប់ខ្លួនរបស់អង្គការ»។ ខ្ញុំក៏បានត្រឡប់មករស់នៅសហករណ៍ឃុំព្រែកអន្ទះវិញ។ ខ្ញុំមកនៅទីនេះបានបួនថ្ងៃក៏ត្រូវអង្គការចាប់ខ្លួនតែម្ដង។

កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់ដែលជាប់ឃុំឃាំងនៅមន្ទីរសន្ដិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានឡើយថា ចម្លើយរបស់អ្នកទោស អ៊ុម ឆន នេះពិតប្ យ៉ាងណានោះទេ។

**ដាត ចាន់សុនិតា**

# ដើមស្រឡៅ

ដើមស្រឡៅបានដុះលូតលាស់ភាគច្រើននៅតំបន់អាស៊ីអាគ្នេយ៍និងនៅប្រទេសដែលមានទទួលអាកាសធាតុត្រូពិច។ នៅប្រទេសកម្ពុជា ដើមស្រឡៅដុះភាគច្រើននៅតំបន់ភ្នំ និងខ្ពង់រាបភាគខាងជើងនៃប្រទេស រួមមាន ៖ ខេត្តសៀមរាប ឧត្តរមានជ័យ និងខេត្តព្រះវិហារ។ ដើមស្រឡៅ មានមែកតូចៗបែកចេញពីដើមដែលដុះត្រង់ទៅលើ និងមានកម្ពស់រហូតដល់ទៅជាង២០ម៉ែត្រ។ ដើមស្រឡៅមានស្លឹកតូចៗពណ៌បៃតងស្រស់ សាច់ឈើពណ៌សថ្លារឹងនិងសំបករលោងប៉ុន្តែគម្រើមដូចជាស្រកាពស់។ ដើមស្រឡៅចេញផ្កាពណ៌ស្វាយស្រស់ក្នុងមួយឆ្នាំម្តង នៅរដូវក្តៅ។

តាមវចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត ស្រឡៅ គឺជាឈ្មោះឈើធំមួយប្រភេទសណ្ឋានស្រដៀងនឹងត្របែកព្រៃ ប៉ុន្តែដើមធំជាង សាច់ស្និទ្ធស្អាតជាង ហើយប្រើធ្វើការបានច្រើនយ៉ាង ៖ ក្តារស្រឡៅ, ទូស្រឡៅ និង តុស្រឡៅ។

ប្រជាជនខ្មែរនិយមយកដើមស្រឡៅយកមកកែច្នៃធ្វើជាគ្រឿង តុ ទូ កៅអី គ្រែ ប្រវាទូក និងគ្រឿងឈើសម្រាប់ធ្វើទូក។ ប្រជាជនខ្មែរខ្លះទៀត ក៏បានអារ និងច្រៀកដើមស្រឡៅធ្វើជាក្តារ និងគ្រឿងឈើសម្រាប់សង់ផ្ទះ។ បើតាម


ផ្កាស្រឡៅ


ដើមស្រឡៅនៅក្នុងព្រៃសង្ឃរុក្ខវ័ន ខេត្តឧត្តរមានជ័យ

ទំនៀមទម្លាប់ និងជំនឿពីបុរាណរបស់អ្នកស្រុកស្វាយលើ ក្នុងខេត្តសៀមរាប និងស្រុកគូលែន ខេត្តព្រះវិហារ នៅពេលអ្នកស្រុករៀបចំសាងសង់ផ្ទះថ្មី ម្ចាស់ផ្ទះត្រូវមានឈើចំនួន ១២មុខ រួមទាំងស្រឡៅ មកផ្សំធ្វើជាគ្រឿងផ្ទះ មានដូចជា សសរ ផ្ដោង ផ្ទាន ក្ដារ រនាបក្រាល បង្កង់ រនុក រនង ដើម្បីឲ្យម្ចាស់ផ្ទះសម្បូរសប្បាយ និងចម្រុងចម្រើន។


សត្វត្រដក់នៅក្នុងព្រៃសង្ឃរុក្ខវ័ន ខេត្តឧត្តរមានជ័យ

ដោយសារប្រជាជនខ្មែរមានជំនឿ ប្រពៃណី វប្បធម៌ និងរស់នៅប្រចាំថ្ងៃជាមួយធម្មជាតិតាំងពីយូរលង់ណាស់មកហើយ ទើបប្រជាជនខ្មែរ អ្នកនិពន្ធ និងអ្នកប្រាជ្ញពីសម័យបុរាណខ្លះបានយកឈ្មោះដើមឈើ មកដាក់ឈ្មោះភូមិ ឬសហគមន៍ដែលខ្លួនបានរស់នៅ ដាក់ឈ្មោះបទចម្រៀងដែលខ្លួនបានតែងនិពន្ធ និងបានសរសេរក្នុងសុភាសិតដើម្បីអប់រំ និងប្រៀនប្រដៅមនុស្ស ដោយបានយកដើមស្រឡៅមកភ្ជាប់ជាមួយ ដែលមានឃ្លាមួយពោលថា «កុំពត់ស្រឡៅ កុំប្រដៅមនុស្សខូច»។

សុភាសិតនេះ បានបង្ហាញពីតថភាពសង្គមខ្មែរ ដោយបានបង្កប់នូវគំនិត ការសញ្ជឹងគិត ការត្រិះរិះពិចារណា និងការអប់រំដោយបានប្រៀបធៀបដើមឈើ និងធម្មជាតិទៅនឹងអត្តចារិតរបស់មនុស្ស។ ស្រឡៅ គឺជាឈើមួយប្រភេទដែលមានសាច់រឹង ហេតុដូច្នេះហើយយើងមិនងាយពត់ស្រឡៅទៅតាមចិត្តដែលយើងចង់បាននោះទេ។ នៅពេលដែលយើងខំប្រឹងពត់ឈើស្រឡៅកាន់តែខ្លាំងក៏អាចបណ្ដាលឲ្យស្រឡៅបាក់ដែរ។ ម្យ៉ាងទៀត ស្រឡៅមានសាច់ឈើរមូរចូលគ្នាជាក្រុម ដែលជាងឈើតែងប្រើឃ្នៀបគៀបតម្រង់ ប៉ុន្តែនៅពេលដកឃ្នៀបចេញ ឈើស្រឡៅបានរមូរត្រឡប់ទៅរកសភាពដើមវិញដដែល។ រីឯមនុស្សខូច គឺសំដៅទៅលើមនុស្សដែលមានគំនិត មាយាទអាក្រក់ វៀចវេរ និងមនុស្សដែលបង់អស់នូវកិត្តិយស សេចក្ដីថ្លៃថ្នូ ដែលពិបាកនឹងកែប្រែចារិត និងប្រែខ្លួនទៅជាមនុស្សល្អបាន។ ទោះបីយ៉ាងណាក៏ដោយ ក៏សុភាសិតនេះបានបង្កប់នូវខ្លឹមសារអប់រំជ្រាលជ្រៅ ភាពវៃឆ្លាត និងប្រាជ្ញារបស់មនុស្សក្នុងដោះស្រាយរាល់បញ្ហាស្មុគស្មាញ ដែលបានកើតឡើងនៅក្នុងសង្គម។ មនុស្សអាចកែច្នៃធម្មជាតិ ដោយយកឈើស្រឡៅដែលមានសាច់រឹង ស្រួយ និងរមូរទៅជាសម្ភារប្រើប្រាស់តាមតម្រូវការ និងគ្រឿងសង្ហារឹមសម្រាប់តាំងលម្អនៅតាមផ្ទះ ការិយាល័យធ្វើការ និងតាមទីសាធារណនានា។ មនុស្សក៏អាចកែប្រែជនខិលខូច បោកប្រាស់ ចោរលួច ចោរប្លន់ រហូត


សត្វសេកនៅក្នុងព្រៃសង្ឃរុក្ខវ័ន ខេត្តឧត្តរមានជ័យ

ដល់ទៅឧក្រិដ្ឋជនឲ្យក្លាយទៅជាមនុស្សល្អបានដែរ តាមរយៈការអប់រំ រៀនសូត្រ បណ្ដុះបណ្ដាលជំនាញ វិជ្ជាជីវៈ សីលធម៌ និងសង្គមជាដើម។

នៅក្នុងបទចម្រៀងខ្មែរ អ្នកនិពន្ធទំនុកចម្រៀង គង់ ប៊ុនឈឿន ក៏បានយកដើមស្រឡៅមកតាក់តែងចេញជាបទ


ដើមស្រឡៅនៅក្នុងព្រៃសង្ឃរុក្ខវ័ន ខេត្តឧត្តរមានជ័យ

ចម្រៀងដែលចំណងជើង «ម្ចប់ស្នេហ៍ដើមស្រឡៅ»។ គង់ ប៊ុនឈឿន មុនពេលទទួលមរណភាពបានរៀបរាប់ពីប្រវត្តិនៃការតែងនិពន្ធបទចម្រៀងនេះដូចតទៅ ៖

នៅឆ្នាំ១៩៧៣ ខ្ញុំបានសរសេរសៀវភៅប្រលោមលោកមួយក្បាលដែលមានចំណងជើងថា «ដំនោរប៉ៃលិន»។ សៀវភៅប្រលោមនេះបានក្លាយជាសៀវភៅដ៏ពេញនិយមក្នុងចំណោមអ្នកអាន ដូច្នេះហើយលោក សូ ម៉ាន់ចាន់ ចាងហ្វាងផលិតកម្ម «វណ្ណចន្ទ» ភាពយន្តបានទិញសិទ្ធិសៀវភៅនេះដើម្បីថតជាខ្សែភាពយន្ត។

ទន្ទឹមនឹងនោះ ស្ទូឌីយោចម្រៀងបានស្នើសុំខ្ញុំឲ្យនិពន្ធបទចម្រៀងចំនួន៤បទថែមទៀត ដើម្បីដាក់បញ្ចូលទៅក្នុងខ្សែភាពយន្តនោះ។ បទចម្រៀងទាំងនោះគឺ ៖ ១) ម្ចប់ស្នេហ៍ដើមស្រឡៅ ២) ទំនួញហ្គីតាមាស ៣) ដំនោរប៉ៃលិន និង ៤) បេះដូងកំព្រា។

បទចម្រៀងទាំង៤នេះ មានប្រជាប្រិយភាពយ៉ាងខ្លាំង បន្ទាប់ពីខាងស្ទូឌីយោបានស្នើសុំសិទ្ធិលើបទចម្រៀងទាំងនេះ ហើយថតចម្លងចែកចាយនៅតាមថាសចម្រៀងកាសែត និងចាក់ផ្សាយ។

ជាអកុសល ខ្សែភាពយន្តនេះមិនទាន់បញ្ចប់ទេ ហើយក៏មិនបានចាក់បញ្ចាំងដែរ រហូតដល់យោធាខ្មែរក្រហមមកដល់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ស៊ិន ស៊ីសាមុត និង រស់ សេរីសុទ្ធា ធ្លាប់បាននិយាយថាបានច្រៀងចម្រៀង «ម្ចប់ស្នេហ៍ដើមស្រឡៅ» ចេញពីបេះដូង និងពីសមត្ថភាពច្រៀងរបស់ខ្លួន។

ទោះបីបទចម្រៀងនេះបានកើតឡើង និងពេលរៀបរាប់លម្អិតតែនៅតំបន់ប៉ៃលិន អមជាមួយទំនុកភ្លេងស្រាល


ដើមស្រឡៅនៅក្នុងព្រៃសង្ឃរុក្ខវ័ន ខេត្តឧត្តរមានជ័យ

ស្រទន់ ផ្អែមល្ហែម ក៏ធ្វើឲ្យចម្រៀងនេះក្លាយទៅជាក្តីសុបិន របស់អ្នកស្តាប់ និងភាពស្រស់ស្អាតកាន់តែខ្លាំងឡើងដែរ។

គង់ ប៊ុនឈឿន បានរៀបរាប់ថា «មានការចងចាំមួយដែលមិនអាចបំភ្លេច ហើយដែលធ្វើឲ្យខ្ញុំមិនសប្បាយចិត្ត។ ខ្ញុំបានជួបស៊ិនស៊ីសាមុតនៅវត្តចម្ប៉ា ស្ថិតនៅក្នុងឃុំព្រែកឯង នៅពេលដែល ប៉ុល ពត បានជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥។ ស៊ិន ស៊ីសាមុត បានអង្គុយដោយយកកែងដៃរបស់គាត់ច្រត់លើជង្គង់ ហើយដៃទាំងពីររបស់គាត់អង្អែលក្បាលឆករបស់គាត់នៅក្នុងផ្ទះឈើមួយ ដោយមានយោធាខ្មែរក្រហមវ័យក្មេងព័ទ្ធជុំវិញ។

យោធាខ្មែរក្រហមវ័យក្មេងទាំងនោះបានឲ្យអង្ករ និងអាហារទៅ ស៊ិនស៊ីសាមុត ដោយស្នើសុំឲ្យ ស៊ិន ស៊ីសាមុត ច្រៀងចម្រៀងមួយបទ។ បទចម្រៀងដែលត្រូវបានស្នើសុំនោះគឺ «ម្ចប់ស្នេហ៍ដើមស្រឡៅ»។

ខ្ញុំបានឮ ស៊ិន ស៊ីសាមុត ឆ្លើយតបទៅនឹងយោធាខ្មែរក្រហមវ័យក្មេងទាំងនោះដោយការញញឹមស្ងួតថា «ការច្រៀងរបស់ខ្ញុំមិនល្អទៀតទេ...»។ នៅពេលឮពាក្យទាំងនោះ ខ្ញុំមានអារម្មណ៍សោកសង្រេងយ៉ាងខ្លាំងចំពោះ ស៊ិន ស៊ីសាមុត ហើយទឹកភ្នែករបស់ខ្ញុំក៏បានហូរចេញមក។ នៅពេលខ្ញុំរៀបចាកចេញបន្តដំណើរទៅមុខទៀតនោះ ស៊ិន សាមុត បានលួចខ្សឹបប្រាប់ខ្ញុំស្ងាត់ៗថា «ឈឿន! ត្រឡប់ទៅស្រុកកំណើតវិញចុះ ចំណែកខ្ញុំមិនទាន់អាចត្រឡប់ទៅវិញភ្លាមទេ ព្រោះប្រពន្ធរបស់ខ្ញុំទើបសម្រាលកូនបានរយៈពេលពាថ្ងៃប៉ុណ្ណោះ»។ ខ្ញុំបាននិយាយទៅកាន់ស៊ិនស៊ីសាមុតវិញថា«សូមស៊ូទ្រាំ ហើយកុំអស់សង្ឃឹមឲ្យសោះ។ ថ្ងៃណាមួយយើងនឹងបានទៅច្រៀងនៅភ្នំពេញវិញមិនខានឡើយ!»។ ស៊ិន ស៊ីសាមុត បានឆ្លើយទាំងឈឺចាប់នៅឃ្លាចុងក្រោយថា «មិនអាចទេ ឈឿន! ខ្ញុំបាត់បង់ក្តីសង្ឃឹមរបស់ខ្ញុំអស់ហើយ។ យើងប្រហែលជាមិនបានជួបមុខគ្នាម្តងទៀតទេ ហើយខ្ញុំក៏មិនប្រាកដថាបានច្រៀងចម្រៀងរបស់ ឈឿន ដែរ!»។

ដោយចៃដន្យ មានយោធាខ្មែរក្រហមវ័យក្មេងពីរបីនាក់ទៀតកំពុងយួរវិទ្យុដែលកំពុងចាក់ផ្សាយបទចម្រៀង «ម្ចប់ស្នេហ៍ដើមស្រឡៅ» មកឲ្យ ស៊ិន ស៊ីសាមុត ស្តាប់ រួចសួរថា «តើអ្នកច្រៀងបទចម្រៀងនេះមែនទេ?»។ ស៊ិន ស៊ីសាមុត បានងក់ក្បាល។ បទចម្រៀងនេះមានអត្ថន័យដូចខាងក្រោម៖

I. (ស) - ក្អែកខ្មៅបូលយំ លើភ្នំផ្កាយព្រឹក សំឡូតអូននឹករលឹកអូរជា ស្ទឹងស្ពៅត្រែងត្រាក ជីសាកទ្រូងខ្វា បល្ល័ងជលសា បុស្បាផ្កាព្រៃ។

II. (ប)- យើងនាំគ្នាទៅកាត់ភ្នំដំបងកំពង់ចម្លងក្រុងម្តុងស្នេហ៍-ថ្មី ស្រឡៅស្រឡូន ភ្នំកូនដំរី សន្សើមដោតដី ដៃអូនជាខ្នើយ។

R. (ស) - ត្រកួនព្រលិត ចិត្តដូចតែគ្នា ស្មោះនឹងស្នេហា ពុំដែលកន្តើយ

(ប) - បងនឹងពុះពារ លុះគ្រាដល់ត្រើយ អូនកុំព្រួយឡើយ ណំាស្រស់ពិសី។

III. (ប) - ចង្រិតស្រែកច្រៀង ចម្រៀងអភ័ព្វ មន្តស្នេហ៍ព្រៃគុប ម្ចប់ដើមស្រឡៅ

(ស) - អូនលក់បេះដូង ជូនទ្រូងប្រុសពៅ ពីថ្ងៃនេះទៅ យើងបានសុខអើយ។

នៅក្នុងរបបខ្មែរក្រហមសិល្បៈករ អ្នកចម្រៀង គឺជាគោលដៅនៃការតាមដាន ចាប់ខ្លួន និងឃុំឃាំង។ ខ្មែរក្រហមបានចាត់ទុកថា សិល្បករបានបន្តឲ្យសង្គមចលាចល ពាលាអាវ៉ាសែ ទៅតាមវប្បធម៌បរទេសដែលប្រឆាំងនឹងមាគ៌ាបដិវត្តន៍។ សិល្បករជាច្រើន បានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម។ មានសិល្បៈករតិចតួចប៉ុណ្ណោះដែលនៅរស់ជីវិតបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ហើយក្នុងចំណោមអ្នកទាំងនោះមួយចំនួនបានភៀសខ្លួន និងបន្តរស់នៅបរទេសរហូតមកដល់សព្វថ្ងៃ។

ដើមស្រឡៅ មិនត្រឹមតែមានបង្ហាញពីសម្រស់នៃធម្មជាតិ សេចក្តីស្នេហាភាពសប្បាយរីករាយរបស់មនុស្សប៉ុណ្ណោះទេ គឺបានផ្សារភ្ជាប់ទៅនឹងប្រវត្តិសាស្ត្រនៃភាពភ័យរន្ធត់ខ្លោចផ្សារ និងការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម។

*សោម ប៊ុនថន*

# ព្រៃឈើ និងយោធាខ្មែរក្រហម

ព្រៃឈើបានផ្តល់នូវជីវៈចម្រុះដ៏ចាំបាច់សម្រាប់ទ្រទ្រង់ជីវិតរបស់មនុស្ស សត្វនៅលើផែនដី។ ព្រៃឈើបានដើរតួនាទីដ៏មានសារសំខាន់ក្នុងការថែរក្សាការប្រែប្រួលអាកាសធាតុ ផ្តល់ជាអាហារ ជាម្ហូប និងជាជម្រកសម្រាប់មនុស្សសត្វជ្រកកោណ។ ប្រទេសកម្ពុជាសម្បូរទៅដោយសត្វព្រៃ និងដើមឈើគ្រប់ប្រភេទ ក្នុងចំណោមប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ធនធានធម្មជាតិទាំងនេះបានធ្វើឲ្យប្រជាជនកម្ពុជារស់នៅបានយ៉ាងងាយស្រួល។ ក្រោយមកព្រៃឈើនៅក្នុងប្រទេសកម្ពុជាក៏ចាប់ផ្តើមបាត់បង់បន្តិចម្តងៗ ដោយការសឹករេចរឹល ការកាប់រាន និងសង្គ្រាម។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានបង្កើតកម្លាំងឧទ្ទាមនៅតាមបណ្តោយឆ្នេរសមុទ្រភាគខាងត្បូង និងខាងលិច ព្រមទាំងនៅតាមបណ្តោយភ្នំដងរែកភាគខាងជើងនៃប្រទេសកម្ពុជា ជាប់ព្រំប្រទល់ជាមួយប្រទេសថៃ និងប្រទេសឡាវ។ នៅទីនោះកងកម្លាំងឧទ្ទាមខ្មែរក្រហមបានទទួលជំនួយពីក្រៅប្រទេសដើម្បីប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញ ដែលគាំទ្រដោយប្រទេសវៀតណាម។ ក្រោយមកសហគមន៍អន្តរជាតិក៏បានផ្តាច់ជំនួយពីកងកម្លាំងឧទ្ទាមខ្មែរក្រហម ដែលធ្វើឲ្យខ្មែរក្រហមកាប់ព្រៃឈើកាន់តែច្រើនឡើងលក់ទៅឲ្យឈ្មួញថៃ ដើម្បីយកលុយមកទិញម្ហូបអាហារ សម្ភារប្រើប្រាស់ និងអាវុធសម្រាប់កងទ័ព។

គឹម ណន ភេទប្រុស អាយុ៥៩ឆ្នាំ អតីតយោធាខ្មែរក្រហម មានទីលំនៅបច្ចុប្បន្នរស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យបានរៀបរាប់ពីជីវិតនៅក្នុងព្រៃ និងការងារ



ពិធីសមាហរណកម្មជាផ្លូវការពេលដែលយោធាខ្មែរក្រហម ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅស្រុកអន្លង់វែង នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

ជាយោធាថា ខ្ញុំបានចូលធ្វើជាយោធាខ្មែរក្រហមតាំងពីអាយុ ១៨ឆ្នាំ នៅស្រុកកំណើតក្នុងខេត្តសៀមរាប។ អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំក៏ត្រូវអង្គការចាត់តាំងឲ្យទៅប្រចាំការនៅអង្គភាពកាំភ្លើងធំ។ ពេលនោះខ្ញុំបានដាំដំណាំសម្រាប់ហូប ដូចជា ឪឡឹក ម្នាស់ និងដំណាំផ្សេងៗទៀត។ ក្រៅពីនោះ ខ្ញុំបានចិញ្ចឹមជ្រូក មាន់ ទា ថែមទៀត។ ខ្ញុំមានអាហារសម្រាប់ហូបចុកគ្រប់គ្រាន់ មិនខុសពីសព្វថ្ងៃនេះទេ ដោយក្នុងមួយថ្ងៃខ្ញុំហូបបាយបីពេល។ ខ្ញុំមិនបានដឹងថា ឪពុកម្ដាយ បងប្អូន សាច់ញាតិ និងប្រជាជនខ្មែរទូទាំងប្រទេសពុំមានអាហារហូបទេ។ អំឡុងពេលនោះ ខ្ញុំគិតថាប្រជាជនខ្មែរមានរបបអាហារហូបគ្រប់គ្រាន់ ដូចនៅអង្គភាពរបស់ខ្ញុំ ព្រោះអង្គការបានប្រាប់ថា ប្រជាជនទទួលបានរបបអាហារហូបចុកបរិបូណ៌គ្រប់ៗគ្នា។

រហូតមកដល់ឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចូលមក ខ្ញុំត្រូវបានប្រធានកងពលខ្មែរក្រហមបញ្ជូនឲ្យទៅកាន់កាំភ្លើងធំនៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ ពេលខ្ញុំទៅដល់ដំបូង ខ្ញុំមិនឃើញវត្តមានកងទ័ពវៀតណាមទេ គឺឃើញតែព្រៃស្បែងស្ងាត់ជ្រងំ។ ស្រាប់តែព្រឹកឡើង កងទ័ពវៀតណាមបានវាយសម្រុកចូលមកយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយការវាយប្រយុទ្ធគ្នាក៏ចាប់ផ្ដើមផ្ទុះឡើង។ ប្រធានអង្គភាពរបស់ខ្ញុំ បានបញ្ជាឲ្យខ្ញុំបាញ់បណ្ដើរ និងដកខ្លួនបណ្ដើរ។ បន្ទាប់មកក្រុមរបស់ខ្ញុំក៏បែកខ្ញែកគ្នាអស់។ កងទ័ពវៀតណាមបាញ់រះមកលើខ្សែត្រៀមខ្ញុំបីយប់បីថ្ងៃ។ ខ្ញុំស្ថិតនៅក្នុងព្រៃជាប់ព្រំប្រទល់ជាមួយប្រទេសឡាវ ដែលមានសភាពងងឹតឈឹងមើលមិនឃើញពន្លឺថ្ងៃឡើយ។ ខ្ញុំឮសូរតែសម្រែកសត្វចចក ខ្លា ដំរី ស្រែកកងរំពងពេញព្រៃ។ ខ្ញុំគិតក្នុងចិត្តថា ជីវិតខ្ញុំដែលមិនស្លាប់នៅពេលវាយប្រយុទ្ធគ្នា ប៉ុន្តែបែជាមកត្រូវស្លាប់ដោយសារសត្វស៊ីទៅវិញ។ សំណាងល្អពេលនោះ ខ្ញុំអាចឡើងដើមឈើបានដូច្នេះពេលយប់ខ្ញុំក៏បានឡើងទៅដេកនៅលើចុងឈើ។ ខ្ញុំវង្វេងនៅក្នុងព្រៃមិនដឹងទិសតំបន់ ព្រោះពេលនោះព្រៃក្រាស់ខ្ញុំមិនអាចមើលឃើញផ្លូវភ្នំដូចបច្ចុប្បន្នឡើយ។ ក្រោយមក ខ្ញុំបានឮសូរកាំភ្លើងផ្ទុះ ខ្ញុំបានដោះខោអាវចេញពីខ្លួនហើយដើរទៅវាលមួយ ដោយស្រែកសួរថា ៖ «បងៗនៅអង្គភាពណា?»។ អ្នកទាំងនោះក៏បានបោយដៃហៅខ្ញុំ។ ពេលខ្ញុំដើរចូលទៅជិតទើបដឹងថា ជាកងទ័ពវៀតណាម។ ដោយសារខ្ញុំខ្លាចកងទ័ពវៀតណាមទាំងនោះសម្លាប់ ខ្ញុំក៏រត់ចូលព្រៃវង្វេងពីរយប់ពីរថ្ងៃទៀត។ ក្រោយមកខ្ញុំក៏បានឮសូរសំឡេងរថយន្ត ពេលខ្ញុំចេញទៅលបមើលក៏ដឹងថាជារថយន្តរបស់ខ្មែរក្រហម។ ខ្ញុំអង្គុយចាំរថយន្តខ្មែរក្រហមត្រឡប់មកវិញ រហូតដល់ថ្ងៃរៀបលិច។ ខ្ញុំបានជិះរថយន្តនោះត្រឡប់មកដល់កងពលកាំភ្លើងធំវិញ។ ក្រោយមក កងទ័ពវៀតណាមបានវាយបណ្ដេញយោធាខ្មែរក្រហមរហូតមកដល់ជើងភ្នំដងរែកក្នុងតំបន់អន្លង់វែង។


ដើមឈើ និងវាលស្មៅព្រៃ នៅក្នុងព្រៃ

ខ្ញុំបានរៀបការនៅក្នុងឆ្នាំ១៩៨៣។ មួយឆ្នាំក្រោយមក ខ្ញុំមានកូនម្នាក់ ប៉ុន្តែខ្ញុំមិនបានរស់នៅជុំគ្នាជាមួយប្រពន្ធកូនទេ។ នៅឆ្នាំ១៨៨៧ ប្រធានកងពលបានចាត់តាំងខ្ញុំដឹកជញ្ជូនគ្រាប់ទៅខេត្តសៀមរាប។ ពេលត្រឡប់មកវិញ ខ្ញុំក៏បានជាន់មីនខ្យល់ ដែលកងទ័ពវៀតណាមដាក់បង្កប់នៅម្តុំអូរស្មាច់ បណ្តាលឲ្យផ្ទុះដាច់ជើងម្ខាង។ ដោយសារខ្ញុំពិការជើងម្ខាង



សហគមន៍សង្ឃរុក្ខវ័ន ខេត្តឧត្តរមានជ័យ

តាម៉ុក ចាត់តាំងខ្ញុំឲ្យទៅបិតចម្រូងលើនៅលើភ្នំ ជាមួយយោធាខ្មែរក្រហមដែលពិការជាច្រើនរូបទៀត។ ក្រៅពីបិតចម្រូង តាម៉ុក បានប្រើខ្ញុំឲ្យដើរដោតចម្រូងការពារការរុលចូលមកពីសំណាក់កងទ័ពវៀតណាម រហូតដល់អូរសំរោង។ ខ្ញុំទទួលបានការផ្គត់ផ្គង់របបអង្ករ អំបិល ប្រហុក ត្រី សាច់ផ្សេងៗពីឃ្លាំងរបស់ តាម៉ុក។

នៅឆ្នាំ១៩៨៩ ពេលកងទ័ពវៀតណាមបានដកចេញទៅវិញ យោធាខ្មែរក្រហមបានវាយរំដោះទឹកដីពីកងទ័ពរដ្ឋកម្ពុជាមកវិញខ្លះ។ បន្ទាប់មក យោធាខ្មែរក្រហមក៏បានចុះពីលើភ្នំដងរែកមករស់នៅខាងក្រោមវិញ។ កងពលលេខ៧៨៥ របស់ខ្ញុំបានចុះមកដល់ក្រោមមុនកងពលផ្សេងទៀត ហើយក៏បានសង់ផ្ទះរស់នៅម្តុំមន្ទីរស្រុកអន្លង់វែង។ ពេលនោះទិដ្ឋភាពនៅជើងភ្នំដងរែកនៃតំបន់អន្លង់វែង ស្រស់ស្អាតយ៉ាងខ្លាំង ហើយសម្បូរណ៍ដោយដើមឈើធំៗមានម្លប់ត្រឈឹងត្រឈៃ ជាពិសេសដើមឈើដែលដុះតាមដងអូរមានទំហំរហូតដល់ប៉ុនកង់រទេះដុះតម្រៀបគ្នាណែនណាន់តាន់តាប់។ ចំណែកឯសត្វព្រៃ និងត្រីវិញមាននៅគ្រប់ទីកន្លែងក្នុងតំបន់នេះ។ នៅមន្ទីរស្រុកអន្លង់វែង ក៏សម្បូរទៅដោយសត្វដំរីធំៗដែរ។ គ្រួសារខ្ញុំ និងប្រជាជនដ៏ទៃទៀតរស់នៅដោយពឹងផ្អែកទៅលើប្រភពធនធានធម្មជាតិទាំងនេះ។ ក្រោយមកព្រៃឈើទាំងនេះក៏ចាប់ផ្តើមបាត់បង់បន្តិចម្តងៗដោយសារតែ តាម៉ុក បានលក់ឈើទាំងនេះទៅឲ្យឈ្មួញថៃ។ តាម៉ុកបានហៅឈ្មួញទាំងនោះមកកាប់ឈើដោយផ្ទាល់នៅក្នុងតំបន់អន្លង់វែងនេះតែម្តង ដោយក្នុងមួយថ្ងៃៗមានឡានប្រមាណ៥០ទៅ៦០គ្រឿង បានដឹកឈើរាប់ម៉ឺនគីបទាំងថ្ងៃទាំងយប់នាំចេញទៅប្រទេសថៃ។ ឈើដែលកាប់លក់ទាំងនោះ មានដូចជា បេងថ្នឹក សុក្រំ គគីរ ត្បែង និងឈើទាលជាដើម។ តាម៉ុក បានប្រាប់ពីមូលហេតុដែលគាត់កាប់ឈើលក់គឺ ដើម្បីយកប្រាក់ទៅចិញ្ចឹមកងទ័ព។ នៅឆ្នាំ១៩៩៣ មានការរៀបចំបោះឆ្នោតដោយអ៊ុនតាក់។ ខ្មែរក្រហមបានបដិសេធមិនចូលរួមក្នុងការបោះឆ្នោត ហើយបន្តធ្វើសង្គ្រាមទ័ពព្រៃប្រឆាំងរដ្ឋាភិបាលភ្នំពេញ។ អំឡុងពេលនោះ កងទ័ពរដ្ឋាភិបាលភ្នំពេញបានវាយបណ្តេញកងទ័ពខ្មែរក្រហមឲ្យឡើងទៅលើភ្នំម្តងទៀត។ ខ្ញុំក៏បានរត់ឡើងទៅលើភ្នំជាមួយ តាម៉ុក ដែរ។ រហូតមកដល់ឆ្នាំ១៩៩៩ ទើបខ្ញុំបានចុះមករស់នៅឃុំត្រពាំងប្រាសាទ ស្រុកអន្លង់វែងរហូតមកដល់ពេលបច្ចុប្បន្ននេះ។

***ផាត ចាន់សុនិតា***

# ព្រះសង្ឃជួយជីវិតមនុស្ស សត្វ និងព្រៃឈើ

នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាមានតែរបបខ្មែរក្រហមមួយប៉ុណ្ណោះ ដែលបានលុបបំបាត់មិនឲ្យមានការគោរពបូជាសាសនា។ វត្តអារាមដែលជាទីកន្លែងសម្រាប់ប្រជាជនគោរពបូជា និងជាទីកន្លែងសម្រាប់អប់រំ ផ្តល់ចំណេះវិជ្ជាតាំងពីសម័យដើមមកត្រូវបានប្រែក្លាយទៅជាមន្ទីរឃុំឃាំង កន្លែងចិញ្ចឹមសត្វ និងជាឃ្លាំងសម្រាប់ដាក់ស្បៀងអាហារ ព្រមទាំងសម្ភារផ្សេងៗ។ ព្រះបដិមាទាំងឡាយត្រូវបានខ្មែរក្រហមវាយកម្ទេច និងយកទៅទម្លាក់ចោលក្នុងស្ទឹងឬទន្លេ ដោយខ្មែរក្រហមលើកឡើងនូវពាក្យមួយឃ្លាថា «កម្ទេចព្រះមួយអង្គចំណេញ ស៊ីម៉ង់ត៍មួយបាវ»។ ចំណែកឯ ព្រះសង្ឃត្រូវបានបង្ខំឲ្យទៅធ្វើការនៅតាមការដ្ឋាន និងសហករណ៍នានា។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រះសង្ឃក៏ជាជនរងគ្រោះដូចប្រជាជនទូទៅដែរ ដូចជា បង្ខំឲ្យធ្វើការហួសកម្លាំង និងការបោសសម្អាតដោយការកាប់សម្លាប់។

នៅក្នុងសាលក្រមសំណុំរឿង០០២/០២ មេដឹកនាំខ្មែរក្រហមត្រូវបានចោទប្រកាន់ជុំវិញការពាក់ព័ន្ធនឹងពុទ្ធសាសនិក ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។ ចំពោះការប្រព្រឹត្តលើពុទ្ធសាសនិក ដែលបទចោទទាំងនេះ អង្គជំនុំជម្រះយល់ឃើញថា ព្រះពុទ្ធសាសនាត្រូវបានហាមឃាត់ និមិត្តរូបតំណាងឲ្យព្រះពុទ្ធត្រូវបានបំផ្លិចបំផ្លាញ ហើយវត្តអារាមមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់គោលបំណងសាសនាទៀតទេ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ព្រះសង្ឃជាច្រើនអង្គត្រូវបានខ្មែរក្រហមផ្សឹក។ ថ្វីត្បិតតែភស្តុតាងមិនអនុញ្ញាតឲ្យអង្គជំនុំជម្រះ សន្និដ្ឋានឲ្យបានច្បាស់លាស់អំពីចំនួនព្រះសង្ឃដែលលាចាកសិក្ខាបទសរុបក៏ដោយ ក៏អង្គជំនុំ



ព្រះសង្ឃចូលរួមកម្មវិធីបញ្ចាំងខ្សែភាពយន្ត «ឆ្នាំព្រៃ» នៅសួនច្បារវិមានឯករាជ្យ ក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩

ជម្រះយល់ឃើញថា មានភ័ស្តុតាងអាចឲ្យជឿទុកចិត្តបាន ដែលបង្ហាញថា ព្រះសង្ឃរាប់រយអង្គត្រូវបានខ្មែរក្រហមផ្សឹកនៅតាមឃុំនានា។ ចេតនារើសអើងនៅពីក្រោយដំណើរការនេះ ត្រូវបានបញ្ជាក់ដោយការហៅព្រះសង្ឃថាជា «តេនញ៉ា» ឬជា «ឈ្លើង»សង្គម និងការប្រកាសបដិសេធព្រះពុទ្ធសាសនា ដោយថាជា អបិយជំនឿសុទ្ធសាធ និងថាព្រះពុទ្ធបដិមា «គ្រាន់តែជាស៊ីម៉ង់ត៍ប៉ុណ្ណោះ»។

ក្រោយឆ្នាំ១៩៧៩ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ វត្តអារាមត្រូវបានបង្កើតឲ្យដំណើរការឡើងវិញនៅតាមទីកន្លែងនានាក្នុងប្រទេសកម្ពុជា។ រហូតមកដល់ពេលបច្ចុប្បន្ន ព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមកម្ពុជា។ បច្ចុប្បន្នវត្តអារាមមានចំនួន៤៩៨៥ ជាទីកន្លែងបណ្តុះបណ្តាលធនធានមនុស្ស និងជួយដល់កុមារកំព្រា សិស្ស និស្សិត ដើម្បីស្នាក់នៅរៀនសូត្រ។ ចំណែកឯព្រះសង្ឃវិញ បានចូលរួមចំណែកជាច្រើនក្នុងការអភិវឌ្ឍន៍ផ្នែកស្មារតី និងព្យាបាលផ្លូវចិត្តដែលមនុស្សតែងជួបប្រទះនៅក្នុងជីវភាពរស់នៅ។ ព្រះសង្ឃគឺជាអ្នកអប់រំសីលធម៌ដើម្បីឲ្យមនុស្សរស់នៅដោយសន្តិភាព តាមរយៈការសម្តែងព្រះធម៌នៅតាមវត្តអារាម ទីសាធារណៈ និងកន្លែងរៀបចំពិធីសាសនាផ្សេងៗ។ ព្រះសង្ឃក៏បានចូលរួមក្នុងការងារសង្គមជាច្រើនទៀតដូចជា ធ្វើជាវាគ្មិនផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង និងទប់ស្កាត់ការប្រើប្រាស់អំពើហិង្សានៅក្នុងគ្រួសារ និងនៅក្នុងសង្គម។ ទន្ទឹមនឹងនេះ ព្រះសង្ឃក៏ជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរផងដែរ។ ព្រះសង្ឃជាអ្នកបណ្តុះនូវមេត្តាធម៌ដល់មនុស្សគ្រប់គ្នាឲ្យចេះរស់នៅ ក្នុងសង្គមប្រកបទៅដោយការអន់ខិនអធ្យាស្រ័យ និងគោរពគ្នាទៅវិញទៅមកដើម្បីជៀសផុតនូវជម្លោះ។ ក្រៅពីការសម្តែងធម្មទេសនា ព្រះសង្ឃក៏បានចូលរួមក្នុងកិច្ចការសង្គមជាច្រើនទៀត ដូចជាបរិច្ចាគបច្ច័យជូនដល់មន្ទីរពេទ្យ និងចូលរួមក្នុងការថែរក្សាបរិស្ថាន និងការពារព្រៃឈើជាដើម។

ខាងក្រោមនេះ គឺជាការរៀបរាប់អំពីកិច្ចការផ្សេងៗដែលព្រះសង្ឃបានចូលរួមនៅក្នុងសង្គម៖

១) ឈុំ ធឿន ភេទប្រុស អាយុ៧០ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាសង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យបានមានប្រសាសន៍ថា ព្រះសង្ឃបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេស។ ជាក់ស្តែងព្រះតេជគុណ ប៊ុន សាលួត ដែលបានបង្កើតព្រៃសហគមន៍សង្ឃរុក្ខវ័ននៅក្នុងទឹកដីខេត្តឧត្តរមានជ័យ។ ព្រះអង្គ ប៊ុន សាលួត មានការលះបង់ខ្ពស់ចំពោះកិច្ចការនេះ ដោយព្រះអង្គបានប្រឈមមុខសព្វគ្រប់បែបយ៉ាងជាមួយការងារក្នុងព្រៃ និងឈ្មួញទុច្ចរិត។ ព្រះសង្ឃដែលនៅការពារព្រៃសហគមន៍សង្ឃរុក្ខវ័នបានជីកប្រឡាយព័ទ្ធជុំវិញព្រៃ ដើម្បីការពារកុំឲ្យមានអ្នកចូលកាប់ឈើ និងទន្ទ្រានយកដី។ បើទោះបីជាមានការបង្ក្រាប និងការពារពីព្រះសង្ឃយ៉ាងណាក៏ដោយ ក៏នៅតែមានក្រុមឈ្មួញទុច្ចរិតព្យាយាមលួចចូលកាប់ឈើដែរ។ ប្រសិនបើគ្មានព្រះសង្ឃការពារនោះទេ ព្រៃឈើនៅលើដីប្រមាណ


ឈុំ ធឿន នៅក្នុងកម្មវិធីចាក់បញ្ចាំងខ្សែភាពយន្តរឿង «ឆ្នាំព្រៃ» នៅសួនច្បារវិមានឯករាជ្យ ក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩

ជាង៣ម៉ឺនហិកតានេះ នឹងត្រូវឈ្មួញកាប់បំផ្លាញអស់ជាមិនខានៗ បច្ចុប្បន្នព្រះសង្ឃមិនអនុញ្ញាតឲ្យប្រជាជនចូលព្រៃក្នុងគោលបំណងកាប់ឈើឡើយ ប៉ុន្តែប្រជាជនអាចចូលទៅរកអនុផលព្រៃឈើ ដូចជា ផ្សិតឬសឈើ ថ្នាំខ្មែរ និងរុក្ខជាតិតូចៗសម្រាប់ហូប និងលក់នៅលើទីផ្សារបានៗ នៅពេលដែលមានព្រះសង្ឃការពារព្រៃមិនឲ្យមានការកាប់បំផ្លាញ ប្រជាជននៅតំបន់នេះមានការសប្បាយចិត្តជាខ្លាំងៗ ពីមុនតំបន់អន្លង់វែងនេះសម្បូរទៅដោយព្រៃឈើ និងសត្វគ្រប់ប្រភេទដូចជា ទន្សោង ដំរី ខ្លា ប្រើស រមាំង ខ្ទីង ក្តាន់ និងសត្វផ្សេងៗទៀតៗ ប្រជាជនអាចរស់បានដោយសារអនុផលធនធានធម្មជាតិទាំងនេះៗ ប៉ុន្តែរហូតមកដល់បច្ចុប្បន្នសត្វទាំងនេះស្ទើរតែផុតពូជអស់ទៅហើយ ព្រោះព្រៃឈើដែលជាជម្រកសត្វព្រៃត្រូវបានកាប់បំផ្លាញៗ ដូច្នេះព្រះសង្ឃពិតជាបានចូលរួចចំណែកយ៉ាងសំខាន់ក្នុងការបង្កើតសហគមន៍ការពារព្រៃសង្ឃរុក្ខវ័ននេះឡើង ដើម្បីថែរក្សាប្រភេទដើមឈើផ្សេងៗដែលជិតផុតពូជដូចជា ផ្ចឹក សុក្រំ ធ្នុង បេង គគីទុកឲ្យអ្នកជំនាន់ក្រោយបានស្គាល់និងជួយធ្វើឲ្យជីវភាពរបស់ប្រជាជននៅក្នុងសហគមន៍បានប្រសើរឡើងៗ

២) ព្រះតេជគុណ ឃឿន សារ៉ាយ មកពីវត្តប្រាសាទវិជ្ជាសំរោង ក្រុងឧត្តរមានជ័យ បានមានសង្ឃដីការថា បន្ទាប់ពីរៀនចប់នៅសាកលវិទ្យាល័យ អាត្មាគិតថាខ្លួនមានតួនាទីមួយ គឺត្រូវជួយសង្គមតាមរយៈកិច្ចការផ្សេងៗដែលអាចធ្វើបានៗ ពីមុនមកអាត្មាធ្លាប់បានបង្រៀនសិស្សនៅតាមវិទ្យាល័យចំនួនពីរឆ្នាំៗ ក្រោយមកអាត្មាបានមកយាមល្បាតព្រៃសហគម៍សង្ឃរុក្ខវ័ននៅក្នុងខេត្តឧត្តរមានជ័យនេះៗ នៅក្នុងកិច្ចការការពារព្រៃឈើ អាត្មាត្រូវរស់នៅក្នុងព្រៃជាមួយគណៈកម្មការការពារព្រៃឈើផ្សេងទៀត ដោយសង់ទីស្នាក់ការនៅក្នុងព្រៃផ្ទាល់តែម្តងៗ ក្រុមគណៈកម្មការយាមល្បាតព្រៃបានសង់ខ្ទមក្នុងចម្ងាយ ៥គីឡូឃ្លាតពីគ្នាដើម្បីចាំឃ្លាំមើលជនល្មើសដែលមានបំណងចូលបំផ្លាញធនធានធម្មជាតិនៅក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័នៗ ប្រជាជនអាចរស់នៅអាស្រ័យលើអនុផលព្រៃឈើនេះបានតាមរយៈការរកត្រីដោយបង់សំណាញ់ និងបេះរុក្ខជាតិផ្សេងៗទៀតដែលអាចហូបបាននៅក្នុងព្រៃៗ ប៉ុន្តែចំពោះសកម្មភាពកាប់ព្រៃឈើ ដាក់អន្ទាក់សត្វ និងនេសាទខុសច្បាប់ត្រូវបានហាមឃាត់ៗ នៅក្នុងការងារការពារព្រៃឈើនេះ អាត្មា និងព្រះសង្ឃដែលនៅក្នុងព្រៃផ្សេងទៀតត្រូវប្រឈមមុខនឹងឧបសគ្គជាមួយជនល្មើសដែលមានគំនិតចង់កាប់បំផ្លាញព្រៃៗ ជនល្មើសទាំងនោះមិនពេញចិត្តចំពោះព្រះសង្ឃដែលបានហាមឃាត់មិនឲ្យខ្លួនចូលកាប់ឈើប្រណិត ដាក់អន្ទាក់សត្វព្រៃ និងចូលឆក់ត្រីឡើយៗ ក្រុមប្រព្រឹត្តិបទល្មើសទាំងនេះបានខឹងសម្បារនឹងគុំកួនជាមួយគណៈកម្មការការពារព្រៃឈើដោយបានគំរាមកំហែង និងលួចដុតផ្ទះគណៈកម្មការជាដើមៗ បើទោះបីជាការងារនេះជួបប្រទះនឹងបញ្ហាប្រឈមបែបនេះក្តីក៏អាត្មានៅតែប្តេជ្ញាចិត្តធ្វើកិច្ចការនេះបន្តទៀត ក្នុងគោលបំណងចង់កែប្រែកន្លែងនេះឲ្យក្លាយទៅជាតំបន់ប្រវត្តិសាស្ត្រ និងថែរក្សាធនធានធម្មជាតិទាំងនេះទុកសម្រាប់អ្នកជំនាន់ក្រោយៗ

៣) ព្រះតេជគុណ ព្រឹម ហួន គឺជាព្រះសង្ឃមួយអង្គដែលបានចូលរួមនៅក្នុងការងារការពារព្រៃសហគមន៍សង្ឃរុក្ខវ័នមានសង្ឃដីកាថា អាត្មាបានជួយបង្ក្រាបទៅលើជនល្មើសដែលចូលមកបំផ្លាញធនធានធម្មជាតិ នៅក្នុងព្រៃសហគមន៍នេះៗ ក្រៅពីការងារការពារព្រៃឈើ ព្រះអង្គបានថតរូបរុក្ខជាតិដែលអាចហូប និងប្រើប្រាស់ជាថ្នាំបានព្រមទាំងថតរូបសត្វព្រៃ និងប្រភេទដើមឈើផ្សេងៗទៀតដែលមាននៅក្នុងព្រៃសង្ឃរុក្ខវ័ន ដើម្បីផ្សព្វផ្សាយ និងចងក្រងជាឯកសារទុកឲ្យប្រជាជន និងយុវជនជំនាន់ក្រោយបានស្គាល់ៗ

ព្រះសង្ឃមិនត្រឹមតែមានតួនាទីត្រឹមអប់រំធម៌ និងផ្សព្វផ្សាយសាសនាទៅដល់ពុទ្ធបរិស័ទនៅគ្រប់ទិសទីប៉ុណ្ណោះទេ គឺព្រះសង្ឃក៏មានតួនាទីក្នុងការជួយជីវិតមនុស្ស សត្វ និងព្រៃឈើឲ្យនៅគង់វង្ស និងយូរអង្វែងទៅថ្ងៃខាងមុខដែរៗ

*ផាត ចាន់សុនិតា*

# ចំណាប់អារម្មណ៍អ្នកទស្សនាចំពោះខ្សែភាពយន្តរឿង «ឆ្នាំព្រៃ» នៅក្នុងទីរួមខេត្តតាកែវ

ខ្សែភាពយន្តឯកសាររឿង«ឆ្នាំព្រៃ» កំពុងតែចាក់បញ្ចាំងផ្សាយនៅតាមបណ្តាខេត្តនានានៅក្នុងប្រទេសកម្ពុជា។ ខេត្តតាកែវ គឺជាទីតាំងទីពនៃការបានចាក់បញ្ចាំង ខ្សែភាពយន្តរឿង«ឆ្នាំព្រៃ» បន្ទាប់ពីបានចាក់បញ្ចាំងនៅក្នុងទីក្រុងភ្នំពេញ និងនៅក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ខ្សែភាពយន្តឯកសារនេះ បានទាក់ទាញចំណាប់អារម្មណ៍របស់អ្នកទស្សនាជាច្រើន ជាពិសេស គ្រូបង្រៀន គរុសិស្ស និងថែមទាំងទទួលបានការកោតសរសើរយ៉ាងខ្លាំងចំពោះកេរដំណែលធនធានធម្មជាតិនៅក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័ន អតីតកន្លែងលាក់ខ្លួនរបស់ខ្មែរក្រហម ក្នុងទឹកដីនៃខេត្តឧត្តមានជ័យ ដែលបានអភិរក្សដោយព្រះសង្ឃ។

ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់អ្នកទស្សនាខ្សែភាពយន្តរឿង «ឆ្នាំព្រៃ» ដែលបានចាក់បញ្ចាំងនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ កាលពីចុងខែមិថុនា ឆ្នាំ២០១៩ កន្លងទៅនេះ៖



គៀន ឡួយ គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវចូលរួមក្នុងកម្មវិធីបញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ»


សុង លីហ្សា គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវចូលរួមក្នុងកម្មវិធីបញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ»


នាង ចាន់បុរី ជាគ្រូបង្រៀនឯកទេសគណិតវិទ្យានៃវិទ្យាល័យជាស៊ីមតាកែវ ចូលរួមក្នុងកម្មវិធីបញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ»

១) នាង ចាន់បុរី ភេទប្រុស អាយុ៣៥ឆ្នាំ គឺជាគ្រូគណិតវិទ្យានៃវិទ្យាល័យជាស៊ីមតាកែវ បានរៀបរាប់ថា៖

ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ នៅពេលដែលបានទស្សនាខ្សែភាពយន្ត«ឆ្នាំព្រៃ» នេះ។ ខ្ញុំមិននឹកស្មានថា នៅក្នុងប្រទេសកម្ពុជា នៅមានសេសសល់ព្រៃឈើជាច្រើនដូចច្នេះទេ។ ខ្ញុំនឹងរៀបគម្រោងដើម្បីចុះទៅទស្សនាព្រៃសហគមន៍សង្ឃរុក្ខវ័នផ្ទាល់តែម្តង និងប្រសិនបើមានឱកាសអាចជួយព្រះសង្ឃបាន ខ្ញុំនឹងជួយទៅតាមលទ្ធភាពរបស់ខ្ញុំ។ ខ្ញុំអាចជួយផ្សព្វផ្សាយព័ត៌មាន និងអប់រំផ្នត់គំនិតសិស្សនៅតាមសាលារៀនឲ្យចេះស្រឡាញ់ ការពារធនធានធម្មជាតិ ដែលមានព្រះសង្ឃក្នុងខ្សែភាពយន្តនេះជាគំរូ។ ការចាក់បញ្ចាំងខ្សែភាពយន្តនេះ បានផ្តល់នូវកម្លាំងចិត្តឲ្យខ្ញុំកាន់តែស្រឡាញ់ព្រៃឈើបន្ទាប់ពីបានទស្សនារួចមក។ សង្ឃដីការបស់តួអង្គ

ព្រះតេជគុណ ប៊ុន សាលួត បានធ្វើឲ្យខ្ញុំចាប់អារម្មណ៍ខ្លាំងណាស់។ ព្រះអង្គពិតជាមានការគិតពិចារណាបានយ៉ាងស៊ីជម្រៅ និងខិតខំប្រឹងប្រែងយ៉ាងខ្លាំងទើបអាចថែរក្សាព្រៃឈើនិងសត្វព្រៃទាំងអស់នេះបាន។ ខ្ញុំសូមស្ងើចសរសើរចំពោះទឹកចិត្តនៃការលះបង់សេចក្តីសុខផ្ទាល់ខ្លួនរបស់ព្រះអង្គចូលទៅរស់នៅក្នុងព្រៃ ដោយបានប្រឈមមុខនឹងគ្រោះថ្នាក់សព្វគ្រប់បែបយ៉ាង ដើម្បីការពារព្រៃឈើសម្រាប់ជាផលប្រយោជន៍រួមរបស់ប្រទេសកម្ពុជា។ ព្រះពុទ្ធទ្រង់បានប្រសូត្រត្រាស់ដឹង និងព្រះនិព្វាននៅក្នុងព្រៃ ហើយព្រះពុទ្ធក៏បានបង្រៀនឲ្យមនុស្សសត្វទាំងអស់រស់នៅជាមួយធម្មជាតិ ប៉ុន្តែនៅតែមានមនុស្សមួយចំនួនមិនយល់អំពីតម្លៃនៃធម្មជាតិឡើយ។ ប្រសិនបើមនុស្សនាំគ្នាបំផ្លាញធម្មជាតិ នោះធម្មជាតិនឹងបំផ្លាញមនុស្សវិញ។ ខ្សែភាពយន្តរឿង «ឆ្នាំព្រៃ» នេះបានចូលរួមចំណែកជាច្រើនសម្រាប់អប់រំបណ្តុះផ្នត់គំនិតមនុស្សឲ្យចេះស្រឡាញ់ធម្មជាតិ។

២) សុង លីហ្សា ភេទស្រី អាយុ១៩ឆ្នាំ គឺជាគរុសិស្សឯកទេសអក្សរសាស្ត្រខ្មែរ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ បានលើកឡើងថា ៖

ខ្សែភាពយន្តរឿង «ឆ្នាំព្រៃ» បានបង្ហាញអំពីសម្រស់ធម្មជាតិដ៏ស្រស់បំព្រង ផ្សារភ្ជាប់ជាមួយនឹងប្រវត្តិសាស្ត្រអតីតកាលដ៏ខ្មៅងងឹតនៃតំបន់អន្លង់វែង ដែលជាតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម។ ខ្សែភាពយន្តនេះ បានអប់រំនិងផ្តល់ជាគំរូដ៏ល្អសម្រាប់ប្រជាជនកម្ពុជា ឲ្យចេះស្វែងយល់អំពីតម្លៃនៃធនធានធម្មជាតិ និងលើកទឹកចិត្តឲ្យចូលរួមថែរក្សាការពារព្រៃឈើ និងសត្វព្រៃឡើងវិញ។ ខ្ញុំគិតថា ថ្នាក់ដឹកនាំ គួរតែចាត់វិធានការបន្ថែមពីលើអ្វីដែលព្រះសង្ឃបានធ្វើ ដើម្បីអភិរក្សធនធានធម្មជាតិ ឲ្យនៅគង់វង្សបានយូរអង្វែង ថែមទាំងអនុវត្តច្បាប់ឲ្យបានតឹងរ៉ឹងចំពោះជនប្រព្រឹត្តបទល្មើសកាប់បំផ្លាញព្រៃឈើ និងសត្វព្រៃ។

៣) គៀន ឡូយ ភេទប្រុស អាយុ២០ឆ្នាំ គឺជាគរុសិស្ស



គរុសិស្សចូលរួមទស្សនាការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ។

*នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ បានចែករំលែកថា៖*

*ខ្សែភាពយន្ត «ឆ្នាំព្រៃ» ពិតជាមានគុណតម្លៃណាស់ក្នុងការដាស់តឿនក្រើនរំឭកយុវជន ក៏ដូចជាប្រជាជនកម្ពុជាឲ្យចេះស្រឡាញ់ និងការពារធនធានធម្មជាតិ។ តាមរយៈសកម្មភាពនៃការតស៊ូរបស់ព្រះតេជគុណ ប៊ុន សាលួត បានផ្តល់ជាគំរូសម្រាប់ប្រជាជនគ្រប់រូបឲ្យមានស្មារតីថែរក្សាសម្បត្តិធម្មជាតិ។ ប្រសិនបើមនុស្សគ្រប់គ្នា មានទឹកចិត្តស្រឡាញ់ព្រៃឈើដូចព្រះសង្ឃ នោះនឹងធ្វើឲ្យសង្គមជាតិមានការរីកចម្រើនឆ្ពោះទៅមុខ។*

*៤) តក់ សុផា ភេទប្រុស អាយុ៥៧ឆ្នាំ គឺជាប្រជាជនរស់នៅក្រុងដូនកែវ ខេត្តតាកែវបានមានប្រសាសន៍ថា ៖*

*ខ្សែភាពយន្តរឿង «ឆ្នាំព្រៃ» បានធ្វើឲ្យខ្ញុំស្រមៃទៅដល់ទិដ្ឋភាពនៅតំបន់ព្រំដែនដែលសម្បូរដោយធនធានធម្មជាតិគ្រប់បែបយ៉ាង ដើមឈើធំៗ និងសត្វព្រៃជាច្រើន។ ខ្ញុំសប្បាយចិត្តណាស់ដែលមានព្រះសង្ឃថែរក្សាធនធានធម្មជាតិទាំងអស់នោះឲ្យនៅគង់វង្ស។*



*ខ្សែភាពយន្តរឿង «ឆ្នាំព្រៃ» បានរំឭកខ្ញុំពីជីវិតរស់នៅក្នុងព្រៃអំឡុងពេលធ្វើសង្គ្រាមនៅតាមព្រំដែន។ ខ្ញុំមានស្រុកកំណើតរស់នៅស្រុកកោះធំ ខេត្តកណ្តាល។ អំឡុងពេលដែលខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅតាមសហករណ៍ ដោយធ្វើការលើកទំនប់នៅស្រុកកោះធំ។ នាថ្ងៃមួយ ពាក់កណ្តាលឆ្នាំ១៩៧៧ អ្នកនៅធ្វើការការដ្ឋានជាមួយខ្ញុំបានឲ្យដូង១ផ្លែមកខ្ញុំ។ កងឈ្លប បានឃើញ ហើយក៏ចោទខ្ញុំថាលួចទ្រព្យសម្បត្តិរបស់អង្គការ។ ខ្ញុំត្រូវបានខ្មែរក្រហមចាប់យកទៅដាក់គុកនៅមន្ទីរឃុំឃាំងពោធិ៍ទន្លេ ក្នុងស្រុកកោះធំ។ អំឡុងពេលរស់នៅក្នុងគុក ខ្ញុំត្រូវធ្វើការគ្មានពេលសម្រាកដោយទទួលបានបបររាវតែមួយវែកប៉ុណ្ណោះក្នុងមួយថ្ងៃ។ មកដល់ពាក់កណ្តាលអធ្រាត្រថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមវាយចូលមកក្នុងប្រទេសកម្ពុជា ទើបខ្ញុំបានរួចចេញពីគុកនោះ។ បន្ទាប់មកខ្ញុំក៏បានស្ម័គ្រចិត្តចូលធ្វើកងទ័ពជាមួយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីវាយផ្តួលរំលំខ្មែរក្រហមដែលនៅសេសសល់នៅតាមព្រំដែន។ អំឡុងពេលនោះ ខ្ញុំត្រូវរស់នៅក្នុងព្រៃតាមព្រំដែនថៃ ដែលមានការបង្កប់នូវគ្រាប់មីនជាច្រើន។ យុទ្ធជនធ្វើសង្គ្រាមនៅក្នុងព្រៃភាគច្រើនរងគ្រោះដាច់ជើង ឬស្លាប់ដោយសារជាន់មីន។ នៅឆ្នាំ១៩៨៧ ខ្ញុំបានប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមនៅផ្លូវបំបែកជាប្អូនជាប់ព្រំប្រទល់ជាមួយខេត្តក្រចេះ ស្ទឹងត្រែង រតនៈគិរី និងមណ្ឌលគិរី។ ពេលនោះ ខ្ញុំត្រូវយោធាខ្មែរក្រហមបាញ់ចំក្បាលពីក្រោយ និងមួយកន្លែងទៀតត្រូវចំស្មា។ ខ្ញុំបានរងរបួសធ្ងន់ស្ទើរតែបាត់បង់ជីវិត។ ក្រោយមកនៅឆ្នាំ១៩៩៣ ក៏មានការរៀបចំបោះឆ្នោតដោយអ៊ុនតាក់។ ខ្ញុំបានឈប់ធ្វើជាកងទ័ព ហើយវិលត្រឡប់មកធ្វើការនៅអង្គការប្រាសាក់ ក្នុងខេត្តតាកែវរហូតមកដល់ពេលបច្ចុប្បន្ន។*

***ផាត ចាន់សុនិតា***

# សិស្សានុសិស្សវិទ្យាល័យប្រមោយសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩)

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សានុសិស្សថ្នាក់ទី១២ ចំនួន៧៣នាក់ ប្រុស៣៧នាក់និងស្រី៣៦នាក់ នៅវិទ្យាល័យប្រមោយ។ វិទ្យាល័យប្រមោយ មានទីតាំងស្ថិតនៅក្នុងឃុំប្រមោយស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលជាអតីតតំបន់តស៊ូចុងក្រោយមួយរបស់ខ្មែរក្រហម។ ទីតាំងនៃវិទ្យាល័យប្រមោយនេះ គឺជាកន្លែងសមរភូមិប្រយុទ្ធរវាងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគាំទ្រដោយវៀតណាម និងយោធាខ្មែរក្រហម នៅអំឡុងទសវត្សរ៍ ឆ្នាំ៨០ និងដើមឆ្នាំ៩០។

បើតាមលោក ពឹង សុខា នាយកសាលាវិទ្យាល័យប្រមោយមានប្រសាសន៍ថា វាលវែងគឺជាតំបន់ព្រៃដែលមានដើមឈើធំៗ និងជាកន្លែងសង្គ្រាម។ ក្រោយពីប្រទេសមានសុខសន្តិភាព ប្រជាជនបានចូលមករស់នៅក្នុងតំបន់នេះកាន់តែច្រើន ហើយជីវភាពរបស់អ្នកទាំងនេះក៏បានធូរធាជាបន្តបន្ទាប់។ នៅឆ្នាំ២០០៣ រដ្ឋាភិបាលបានបង្កើតសាលានៅស្រុកវាលវែងដំបូងដោយដាក់ឈ្មោះថា អនុវិទ្យាល័យប្រមោយ។ បន្ទាប់មកនៅឆ្នាំ២០០៧ ក្រសួងអប់រំយុវជន និងកីឡា ក៏បានដំឡើងអនុវិទ្យាល័យប្រមោយ ទៅជាវិទ្យាល័យដោយសារតែចំនួនសិស្សមានការកើនឡើងជាលំដាប់។ រហូតមកដល់បច្ចុប្បន្នវិទ្យាល័យប្រមោយ មានអគារចំនួន២ខ្នងដែលស្មើ១០បន្ទប់ សង់លើផ្ទៃដីទំហំ៩ហិកតា។ សព្វថ្ងៃនេះមានកូនសិស្សចូលរៀនចំនួន៥៩៨នាក់ ក្នុងនោះមានសិស្សស្រី ២៨៧នាក់ និងមានលោកគ្រូអ្នកគ្រូសរុបចំនួន ២៨នាក់ ក្នុងនោះមានស្រី៩នាក់។

មុននឹងចាប់ផ្ដើមបើកវេទិកាថ្នាក់រៀន លោក ពឹង សុខា ក៏មានមតិសំណេះសំណាល និងធ្វើការផ្ដាំផ្ញើដល់សិស្សទាំងអស់ឲ្យខិតខំយកចិត្តទុកដាក់ចំពោះមុខវិជ្ជាប្រវត្តិសាស្ត្រ ដែលអាចមាននៅក្នុងវិញ្ញាសាប្រឡងបាក់ឌុបចំពោះមុខវិជ្ជាប្រវត្តិវិទ្យានៅក្នុងឆ្នាំនេះ។ លោកនាយកក៏បានបញ្ជាក់បន្ថែមទៀតថា សិស្សានុសិស្សត្រូវស្គាល់ពីប្រវត្តិសាស្ត្ររបស់ខ្លួន ទោះបីប្រវត្តិសាស្ត្រនោះល្អ ឬអាក្រក់យ៉ាងណាក៏ដោយ ក៏សិស្សចាំបាច់ត្រូវសិក្សាស្វែងយល់ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចម្រើន និងធ្វើឲ្យជនរងគ្រោះ និងជនដៃដល់មានការយោគយល់ អត់ឱនអធ្យាស្រ័យគ្នាទៅវិញទៅមកដើម្បីឈានទៅរកការផ្សះផ្សា។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបរាប់ពីគោលបំណងនៃការបង្កើតកម្មវិធីនេះឡើង គឺដើម្បីជួយពង្រឹកចំណេះដឹងរបស់សិស្សក្នុងការយល់ដឹងកាន់តែច្បាស់ពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម, ស្វែងយល់បន្ថែមពីអតីតកាលដែលបានកើតឡើង គឺក្នុងគោលបំណងដើម្បីផ្សះផ្សាអត់ឱនអធ្យាស្រ័យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាមិនឲ្យកើតមានឡើងសាជាថ្មីម្ដងទៀតនាពេលអនាគត។

វេទិកាថ្នាក់រៀន បានប្រព្រឹត្តទៅក្នុងរយៈពេលជាង២ម៉ោង គឺចាប់ពីម៉ោង៨ៈ៣០នាទីព្រឹក ដល់ម៉ោង ១១ៈ៣០។ មុនពេលចាប់ផ្ដើមធ្វើបទបង្ហាញពីមេរៀន ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់ឱកាសឲ្យសិស្ស ទី១) បំពេញសំណួរស្ទាបស្ទង់មតិ ទី២) សិស្សឡើងសរសេរនូវអ្វីដែលខ្លួនចង់ដឹង និងបានដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម ទី៣) ទស្សនាការតាំងបញ្ចាំងខ្សែភាពយន្តឯកសារ ស្ដីពីគណៈប្រតិភូរណសិរ្សរំដោះវៀតណាមខាងត្បូង មកទស្សនកិច្ចតំបន់រំដោះ ឆ្នាំ១៩៧៣ និង

ខ្មែរភាពយន្តឯកសារកុមារកម្ពុជា។ បន្ទាប់មក លោក ឡុង ដានី បានធ្វើបទបង្ហាញដោយសង្ខេបអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សានុសិស្សបានសិក្សាស្វែងយល់ ដែលទាក់ទងនឹង៖ ដើមកំណើតនៃរបបខ្មែរក្រហម, ការឡើងកាន់អំណាច, ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រង, ជីវភាពរបស់ប្រជាជននៅតាមតំបន់ និងតាមភូមិភាគនីមួយៗ, ភាពខុសប្លែកគ្នារវាងប្រជាជនចាស់ និងប្រជាជន ១៧ មេសា ដែលរស់នៅតាមស្រុកស្រែចម្ការ និងតាមមូលដ្ឋាន។ លោក ឡុង ដានី បាននិយាយថា ប្រជាជនកម្ពុជាទូទាំងប្រទេសត្រូវបានអង្គការប្រមូលផ្តុំនិងចាត់តាំងឲ្យទៅរស់នៅតាមសហករណ៍។ អង្គការបានបែងចែកកម្លាំងពលកម្មមនុស្សចាស់និងក្មេងឲ្យធ្វើការងារផ្សេងគ្នា ហើយរបបខ្មែរក្រហមក៏បានសម្លាប់ប្រជាជនជាង ១លាននាក់ រួមមាន ៖ ការជម្លៀសប្រជាជនដោយបង្ខំ, ការបង្ខំឲ្យប្រជាជនធ្វើការងារបាក់កម្លាំង, ការមិនផ្តល់អាហារឲ្យប្រជាជនបានហូបចុកគ្រប់គ្រាន់, ការរស់នៅគ្មានអនាម័យ និងការយកប្រជាជនទៅសម្លាប់ចោលដោយមិនមានការជំនុំជម្រះ។ លោក ឡុង ដានី ក៏បានបន្ថែមទៀតថា របបកម្ពុជាប្រជាធិបតេយ្យក៏មានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសផ្សេងៗទៀត ដែលមានស្ថានទូតប្រចាំនៅកម្ពុជាដែរ។

បន្ទាប់ពីធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរួចមក មានសិស្សានុសិស្សបានបញ្ចេញមតិយោបល់របស់ខ្លួនដូចខាងក្រោម ៖



លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង កំពុងបង្រៀនសិស្សពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-១៩៧៩)

១) ហែម រស្មី ភេទស្រី អាយុ១៩ឆ្នាំ ជាសិស្សថ្នាក់ ១២(A) នៃវិទ្យាល័យប្រម៉ោយ សព្វថ្ងៃរស់នៅភូមិក្រពើពីរលើ ឃុំភូមិក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលមានឪពុកម្ដាយជាអតីតកម្មាភិបាលខ្មែរក្រហមបានរត់ភៀសខ្លួនពីខេត្តតាកែវ មកនៅជាយដែនខ្មែរ-ថៃដោយសារតែមានសង្គ្រាមឆ្នាំ១៩៧៩។ រស្មី បានរៀបរាប់ថា ខ្ញុំបានដឹងពួពីឪពុកម្ដាយនិយាយប្រាប់ថា នៅក្នុងរបបខ្មែរក្រហមមិនមានអាហារហូបចុកគ្រប់គ្រាន់ ប្រជាជនត្រូវបង្ខំឲ្យធ្វើការហួសកម្លាំងពិធីរៀបការអង្គការជាអ្នករៀបចំឲ្យ និងមានការសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ។ បន្ទាប់ពីខ្ញុំបានរៀនប្រវត្តិសាស្ត្រស្ដីពីរបបខ្មែរក្រហមពីលោកគ្រូអ្នកគ្រូបង្រៀន តាមកម្មវិធីក្រសួងអប់រំ និងវេទិកាស្ដីពីការបង្រៀនប្រវត្តិសាស្ត្រសម័យខ្មែរក្រហមនៅថ្ងៃនេះ បានធ្វើខ្ញុំបានយល់ច្បាស់បន្ថែមទៀតពីប្រវត្តិសាស្ត្រ និងមានគំនិតចង់ចូលរួមជួយអភិវឌ្ឍន៍ប្រទេសជាតិខ្លួនឯង។

២) សាត ពិសិដ្ឋ ភេទប្រុស អាយុ១៩ឆ្នាំ ជាសិស្សថ្នាក់ទី១២(A) គឺជាអ្នកចំណូលថ្មី មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង ដែលសព្វថ្ងៃរស់នៅភូមិអន្លង់រាប ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ កន្លងមក ខ្ញុំបានរៀនសូត្រពីរបបខ្មែរក្រហមតាមរយៈកម្មវិធីក្រសួងអប់រំ និងធ្លាប់ចូលរួមវេទិកាស្ដីអំពីការយល់ដឹងពីអំពើរបបប្រល័យពូជសាសន៍ ប៉ុល ពត និងបានដឹងបន្ថែមពីឪពុកម្ដាយជីដូនជីតាដែលបានរៀបរាប់ពីទុក្ខលំបាកក្នុងរបបខ្មែរក្រហម។ ប៉ុន្តែឪពុកម្ដាយរបស់ខ្ញុំបានប្រាប់ថា កុំឲ្យមានការរើសអើងចំពោះជាតិសាសន៍ និងសាសនា។ ថ្ងៃនេះខ្ញុំសប្បាយរីករាយខ្លាំងណាស់ដែលបានចូលរួមវេទិកាស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឲ្យខ្ញុំបានយល់ដឹងកាន់តែច្បាស់បន្ថែមទៀតពីរឿងរ៉ាវដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំពិតជាសោកស្ដាយចំពោះប្រជាជនខ្មែរ ដែលជួបប្រទះទុក្ខលំបាកក្នុងរបបខ្មែរក្រហម។

៣) ភូ ស្រីនិត ភេទស្រី រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គម មានស្រុកកំណើតនៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំងនិងបានផ្លាស់មករស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅអំឡុងឆ្នាំ២០០៧ បានរៀបរាប់ថា កន្លងមកខ្ញុំបានដឹងខ្លះពីរបបខ្មែរក្រហមខ្លះៗតាមរយៈឪពុកម្ដាយ តាមរយៈការសិក្សារៀនសូត្រ ក្នុងកម្មវិធីរបស់ក្រសួងអប់រំ និងធ្លាប់បានចូលវេទិកាស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យម្ដងរួចមកហើយ។ នេះគឺជាលើកទីពីរដែលខ្ញុំបានចូលរួមថ្នាក់រៀនប្រវត្តិសាស្ត្រ ហើយថ្នាក់រៀននេះធ្វើឲ្យនាងខ្ញុំបានយល់ច្បាស់មួយកម្រិតបន្ថែមទៀត និងបានដឹងពីផែនការបួនឆ្នាំរបស់ខ្មែរក្រហម ដឹងពីការសម្លាប់របស់ខ្មែរក្រហម និងអាចរិះរកវិធីទប់ស្កាត់កុំឲ្យមានអំពើប្រល័យពូជសាសន៍ម្ដងទៀត។ បើមានវេទិកានេះលើកក្រោយនាង ខ្ញុំចង់ដឹងពីការសួរចម្លើយអ្នកទោសនៅក្នុងគុកទួលស្លែង។

៤) អ៊ិន ចាន់រ៉ា ភេទស្រី រៀនថ្នាក់ទី១២(A) ផ្នែកវិទ្យាសាស្ត្រពិត សព្វថ្ងៃរស់នៅឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ពីមុនមកខ្ញុំដឹងអំពីរបបខ្មែរក្រហមតាមចាស់ៗនិយាយតៗគ្នា និងបន្ទាប់មកខ្ញុំបានរៀនសូត្រពីលោកគ្រូអ្នកគ្រូដែលបានបង្រៀនតាមកម្មវិធីរបស់ក្រសួងអប់រំ។ ខ្ញុំសប្បាយចិត្ត និងមានអារម្មណ៍រីករាយដែលបានចូលរួមក្នុងវេទិកាស្ដីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជា និងបានធ្វើឲ្យខ្ញុំបានយល់ច្រើនពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ នៅពេលដែលខ្ញុំបានមើលខ្សែភាពយន្តឯកសារទាក់ទងនឹងគុកទួលស្លែងរួចមក បានធ្វើឲ្យខ្ញុំបានយល់អំពីទុក្ខវេទនារបស់ប្រជាជនខ្មែរ។ ខ្ញុំគិតថា យើងត្រូវស្វែងយល់ពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ឲ្យបានស៊ីជម្រៅ ដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមកើតមានម្ដងទៀត។ យើងរៀនអំពីប្រវត្តិសាស្ត្រ គឺមិនមែនរៀនដើម្បីការសងសឹកគ្នានោះទេ ប៉ុន្តែយើងរៀនដើម្បីការអត់ឱនឲ្យគ្នា និងរៀនដើម្បីការផ្សះផ្សា។

សុខ វណ្ណៈ

# កងរកខ្លឹមចន្ទន៍ក្រស្នា ជ័ររ៉ុង និង បេះផ្លែក្រវាញ នៅក្នុងរបបខ្មែរក្រហម

ឃុំអូរសោម គឺជាឃុំមួយដែលស្ថិតនៅជួរភ្នំក្រវាញ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ឃុំនេះមានភូមិចំនួន៤ គឺ ភូមិឆាយលូក ភូមិកណ្ដាល ភូមិកៀនជង្រុក និងភូមិអូរសោម និងមានភូមិខ្លះដែលមិនទាន់ទទួលស្គាល់ជាផ្លូវការពីក្រសួងមហាផ្ទៃនៅឡើយទេដូចជាភូមិស្ទឹងតាចាន់និងភូមិអូរក្របីផាប់ ឬភូមិតាឡុះ។ ភូមិទាំងនេះនៅមិនឆ្ងាយប៉ុន្មានពីដែនជម្រកសត្វព្រៃភ្នំសំកុសឡើយ។ ដែនជម្រកសត្វព្រៃភ្នំសំកុស គឺជាតំបន់ដែលមានរុក្ខជាតិកម្រ ជាច្រើនប្រភេទ ជាពិសេសរុក្ខជាតិក្រវាញ ដែលបច្ចុប្បន្នមានផ្ទៃដីអភិរក្សប្រមាណជា៥០៦ ហិចតា។ ភូមិទាំងនេះមានជនជាតិជងរស់នៅច្រើន ហើយភាគច្រើនប្រកបរបរដាំពោត សណ្ដែក ស្រូវ ត្រាវ ដំឡូង ដោយពឹងផ្អែកទៅលើធម្មជាតិ និងអនុផលព្រៃឈើ ដូចជា រកជ័ររ៉ុង បេះផ្លែក្រវាញជាដើម។ ភូមិនេះគឺជាភូមិដែល គ្រី ស៊ុម បានមករស់នៅតាំងពីឆ្នាំ១៩៩១។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានបង្កើតកងស្វែងរកជ័ររ៉ុង រកខ្លឹមចន្ទន៍ក្រស្នា និងបេះផ្លែក្រវាញ នៅក្នុងព្រៃឈើតាមជួរភ្នំក្រវាញ ហើយក្នុងនេះក៏មាន គ្រី ស៊ុម។ គ្រី ស៊ុម ដែលមានអាយុ៧៩ ឆ្នាំបានរៀបរាប់ថា ខ្ញុំគឺជាជនជាតិជងកើតនៅឃុំថ្មបាំង ស្រុកឫស្សីជ្រុំ ខេត្តកោះកុង។ ឪពុកឈ្មោះ ជិន និងម្ដាយឈ្មោះ ហាន់ ប្រកបរបរធ្វើចម្ការ និងមានបងប្អូនបង្កើតចំនួន២នាក់។ ជនជាតិជងបានសាងសង់ខ្ទមតូចៗ តាមបណ្ដោយមាត់ស្ទឹង ដើម្បីរស់នៅ ព្រោះជនជាតិជងគិតថាស្ទឹងគឺជាប្រភពទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។



គ្រី ស៊ុម អង្គុយនៅមុខផ្ទះរបស់គាត់ ស្ថិតនៅក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានចូលទៅក្នុងភូមិរបស់ខ្ញុំ។ ខ្ញុំបានទទួលការអប់រំវគ្គនយោបាយ ដែលមានឈ្មោះ ប៉ូច ជាអ្នកបង្រៀននយោបាយ។ នៅឆ្នាំ១៩៧៥ ប្រជាជនត្រូវបានជម្លៀសចេញពីភូមិឫស្សីជ្រុំទៅស្រុកថ្មបាំង នៅខេត្តកោះកុង។ នៅទីនោះ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនកាប់ឆ្ការព្រៃ ធ្វើស្រែ និងហូបរួមនៅក្នុងសហករណ៍។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការងារនៅក្នុងកងធ្វើស្រែ ដែលមាន

សមាជិកប្រមាណជា២០នាក់ ក្នុងនោះមាន អ្នកភ្ជួររាស់ និងដកស្ទូង។ ទិន្នផលស្រូវដែលទទួលបានច្រើនខ្លាំងណាស់។ ប្រភេទពូជស្រូវដែលបានដាំពេលនោះមាន ៖ ស្រូវនាងអែម, នាងវេង, នាងណយ និងស្រូវអរពូជ ដែលជាស្រូវដែលមានកម្ពស់ត្រឹមទ្រូងដែលជាប្រភេទស្រូវធន់នឹងទឹក។ អាហារនៅពេលនោះ ខ្ញុំហូបបបរដំឡូងមី ដោយចុងភៅកាប់ដំឡូងជាកង់ៗ រួចបបរដំឡូងឲ្យរលួយ។ ខ្ញុំក៏អាចត្រឡប់មកផ្ទះវិញសម្រាកជាមួយប្រពន្ធកូនដែរ។ នៅឆ្នាំ១៩៧៦ ខ្ញុំបានឃើញប្រជាជនថ្មីជម្លៀសមកពីភ្នំពេញ។

នៅអំឡុងឆ្នាំ១៩៧៦-១៩៧៧ ខ្ញុំត្រូវបានចាត់តាំងឲ្យដើររកខ្លឹមច័ន្ទន៍។ កងរបស់ខ្ញុំមានគ្នាចំនួន៧០នាក់ដែលក្នុងនោះមាន២០នាក់ជាកងទ័ព។ ប្រធានកងរបស់ខ្ញុំឈ្មោះ ផា ហើយអនុប្រធានកងឈ្មោះ យ៉ាត។ កងរបស់ខ្ញុំបានរៀបចំអង្ករ និងឆ្នាំងសម្រាប់ដាំបាយហូបនៅក្នុងព្រៃពេលទៅរកខ្លឹមច័ន្ទន៍ក្រឹស្នា។ ចំណែកកងមួយទៀតដែលមានសមាជិក៣ទៅ៤នាក់ ត្រូវបានចាត់តាំងឲ្យទៅនេសាទត្រីដើម្បីយកមកធ្វើម្ហូប ព្រោះកងរកខ្លឹមចន្ទន៍ក្រឹស្នា មិនបាញ់សត្វព្រៃធ្វើជាអាហារនោះទេ។ តំបន់ដែលកងរបស់ខ្ញុំដើររកខ្លឹមចន្ទន៍ក្រឹស្នា គឺនៅម្តុំភូមិជនាប់ ចំណារ និងភ្នំរូងក្អែកដែលស្ថិតនៅស្រុកថ្មបាំង។ នៅពេលនោះកងរបស់ខ្ញុំត្រូវដើររកនិងពិនិត្យមើលដើមច័ន្ទន៍ក្រឹស្នា ហើយបើសង្កេតមើលថាដើមនោះមានខ្លឹមហើយ ខ្ញុំនិងសមាជិកកង ក៏បានកាប់ដើមឈើផ្តួលបន្ទាប់មកកាត់ដើមឈើជាពីរកំណាត់ រួចយកដែកត្បូងមកចាំងយកសាច់ឈើពណ៌សចេញដើម្បីយកខ្លឹមពណ៌ខ្មៅ។ ដើមខ្លឹមចន្ទន៍ក្រឹស្នាដែលដុះលូតលាស់ល្អក្រុមខ្ញុំអាចចាំងយកខ្លឹមបានប្រហែលជាមួយអម្រែក។ ខ្ញុំនិងសមាជិកដើររកខ្លឹមចន្ទន៍ក្រឹស្នានៅក្នុងព្រៃរយៈពេល១ខែ ទើបយើង បានត្រឡប់មកសហករណ៍វិញ ដោយយកខ្លឹមចន្ទន៍ក្រឹស្នាទៅដាក់ក្នុងមន្ទីរស្រុកដែលមានគណៈស្រុកជាអ្នកចាំទទួលយក។ ខ្ញុំបានដឹងថាខ្លឹមចន្ទន៍ក្រឹស្នាត្រូវបាននាំទៅក្រៅដើម្បីធ្វើគ្រឿងក្រអូប។

ក្រោយមក កងរបស់ខ្ញុំត្រូវបានចាត់តាំងឲ្យរកជ័រវ៉ុង ស្ថិតនៅជួរភ្នំក្រវាញ។ កងរបស់ខ្ញុំបានរៀបចំសម្ភារ និងអង្ករសម្រាប់ដាំហូបនៅក្នុងព្រៃ។ នៅពេលឃើញដើមវ៉ុងដែលមានអាយុល្មមអាចចៀរយកជ័របាន គឺកងរបស់ខ្ញុំបានឡើងចៀរដើមវ៉ុងពីលើដល់ក្រោមដែលការចៀរនោះស្រដៀងនឹងការចៀរ និងត្រងយកជ័រពីដើមកៅស៊ូដែរ។ ដើមវ៉ុងដែលធ្លាប់ចៀរយកជ័រម្តងហើយ គឺយើងត្រូវរង់ចាំរហូតដល់រយៈពេលមួយឆ្នាំទើបអាចចៀរយកជ័រម្តងទៀត។ ក្នុងរយៈពេលមួយខែ កងខ្ញុំអាចរកជ័រវ៉ុងបានប្រហែលជាមួយតោន ទើបត្រឡប់ទៅសហករណ៍វិញ។ មុននឹងយកជ័រវ៉ុង ទៅដាក់នៅមន្ទីរ កងរបស់ខ្ញុំបានយកជ័រវ៉ុង ទៅរម្ងាស់រួចហើយធ្វើជាជ័រដុំៗដែលមានទំហំប៉ុនកដើង ឬកដៃ រួចយកទៅដាក់ក្នុងមន្ទីរស្រុក។ ដោយជ័រវ៉ុង មានជាតិរំសេវ ខ្មែរក្រហមបានយកទៅធ្វើជារំសេវ ហើយក៏បាននាំទៅប្រទេសអ៊ីរ៉ាក់ និងប្រទេសអ៊ីរ៉ង់។

មកដល់រដូវក្រវាញទុំ កងខ្ញុំដែលជាកងរកជ័រវ៉ុងក៏ត្រូវបានប្តូរមកបេះផ្លែក្រវាញវិញ។ ផ្លែក្រវាញទុំនៅខែកក្កដា។ ផ្លែក្រវាញមានខ្លិនប្រហើរ និងអាចចម្រាញ់ធ្វើជាប្រេងកូឡា ឬប្រេងខ្យល់សម្រាប់លាបខ្លួន។ ចំណែកប្រជាជនខ្លះបានយកផ្លែក្រវាញមកដាំទឹកផឹកព្រោះអាចព្យាបាលជំងឺគ្រុនក្តៅ និងដកដង្ហើមស្រួល។

ក្រោយពេលរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ខ្ញុំ និងប្រជាជនក្នុងភូមិបានរត់ចូលក្នុងព្រៃ។ ខ្ញុំបានសង់ខ្ទមតូចមួយដើម្បីស្នាក់នៅ និងបានដើរបេះស្លឹកឈើព្រៃ ដឹកដំឡូង និងក្តួចហូប។ ឆ្នាំ១៩៨៤ ខ្ញុំបានរត់ទៅជំរំអូរត្រាវ ក្រោយមកដោយមានការជួយជ្រោមជ្រែងពីកាកបាទក្រហម ខ្ញុំក៏ផ្លាស់ទៅរស់នៅជំរំសាយខុ។ នៅឆ្នាំ១៩៩១ ខ្ញុំក៏បានមករស់នៅឃុំអូរសោម ដោយពេលនោះមានជនជាតិជងរស់នៅទីនេះ សរុបទាំងអស់ប្រមាណ៤០គ្រួសារ។ ខ្ញុំបានកាប់ព្រៃដាំពោត ដាំស្រូវ ត្រាវ ដូចដែលបងប្អូនជនជាតិជងធ្លាប់ធ្វើពីមុនមក។

*ដារ៉ារដ្ឋ មេត្តា*

# រឿងរ៉ាវរំលោភស្ត្រី នៅក្នុងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»

ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺជាការសម្តែងទាក់ទងទៅនឹងជីវិតរស់នៅរបស់ប្រជាពលរដ្ឋខ្មែរនៅក្នុងសម័យខ្មែរក្រហម។ ល្ខោននេះបានឆ្លុះបញ្ចាំងអំពីតថភាពពិតជាក់ស្តែងនៅក្នុងសង្គមកម្ពុជានាសម័យខ្មែរក្រហម ដែលបង្ហាញអំពីទុក្ខវេទនា និងភាពរឹងមាំរបស់ប្រជាជនខ្មែរនៅទូទាំងប្រទេស។ គោលបំណងនៃការសម្តែងសិល្បៈនេះ គឺដើម្បីឲ្យមានការផ្សះផ្សារបួសផ្លូវចិត្តរវាងជនរងគ្រោះ និងជនដៃដល់ ដែលបន្តរស់រានមានជីវិតរហូតមកដល់ពេលបច្ចុប្បន្ន។ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» មាន៨



ភួង ម៉ាលី

ឈុត ហើយនៅក្នុងឈុតនីមួយៗមានរឿងរ៉ាវផ្សេងៗពីគ្នា។

ខាងក្រោមនេះ គឺជាខ្លឹមសារនៃសាច់រឿងនៅក្នុងឈុតទី៦ ដែលរៀបរាប់អំពីដំណើរជីវិតក្មេងស្រីម្នាក់ត្រូវបានយោធាខ្មែរក្រហមចាប់រំលោភ ៖

ដា គឺជាក្មេងស្រីជំទង់ម្នាក់ដែលមានរូបសម្ផស្សស្រស់ស្អាត។ នៅពេលដែលនាងធ្វើដំណើរទៅធ្វើការ ពួកយោធាខ្មែរក្រហមតែងតែតាមសម្លឹងមើលនាងជានិច្ច។ ឪពុកម្តាយរបស់ ដា មានការព្រួយបារម្ភ និងយកចិត្តទុកដាក់ការពារនាងយ៉ាងខ្លាំង។ ពួកគាត់បានយកភក់មកប៉ាតលើផ្ទៃមុខ ដា ដើម្បីបិទបាំងសម្រស់របស់នាង។ នាយប់មួយ ក្នុងខែមីនា ឆ្នាំ១៩៧៦ មានយោធាខ្មែរក្រហម ៣នាក់ បានមកដល់ខ្ទមដែលគ្រួសារ ដា រស់នៅ។ យោធាទាំងនោះ បាននិយាយទៅកាន់ឪពុកម្តាយរបស់ដាថា«អង្គការត្រូវការស្នើដាឲ្យទៅកាប់ពោត»។ ម្តាយរបស់ដាយំខ្ទិបដៃនាងជាប់។ ឪពុកម្តាយរបស់ ដា បានលត់ជង្គង់អង្វរពួកយោធាទាំងនោះឲ្យយកពួកគាត់ទៅជំនួស ដា ប៉ុន្តែយោធាទាំងនោះពុំព្រមឡើយ។ ពួកគេបាននិយាយទៅកាន់ឪពុកម្តាយ ដា ថាអង្គការត្រូវការតែ ដា ម្នាក់ប៉ុណ្ណោះ មិនត្រូវតវ៉ាជាមួយអង្គការនោះទេ អង្គការបញ្ជាឲ្យធ្វើអ្វីយើងត្រូវតែធ្វើតាម។ បន្ទាប់មកពួកយោធាបានចាប់យក ដា ទៅក្នុងព្រៃ។ ដា បានងាកក្រោយសម្លឹងមើលមកឪពុកម្តាយរបស់ខ្លួនរហូតផុតកន្ទុយភ្នែក។ នៅក្នុងរាត្រីនោះ ឪពុកម្តាយដាយំសោកដូចអកព្រាត់កូន។ ព្រឹកព្រលឹមឡើង យោធាទាំងនោះបានបញ្ជូន ដា ឲ្យមកជួបឪពុកម្តាយនាងវិញ។ ប៉ុន្តែ ដា មិនមែនជា ដា ដូចកាលពីមុនទៀតឡើយ មុខនាងហើម ស្មាធ្លាក់ចុះ ដៃទាំងទ្វេសំយុងហាក់គ្មានជីវិត នាងបាត់បង់នូវភាពញញឹម និងរស់រាយរាក់ទាក់ដែលធ្លាប់មានកន្លងមក។ ចាប់តាំងពីពេលនោះមក ដា ឈប់និយាយស្តីជារៀងរហូត។ នាង ដោះដំហ៊ានដើរដូចជាមនុស្សគ្មានវិញ្ញាណ

ហើយតែងតែឱនមុខចុះគ្រប់ពេល។ គ្មាននណាម្នាក់និយាយ ឬមកជិត ជា ឡើយ។ មនុស្សម្នាតែងតែនាំគ្នាគេចមុខចេញ នៅពេលដែលនាងដើរកាត់។

ខាងក្រោមនេះគឺជាទស្សនៈ និងការយល់ឃើញរបស់ប្រជាពលរដ្ឋខ្មែរទៅលើឈុតទី៦ បន្ទាប់ពីបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» រួចមក ៖

១) អ្នកម៉ាលី ភេទស្រី អាយុ៧៨ឆ្នាំ បច្ចុប្បន្នជាអនុប្រធានភូមិទី៣ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម បានមានប្រសាសន៍ថា នៅក្នុងសម័យខ្មែរក្រហមប្រជាជនរស់នៅប្រកបទៅដោយការភ័យខ្លាចសព្វគ្រប់បែបយ៉ាង។ ក្រៅពីការបង្ខំឲ្យធ្វើការហួសកម្លាំង និងការបង្អត់អាហារ ប្រជាជនខ្មែរត្រូវបានខ្មែរក្រហមកាប់សម្លាប់យ៉ាងរង្គាល។ ក្នុងរបបនេះបានហាមផ្តាច់មិនឲ្យមានការលួចទាក់ទងគ្នារវាងមនុស្សប្រុស និងមនុស្សស្រី ព្រោះអង្គការខ្មែរក្រហមចាត់ទុកថាជាការប្រព្រឹត្តខុសសីលធម៌ដែលអាចមានទោសកំហុសដល់ស្លាប់។ ថ្វីត្បិតតែមានការហាមឃាត់បែបនេះមែន ក៏នៅមានកម្មាភិបាលយោធាខ្មែរក្រហមដែលមិនបានគោរពទៅតាមគោលការណ៍នេះឡើយ។ កងឈ្លប យោធា ឬឆ្មាំគុកខ្មែរក្រហមខ្លះ បានរំលោភអ្នកទោសស្ត្រី បន្ទាប់មកទើបសម្លាប់ស្ត្រីរងគ្រោះនោះ។ ស្ត្រីដែលមានរូបសម្រស់ស្រស់ស្អាតមួយចំនួន ក៏ត្រូវបានយោធាខ្មែរក្រហមចាប់រំលោភ ប៉ុន្តែស្ត្រីរងគ្រោះនោះមិនហ៊ាននិយាយ ព្រោះខ្លាចការគំរាមកំហែង និងការសម្លាប់។ សម្រាប់ខ្លួនខ្ញុំផ្ទាល់មានការភិតភ័យគ្រប់ពេល ដោយសារតែកម្មាភិបាលខ្មែរក្រហមតែងតែបង្ខំខ្ញុំឲ្យរៀបការជាមួយយោធាខ្មែរក្រហមដែលជាជនពិការ។ ជារៀងរាល់យប់តែងតែមានកងឈ្លបដើរយាមល្បាត និងចាប់



គរុសិស្សនៅខេត្តកំពង់ចាមរង់ចាំទស្សនាការសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់»

ខ្លួនប្រជាជនយកទៅសម្លាប់។ ខ្ញុំបន់ឲ្យតែមេឃឆាប់ភ្លឺ ដើម្បីបានឃើញពន្លឺព្រះអាទិត្យរះ។ នៅវេលាម៉ោង៧ យប់មួយក្នុងឆ្នាំ១៩៧៧ កងឈ្លបបានមកចាប់ដល់ខ្ទមដែលគ្រួសារខ្ញុំរស់នៅ និងបានចាប់ខ្លួនខ្ញុំ។ ខ្ញុំបានសុំម្តាយស្លៀកសម្លៀកបំពាក់ថ្មី ហើយបាននិយាយពាក្យផ្តែផ្តាំ និងលាគាត់ជាលើកចុងក្រោយ ព្រោះខ្ញុំគិតថាមិនអាចមានជីវិតមកជួបគាត់ទៀតទេ។ កងឈ្លបបាននាំខ្ញុំទៅជួបនឹងប្រធានរបស់គេ ប្រធានកងឈ្លបនោះបានសួរអំពីប្រវត្តិសាវតាររបស់ខ្ញុំ។ បន្ទាប់ពីសាកសួររួចទើបគាត់ដឹងថា ខ្ញុំត្រូវជាប្អូនថ្លៃរបស់គាត់ ដូច្នេះហើយខ្ញុំក៏ត្រូវបានដោះលែងឲ្យត្រឡប់មកធ្វើការធម្មតាវិញ។ ប្អូនប្រុសបង្កើតរបស់ខ្ញុំម្នាក់ ក៏ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ នៅក្នុងអំឡុងឆ្នាំ១៩៧៧ ដោយសារតែប្អូនខ្ញុំ គឺជាអតីតទាហ៊ាន លន់ នល់។

២) រិន ផល្លា ភេទស្រី អាយុ២៣ឆ្នាំ គឺជាគរុសិស្សឆ្នាំទី១ ឯកទេសប្រវត្តិភូមិ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម បានរៀបរាប់ថា ៖ ខ្ញុំពិតជាមានអារម្មណ៍តក់ស្លុតណាស់ ក្រោយពីបានទស្សនា «ល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់» ដែលបង្ហាញអំពីសោកនាដកម្មកើតឡើងចំពោះប្រជាជនខ្មែរនៅក្នុងអំឡុងសម័យកាលនោះ។ បើទោះបីជាខ្ញុំមិនបានរស់នៅក្នុងសម័យកាលនោះពិតមែន ប៉ុន្តែនៅពេលទស្សនាសាច់រឿងនេះ ធ្វើឲ្យខ្ញុំនឹកស្រមៃដល់ជីវិតប្រជាជនខ្មែរទូទាំងប្រទេសដែលត្រូវទទួលរងគ្រោះដោយសាររបបដ៏ខ្មៅងងឹតនេះ។ ជាក់ស្តែងនៅក្នុងឈុតទី៦ ដែលនិយាយអំពីជីវិតក្មេងស្រីម្នាក់ដែលត្រូវបានកម្មាភិបាលខ្មែរក្រហមមកចាប់ខ្លួនដល់ផ្ទះយកទៅរំលោភ ដោយកម្មាភិបាលនោះគ្រាន់តែប្រើពាក្យ «អង្គការ» ស្មើទៅកាច់ពោត។

សាច់រឿងនេះបានឆ្លុះបញ្ចាំង អំពីអំណាចយ៉ាងទូលំទូលាយនៃពាក្យ «អង្គការ» ដែលកម្មាភិបាលយោធាខ្មែរក្រហមតែងតែប្រើក្នុងការបញ្ជាឲ្យចាប់ខ្លួន ឬសម្លាប់ប្រជាជនខ្មែរណាម្នាក់។ សម្រាប់រូបខ្ញុំផ្ទាល់ប្រសិនបើជួបប្រទះហេតុការណ៍ដូចតួអង្គ ជា ខ្ញុំក៏មិននិយាយស្តីដែរ។ ខ្ញុំនឹងក្លាយទៅជាក្មេងស្រីម្នាក់ដែលបាក់ទឹកចិត្ត បាត់បង់ទំនាក់ទំនងក្នុងសង្គម មិនចង់មានជីវិតរស់នៅតទៅទៀត ដោយសារតែទទួលរងនូវការរើសអើងពីសំណាក់មនុស្សនៅជុំវិញខ្លួន។ ខ្ញុំយល់ថានៅក្នុងសង្គមខ្មែរមិនឲ្យតម្លៃ និងមានការរើសអើងចំពោះស្ត្រីភេទ ដែលបាត់បង់ព្រហ្មចារីដោយមិនបានរៀបការ។ សូម្បីតែតួអង្គ ជា នៅក្នុងល្ខោននិយាយដែលជាជនរងគ្រោះ បន្ទាប់ពីនាងត្រូវបាន យោធាខ្មែរក្រហមចាប់រំលោភ ក៏អ្នកជិតខាងរបស់នាងមិនបានជួយលើកទឹកចិត្តនាង ហើយថែមទាំងមានការស្អប់ខ្ពើម និងរើសអើងចំពោះរូបនាងថែមទៀត។

៣) ឈិន សុខណា អាយុ២៥ឆ្នាំ ជាគរុសិស្សឆ្នាំទី១ ឯកទេសភាសាខ្មែរ-អង់គ្លេស នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម បានរៀបរាប់ថា៖ ល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» បានផ្តល់ចំណេះដឹងឲ្យខ្ញុំដែលជាមនុស្សជំនាន់ក្រោយបានស្វែងយល់អំពីរឿងរ៉ាវសោកនាដកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ខ្លឹមសារល្ខោននិយាយបានឆ្លុះបញ្ចាំងឲ្យឃើញអំពីភាពអមនុស្សធម៌រវាងជនជាតិខ្មែរដែលបានធ្វើការកាប់សម្លាប់គ្នាឯងយ៉ាងរង្គាល។ តួអង្គ ជា នៅក្នុងរឿងដែលត្រូវបានយោធាខ្មែរក្រហមចាប់រំលោភយ៉ាងព្រៃផ្សៃ និងពុំមានអ្នកទទួលខុសត្រូវ។ ប្រសិនបើករណីបែបនេះកើតឡើងចំពោះរូបខ្ញុំវិញ ខ្ញុំប្រាកដជាជួបប្រទះបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ ដោយសារភាពអាម៉ាស និងការរើសអើងរបស់អ្នកជិតខាងដែលរស់នៅក្នុងសង្គមជាមួយគ្នា។ តាមរយៈការសម្តែងឈុតទី៦នេះក៏បានផ្តល់តម្លៃអប់រំដល់អ្នកទស្សនាឲ្យចេះជួយរំលែកទុក្ខមនុស្សនៅជុំវិញខ្លួន ដោយមិនបោះបង់គ្នាចោលពេលមានបញ្ហា។ ឧទាហរណ៍ដូចអ្នកជិតខាងរបស់តួអង្គ ជា ដែលបានទុកនាងឲ្យរស់នៅឯកោអំឡុងពេលនាងជួបប្រទះនឹងបញ្ហា។ ក្រោយមកទៀត អ្នកទាំងនោះមានភាពសោកស្តាយ ចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តទៅលើតួអង្គ ជា។

**ផាត ចាន់សុនិតា**

# ភូមិក្រពើពីរ

ភូមិក្រពើពីរ ជាភូមិចាស់កើតតាំងពីសម័យអាណានិគមបារាំង។ ភូមិនេះ មិនសូវមានប្រជាជនមករស់នៅច្រើនទេ ដោយសារតែមានព្រៃឈើក្រាស់ និងមានសត្វព្រៃជាច្រើនប្រភេទជាពិសេសហ្វូងសត្វដំរី។ ប្រជាជនរស់នៅភូមិក្រពើពីរកាលពីមុនសម័យសង្គ្រាមពិបាកទៅផ្សារទិញប្រហុកអំបិល ដោយសារតែផ្លូវលំបាក។ បើតាមការនិយាយតៗរបស់អ្នកភូមិ ការដាក់ឈ្មោះ ភូមិក្រពើពីរ ដោយសារកាលដើមឡើយមានអ្នកភូមិជាច្រើនធ្លាប់បានឃើញក្រពើពីរ ក្បាលមានញីមានឈ្មោល រស់នៅក្នុងជ្រោះភ្នំពីរដែលមានសណ្ឋានដូចជារូបក្រពើ។ ក្រពើទាំងពីរក្បាលបានហែលចេញពីជ្រោះភ្នំមកចាប់ត្រីស៊ីក្នុងស្ទឹងជាអាហារ ហើយឡើងដេកលើគោក។ សត្វក្រពើរស់នៅក្នុងភូមិនេះ នៅមានរហូតមកដល់សព្វថ្ងៃនេះ។ ភូមិក្រពើពីរ ស្ថិតនៅក្នុងឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ បើយើងធ្វើដំណើរចេញពីរង្វង់មូលប្រម៉ោយតាមផ្លូវលំក្រាលគ្រួសក្រហមលាយជាមួយដុំថ្មតូចៗ និងឆ្លងកាត់អូរ កាត់ព្រៃដ៏ស្រស់ស្អាត និងកាត់ភ្នំជាច្រើន ក្នុងចម្ងាយប្រហែលជា៤០គីឡូម៉ែត្រ ទើបទៅដល់ភូមិក្រពើពីរ។

នៅក្នុងរដូវធ្លាក់ភ្លៀង នៅដើមខែឧសភា ការធ្វើដំណើរដោយជិះរថយន្ត គឺត្រូវចំណាយពេលរហូតដល់ជិតពីរម៉ោង ទើបបានទៅដល់ភូមិនេះ។ ភូមិក្រពើពីរសព្វថ្ងៃត្រូវបានដំឡើងទៅជាឃុំក្រពើពីរ និងមានភូមិចំនួន១០ចំណុះឲ្យឃុំនេះ ក្នុងនោះមានភូមិចំនួនបីជាភូមិដែលមានអនុក្រិត្យជាផ្លូវការដែលចេញពីក្រសួងមហាផ្ទៃ ដូចជាភូមិក្រពើពីរលើ ភូមិក្រពើរពីក្រោម និងភូមិសំឡាញ ចំណែកភូមិចំនួន៧ផ្សេងទៀតមិនទាន់មានអនុក្រិត្យជាផ្លូវការទេ ដូចជា ភូមិក្រសាំងញោ ភូមិអូរតាទិន ភូមិកុំប៉ង់ ភូមិអូររំចេក ភូមិអូរធំ ភូមិស្នែត និងភូមិបឹងរំលេច។ ភូមិទាំងនេះសព្វថ្ងៃភាគច្រើនមានអតីតកម្មាភិបាលខ្មែរក្រហមចូលមករស់នៅប្រមាណ៧០ភាគរយ ចំណែកប្រជាជនចំណូលថ្មីមានប្រហែលជា ២៥ទៅ៣០ភាគរយប៉ុណ្ណោះ។ ប្រជាជនចាស់ដែលធ្លាប់រស់នៅក្នុងភូមិក្រពើពីរតាំងពីសង្គមចាស់ បានផ្លាស់ទីលំនៅដ្ឋានរបស់គាត់ទៅកន្លែងផ្សេងដោយសារតែសង្គ្រាមស៊ីវិលនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៧០ ហើយអ្នកទាំងនោះមិនបានត្រឡប់មករស់នៅតាមភូមិវិញទេ។ អតីតកម្មាភិបាលខ្មែរក្រហមដែលរស់នៅក្នុងភូមិក្រពើពីរនេះភាគច្រើនមកពីខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។

ទូច ឡេង អតីតកម្មាភិបាលខ្មែរក្រហម អាយុ៦៥ឆ្នាំ មកពីភូមិដើមចាន់ ឃុំរមិញ ស្រុកកោះអណ្តែត ខេត្តតាកែវ បានរៀបរាប់ថា ខ្ញុំបានមករស់នៅភូមិក្រពើពីរក្រោម ដើម្បីប្រកបរបរធ្វើស្រែ និងចម្ការ។



ទូច ឡេង រស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ចាស់ប៉ុណ្ណោះ នៅសាលាអនុវិទ្យាល័យកោះអណ្តែត កាលនៅស្រុកកំណើត ដោយសារកើតមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុ។ នៅពេលនោះ ខ្ញុំមានអាយុ១៦ឆ្នាំ ខ្ញុំបានឮសំឡេងសម្តេច សីហនុ ប្រកាសតាមវិទ្យុពីទីក្រុងប៉េកាំងប្រទេសចិន ឲ្យកូនចៅចូលព្រៃម៉ាគីដើម្បីរំដោះប្រទេសជាតិឲ្យរួចផុតពីការត្រួតត្រារបស់បរទេសជាពិសេសសហរដ្ឋអាមេរិក។ ការប្រកាសនេះ ត្រូវបានផ្សព្វផ្សាយបន្ត និងឮសុះសាយពាសពេញផ្ទៃប្រទេស។ ខ្ញុំគឺជាយុវជនវ័យក្មេងដែលងាយជឿទុកចិត្ត និងចាញ់បោកការឃោសនារបស់អ្នកនយោបាយដោយមិនដឹងខ្លួន។ ការឃោសនាអំពីការតស៊ូដើម្បីប្រទេសជាតិពេលនោះ បានធ្វើឲ្យខ្ញុំ និងយុវជននៅក្នុងភូមិនាំគ្នាស្ម័គ្រចូលបម្រើចលនាខ្មែរក្រហមនៅខែ៩ ឆ្នាំ១៩៧០ ដោយមិនស្ទាក់ស្ទើរឡើយ។ ការឃោសនារបស់ខ្មែរក្រហមឲ្យប្រជាជនចូលរួមជាមួយចលនារបស់ខ្លួន ស្របពេលដែលមានយន្តហោះខាងរដ្ឋាភិបាល លន់ នល់ បានហោះមកទម្លាក់គ្រាប់បែកនៅក្នុងភូមិរបស់ខ្ញុំទាំងយប់ទាំងថ្ងៃ។ ទោះបីការទម្លាក់នោះ មិនបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ប្រជាជននៅតាមស្រុកចម្ការក៏ដោយ ក៏ប្រជាជនមានការបារម្ភ ភ័យខ្លាច និងជួបការលំបាកក្នុងការប្រកបមុខរបរធ្វើស្រែចម្ការដែរ។ ខ្ញុំបានឃើញសកម្មភាពទម្លាក់គ្រាប់នេះដាក់ស្តែងនៅក្នុងភូមិទើបធ្វើឲ្យខ្ញុំមានការឈឺចាប់កាន់តែខ្លាំងឡើង រហូតហ៊ានលះបង់ជីវិតដោយមិនស្តាយស្រណោះឡើយ។

នៅឆ្នាំ១៩៧១ ខ្ញុំបានឡើងមកធ្វើជានីរសារនៅស្រុកកោះអណ្តែត ដែលកាលនោះមាន តាអ៊ិន តាភន តាខឹម ជាគណៈស្រុក។ ការងារនីរសារខ្ញុំគឺនាំយកសំបុត្រពីស្រុកទៅឲ្យថ្នាក់មូលដ្ឋាន និងឃុំជាសម្ងាត់ ព្រោះកន្លែងខ្លះខាងរដ្ឋការ លន់ នល់ នៅគ្រប់គ្រងនៅឡើយ។ មធ្យោបាយរត់



ផ្លូវនៅក្នុងឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់

*សំបុត្ររបស់ខ្ញុំពេលនេះ គឺដើរថ្មើរជើង ហើយនៅពេលប្រញាប់ខ្លាំងខ្ញុំបានជិះកង់។*

*នៅឆ្នាំ១៩៧៣ ខ្ញុំបានមកធ្វើជានីរសារតំបន់១៣ ដោយមានតាសោម គឺជាគណៈតំបន់។ នីរសារតំបន់ គឺមានតួនាទីយកសំបុត្រពីតំបន់ទៅប្រគល់ជូនកងពលនៅសមរភូមិផ្ទាល់។ បន្ទាប់មកទៀត ខ្ញុំបានចូលធ្វើយោធានៅកងពលទី២ ដែលមាន តាប៊ិត តាគិន តារិន ជាប្រធាន។ ពេលនោះ ខ្ញុំនៅក្នុងវរសេនាធំ១៤ ដែលមាន តាសឿន ប្រធាន ចំណុះឲ្យអនុសេនាតូច៣៦០ ដែលមាន តាបឿន ជាអ្នកដឹកនាំ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៤ ខ្ញុំបានចូលសមរភូមិវាយជាមួយកងទ័ព លន់ នល់ នៅតាមបណ្ដោយផ្លូវលេខ២ រហូតដល់ម្តុំព្រៃស។ ពេលនោះខ្ញុំត្រូវរបួសជើង និងត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យកងពល។*

*នៅពេលខ្ញុំបានជាពីស្នាមរបួស នៅឆ្នាំ១៩៧៥ អង្គការបានបញ្ជូនខ្ញុំឲ្យទៅការពារព្រំដែន នៅខាងស្រុកគិរីវង្ស។ ខ្ញុំនៅចាំថា មុនដំបូងយោធាខ្មែរក្រហមនិងកងទ័ពវៀតណាមមានទំនាក់ទំនងល្អ ហើយអង្គភាពយោធាក៏បានចាត់តាំងយោធាខ្មែរក្រហមទាំងអស់ឲ្យធ្វើស្រែ។ ចាប់ពីឆ្នាំ១៩៧៧ សង្គ្រាមបានផ្ទុះឡើងជាមួយប្រទេសវៀតណាម ដោយខ្មែរក្រហមបានជំនួយអាវុធពីប្រទេសចិន។ ខ្ញុំបានចូលប្រយុទ្ធតទល់នឹងកងទ័ពវៀតណាមបានមួយរយៈខ្លី មុខរបួសរបស់ខ្ញុំក៏ចាប់ផ្ដើមរើបឡើងវិញ។ អង្គការបានបញ្ជូនខ្ញុំមកសម្រាកព្យាបាលនៅភ្នំពេញ។*

*ខ្ញុំបានស្នាក់នៅពេទ្យរហូតដល់មានកងទ័ពវៀតណាមវាយចូលដល់ ក្រុងភ្នំពេញ ឆ្នាំ១៩៧៩ ទើបខ្ញុំបានប្រជ្រៀតឡើងជិះរថភ្លើងជាមួយកម្មាភិបាលខ្មែរក្រហម រាប់រយនាក់ទៀតទៅខេត្តបាត់ដំបង។ បន្ទាប់មក ខ្ញុំបានចុះពីរថភ្លើង រួចហើយធ្វើដំណើរចូលទៅក្នុងព្រៃជាមួយមិត្តភក្តិស្គាល់ៗគ្នា រហូតដល់ព្រំដែនខ្មែរថៃ និងបានចេញចូលទឹកដីថៃជាញឹកញាប់។ ក្រោយមក ខ្ញុំបានចូលធ្វើយោធាខ្មែរក្រហមនៅតាមបណ្ដោយព្រំដែនកោះកុង និងថ្មដា ម្ដងទៀត។ ខ្ញុំនៅក្នុងកងពលទី២ ដែលមាន តាវ៉ែន និងតាសេង គឺជាប្រធានកងពល។*

*នៅឆ្នាំ១៩៧៩ យោធាខ្មែរបានប្រមូលផ្ដុំគ្នាជាច្រើនកងពលវាយប្រយុទ្ធតទល់នឹងវត្តមានកងទ័ពវៀតណាម ព្រោះខ្មែរក្រហមចោទថា កងទ័ពវៀតណាមបានឈ្លានពានរំលោភទឹកដីកម្ពុជា។ យោធាខ្មែរក្រហមក៏មានជំនួយពីប្រទេសចិនដែរ។ ខ្មែរក្រហមបានវាយប្រយុទ្ធតទល់នឹងកងទ័ពវៀតណាមរហូតដល់ឆ្នាំ១៩៨៩ ទើបកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជា។ ទោះបីប្រទេសកម្ពុជាលែងមានវត្តមានកងទ័ពវៀតណាម តែសង្គ្រាមរវាងកងទ័ពខ្មែរគ្នាឯងនៅតែបន្ត។*

*នៅឆ្នាំ១៩៩០ ការចរចារវាងខ្មែរ និងខ្មែរដើម្បីបញ្ចប់សង្គ្រាម និងស្វែងសន្តិភាពជូនប្រជាជន ត្រូវបានផ្តួចផ្តើមឡើង រហូតឈានទៅដល់ការបោះឆ្នោតដែលរៀបចំដោយអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ ឬហៅកាត់ថា (អ៊ុនតាក់) នៅឆ្នាំ១៩៩៣។ ពេលនោះគ្រប់ភាគីនយោបាយទាំងអស់បានចូលរួមក្នុងការបោះឆ្នោត លើកលែងតែក្រុមខ្មែរក្រហមបានធ្វើពហិការ។*

*នៅអំឡុងពេលនោះ ខ្ញុំបានផ្លាស់មករស់នៅភូមិក្រពើពីរ ហើយក៏បានឃើញកងកម្លាំងរបស់ អ៊ុនតាក់ ចូលមកតំបន់របស់ខ្ញុំរស់នៅដែរ ប៉ុន្តែខ្ញុំមិនស្គាល់ថាអ្នកទាំងនោះមានជាតិសាសន៍អ្វីខ្លះទេ។ បន្ទាប់មកសង្គ្រាមក៏ចាប់ផ្តើមផ្ទុះឡើងម្តងទៀត ហើយខ្មែរក្រហមក៏ប្រកាសឲ្យយោធាចេញទៅកាន់កងពលរៀងៗខ្លួនវិញ។ នៅពេលនោះ ប្រទេសចិនឈប់ផ្តល់ជំនួយឲ្យខ្មែរក្រហមហើយ ដូច្នេះខ្មែរក្រហមក៏បានចាប់កាប់ឈើហ៊ុបធំៗ លក់ទៅឲ្យឈ្មួញថៃ ដើម្បីយកលុយធ្វើសង្គ្រាមបន្តទៀត។*

*រហូតដល់ឆ្នាំ១៩៩៦ មេកងពលរបស់ខ្មែរក្រហមជាច្រើនបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយតំបន់វាលវែងក៏មានសន្តិភាពចាប់តាំងពីពេលនោះមក។*

*សុខ វណ្ណៈ*

# មនោគមន៍វិជ្ជាខ្មែរក្រហមបានធ្វើឲ្យខ្ញុំលែងគិតពីជីវិតផ្ទាល់ខ្លួន

ខ្ញុំឈ្មោះ ជាម ទ្រឹម អាយុ៦០ឆ្នាំ គឺជាអតីតយោធាខ្មែរក្រហម។ ដោយសារមនោគមន៍វិជ្ជារបស់ខ្មែរក្រហមបានធ្វើឲ្យខ្ញុំដែលចូលរួមជាមួយចលនាតស៊ូនេះ ហាក់លែងគិតពីជីវិតរបស់ខ្លួន ហើយធ្វើយ៉ាងណាត្រូវរំដោះប្រទេសជាតិចេញពីសត្រូវ។ នៅក្នុងបរិបទសង្គមកម្ពុជា ដែលពុំអាចគេចផុតពីសង្គ្រាម បានតម្រូវឲ្យខ្ញុំលះបង់គ្រប់យ៉ាង និងហ៊ានធ្វើពលិកម្មដើម្បីផ្លាស់ប្តូរដោគវាសនាប្រទេសជាតិ ប៉ុន្តែលទ្ធផលដែលទទួលបានមកគឺមិនដូចការគិតរបស់ខ្ញុំឡើយ។

ខ្ញុំកើតនៅភូមិក្បាលកោះ ឃុំកោះប្រែង ស្រុកក្រចេះ ខេត្តក្រចេះ។ នៅដើមឆ្នាំ១៩៧៤ ខ្ញុំបានធ្វើជាយោធាតំបន់របស់ខ្មែរក្រហមនៅក្នុងខេត្តក្រចេះ។ ជីវិតរបស់ខ្ញុំ និងកងទ័ពដទៃទៀតនាពេលនោះ ក៏មិនខុសពីប្រជាជនផ្សេងទៀតដែរ ដោយថ្នាក់លើ បានបញ្ជូនខ្ញុំទៅលើកទំនប់នៅស្រុកសំបូរជាមួយប្រជាជនអស់រយៈពេលជាច្រើនខែ។ ក្រោយមកខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅឈរជើងនៅភាគខាងលិចនៃទីក្រុងភ្នំពេញ ម្តុំទំនប់កប់ស្រូវ និងពោធិ៍ចិនតុង ដើម្បីវាយប្រយុទ្ធតទល់ជាមួយទាហាន លន់ នល់។ ខ្ញុំនិងកងទ័ពដទៃទៀត បានប្រយុទ្ធតទល់ជាមួយទាហាន លន់ នល់ យ៉ាងខ្លាំងក្លារហូតទទួលបានជ័យជម្នះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

បន្ទាប់ពីទទួលបានជ័យជម្នះ ខ្ញុំពិតជាមានការត្រេកអរយ៉ាងខ្លាំង ព្រោះខ្ញុំគិតថា សង្គ្រាមនឹងត្រូវបានបញ្ចប់ ហើយខ្ញុំក៏លែងចង់បន្តធ្វើសង្គ្រាមតទៅទៀតដែរ។ ផ្ទុយទៅវិញការស្រមើស្រមៃរបស់ខ្ញុំត្រូវបានបញ្ចប់ទៅវិញក្នុងរយៈពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះ។ កាលនោះ ជីវិតរបស់ខ្ញុំពិតជាមានការលំបាកខ្លាំងណាស់ ព្រោះខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅធ្វើស្រែនៅស្រុកឧដុង្គ ក្នុងខេត្តកំពង់ស្ពឺ។ មួយរយៈក្រោយមក ខ្ញុំក៏ត្រូវបានថ្នាក់លើចាត់តាំងឲ្យទៅឈរជើងការពារ



ជាម ទ្រី នៅផ្ទះរបស់គាត់ស្ថិតនៅក្នុងអន្លង់វែង ខេត្តឧត្តរមានជ័យ។

ព្រំដែន នៅខេត្តរតនៈគិរី ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ពី សូ សារឿន (០៥) ប្រធានកងពល៨០១។ ខ្ញុំ និងកងទ័ពដទៃទៀត បានឈរជើងនៅសមរភូមិ ដែលគ្របដណ្តប់ដោយព្រៃជុំជិត និងមិនមានទំនាក់ទំនងជាមួយប្រជាជនទេ។ ខ្ញុំនិងកងកម្លាំងដទៃទៀត មិនដែលទទួលបានរបបអាហារហូបចុកគ្រប់គ្រាន់ទេ ហើយក៏មិនមានអំបិល និងគ្រឿងទេសសម្រាប់ហូបដែរអស់រយៈពេលប្រហែលពីរឆ្នាំ។ ដោយភាពស្រេកឃ្លានខ្ញុំបាននាំគ្នាដើររកជីកដំឡូងព្រៃ និងមើមក្តួចដើម្បីហូបបណ្តោះអាសន្ន។ នៅសមរភូមិ ខ្ញុំមានការលំបាកខ្លាំងណាស់ ព្រោះមិនមានប្រជាជនរស់នៅក្បែរ។

នៅដើមឆ្នាំ១៩៧៨ ក៏កើតមានព្រឹត្តិការណ៍ប្រយុទ្ធគ្នារវាងកងពល៨០១ ជាមួយកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម។ នៅអំឡុងពេលនោះ ខ្ញុំក៏បានរងរបួសដាច់ដៃស្តាំដោយសារខ្ទាតអំបែងគ្រាប់ត្រូវពេលកងទ័ពដែលរួមដំណើរជាមួយខ្ញុំបានជាន់មីននៅសមរភូមិ។ ក្រោយពីរងរបួសភ្លាម ខ្ញុំក៏ត្រូវបានកងកម្លាំងនៅសមរភូមិបញ្ជូនមកព្យាបាលនៅពេទ្យអង្គភាពនៅសមរភូមិក្រោយ និងបញ្ជូនបន្តតាមខត្តម្កាគចក្រមកព្យាបាលនៅមន្ទីរពេទ្យ១៧ មេសា ក្នុងទីក្រុងភ្នំពេញ។ ខ្ញុំបានសម្រាកព្យាបាលនៅពេទ្យ១៧ មេសា អស់រយៈពេលបីខែរហូតបានជាសះស្បើយ។ ក្រោយមក ខ្ញុំក៏បានវិលត្រឡប់មកកាន់សមរភូមិក្នុងខេត្តរតនៈគិរីវិញ។ ហេតុការណ៍ប្រយុទ្ធគ្នានៅសមរភូមិខេត្តរតនៈគិរីនៅតែបន្តឥតឈប់ឈរ ហើយកងកម្លាំងនៅក្នុងកងពល៨០១ បានវាយប្រយុទ្ធតទល់យ៉ាងខ្លាំងក្លាជាមួយវៀតណាម។

នៅឆ្នាំ១៩៨២ កងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយទៅលើកងពល៨០១ តាមព្រំដែនកាន់តែខ្លាំងឡើងបណ្តាលឲ្យកងពល៨០១បាក់ទ័ពរត់ខ្ចាត់ខ្ចាយចូលទៅក្នុងព្រៃ។ ពេលនោះខ្ញុំបានធ្វើដំណើរដោយថ្មើរជើង ជាមួយនឹងកងកម្លាំងដែលនៅសេសសល់ ឆ្ពោះទៅកាន់តំបន់ភ្នំ១០០១ ក្នុងខេត្តព្រះវិហារ។ នៅពេលមកដល់ភ្នំ១០០១ ខ្ញុំក៏បានបន្តដំណើរទៅទន្លេរពៅ។ ក្នុងអំឡុងពេលនោះ ខ្ញុំត្រូវបានថ្នាក់លើចាត់តាំងឲ្យមើលការខុសត្រូវ និងមានតួនាទីជាអ្នកបើកស្បៀងអាហារឲ្យប្រជាជន និងកងទ័ពដែលរស់នៅលើភ្នំ១០០១។ ក្រោយមក ទីតាំងដែលខ្ញុំរស់នៅទទួលរងនូវការវាយប្រហារពីកងទ័ពមួយក្រុមដែលដឹកនាំដោយលោក ញឹក ប៊ុនឆៃ និងបានបណ្តាលឲ្យកងកម្លាំងខ្មែរក្រហមប្រមាណជាងដប់នាក់បានស្លាប់បាត់បង់ជីវិត។ ការប្រយុទ្ធតទល់រយៈពេលខ្លីនេះ បានបញ្ចប់បន្ទាប់ពីមានការវាយបកពីសំណាក់កងទ័ពខ្មែរក្រហម។ ខ្ញុំនិងកងទ័ពនៃកងពល៨០១ បានបន្តការរស់នៅលើភ្នំ១០០១ រហូតដល់ឆ្នាំ១៩៩០។

ក្រោយមក ខ្ញុំត្រូវបានខ្មែរក្រហមផ្លាស់ឲ្យទៅឈរជើងនៅតំបន់ភ្នំ១០០៣ ក្នុងទឹកដីស្រុកអន្លង់វែង។ ដំបូង ខ្ញុំ និងយោធា ព្រមទាំងប្រជាជនជាច្រើននាក់បានមករស់នៅក្នុងភូមិទួលសាលា ដែលជាមូលដ្ឋានឈរជើងរបស់កងពល៨០១ចាស់។ ការវាយប្រយុទ្ធគ្នាក៏បានកើតមានឡើងជាបន្តបន្ទាប់នៅក្រោយពេលបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអ៊ុនតាក់។ ពេលនោះ ភូមិទួលសាលា ក៏កើតមានអសន្តិសុខដែលជាហេតុនាំឲ្យខ្ញុំ និងប្រជាជនក្នុងភូមិនេះរត់ភៀសខ្លួនទៅរស់នៅភ្នំ១០០៣ និងជំរំភូណាយ ក្នុងទឹកដីថៃ។

នៅចុងឆ្នាំ១៩៩៨ ខ្ញុំ និងប្រជាជនដែលបានរត់ភៀសខ្លួនត្រូវបានថ្នាក់លើបញ្ជូនឲ្យត្រឡប់ចុះមកក្រោមវិញ ដើម្បីផ្តិតមេដៃធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា។ ក្នុងកំឡុងពេលនោះ ខ្ញុំពិតជាមានការរំភើបខ្លាំងណាស់ និងហាក់បីដូចជាបានកើតម្តងទៀត។ សម្រាប់អតីតយោធា និងកម្មាភិបាលខ្មែរក្រហម ពុំចង់ឲ្យកើតមានសង្គ្រាមទៀតទេ ព្រោះការធ្វើសង្គ្រាមគឺគ្មានអ្នកឈ្នះ ហើយក៏គ្មានអ្នកចាញ់ដែរ។ គោលនយោបាយសមាហរណកម្ម គឺបានបង្ហាញពីការស្នេហាជាតិ និងស្រឡាញ់សន្តិវិធី។

*ស្វួត វិចិត្រ*

# ទីតាំងប្រវត្តិសាស្ត្រ និងហេតុការណ៍រន្ធត់ដែលមិនអាចបំភ្លេចបាន

ខ្ញុំបាទ គឺជាយុវជនដែលបានធំធាត់ឡើងក្នុងទឹកដីនៃស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ស្រុកអន្លង់វែង គឺជាទឹកដីដែលធ្លាប់ទទួលរងនូវភាពខ្ទេចខ្ទាំកាលពីអតីតកាល ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ខ្ញុំធ្លាប់បានឮតាមរយៈឪពុករបស់ខ្ញុំនិយាយប្រាប់ពីរឿងរ៉ាវដ៏ជូរចត់របស់គាត់នៃសម័យខ្មែរក្រហម ជាពិសេស ទាក់ទងនឹងទីតាំងប្រវត្តិសាស្ត្រមួយចំនួននៅក្នុងស្រុកអន្លង់វែង ដូចជា «ឃ្លាំងកណ្ដាល គឺជាទីតាំងមួយក្នុងចំណោមទីតាំងប្រវត្តិសាស្ត្រដទៃទៀត ដែលខ្ញុំបានចងចាំទាំងស្រពេចស្រពិល តាំងពីខ្ញុំនៅវ័យកុមារមកម្ល៉េះ»។ ការចងចាំ គួបផ្សំនឹងការអានសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហម និងសហគមន៍អន្លង់វែង ដែលជាភូមិកំណើតរបស់ខ្ញុំ បានធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់ពីទឹកដីប្រវត្តិសាស្ត្រមួយនេះ និងបានជំរុញទឹកចិត្តខ្ញុំឲ្យធ្វើការសិក្សាស្រាវជ្រាវស្វែងយល់បន្ថែម ឲ្យកាន់តែស៊ីជម្រៅនូវរឿងរ៉ាវប្រវត្តិសាស្ត្រដែលធ្លាប់បានកើតឡើងនៅក្នុងទឹកដីតំបន់អន្លង់វែង។

កាលពីពេលថ្មីៗនេះ ខ្ញុំក៏បានទៅដល់ទីតាំងប្រវត្តិសាស្ត្រ «ឃ្លាំងកណ្ដាល» ដែលស្ថិតនៅក្នុងឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ វាគឺជាឱកាសមួយសម្រាប់ខ្ញុំនិងជាលើកដំបូង ដែលខ្ញុំបានឃើញទិដ្ឋភាពរស់នៅរបស់ប្រជាជននៅក្នុងភូមិឃ្លាំងកណ្ដាលនេះ។ បច្ចុប្បន្ន ពាក្យថា «ឃ្លាំងកណ្ដាល» គឺនៅសល់ត្រឹមតែទីតាំង និងអាងស្តុកទឹកតូចមួយប៉ុណ្ណោះ។ កាលពីមុន«ឃ្លាំងកណ្ដាល» គឺជាឃ្លាំងរបស់ តាម៉ុក សម្រាប់ដាក់សម្ភារប្រើប្រាស់ផ្សេងៗ និងគ្រឿងយុទ្ធភណ្ឌដែលបានដឹកជញ្ជូនមកពីប្រទេសថៃ និងដឹកមកពីតំបន់ផ្សេងៗទៀត។ រាល់សម្ភារទាំងអស់ដែលបានតម្កល់ទុកនៅក្នុងឃ្លាំងកណ្ដាលនេះ គឺសម្រាប់កងទ័ព និង



ទីតាំងការដ្ឋានដឹកជញ្ជូនរបស់តាម៉ុក (ឃ្លាំងកណ្ដាល)

ក្រោមគ្រប់គ្រងរបស់ តាម៉ុក។ ក្រោយមកទៀត «ឃ្លាំងកណ្តាល» ក៏ត្រូវប្រជាជនរុះរើ ក្រោយពេលដែលខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅចុងឆ្នាំ១៩៩៨។ ខ្ញុំពិតជាមានអារម្មណ៍សោកស្តាយយ៉ាងខ្លាំង ចំពោះការបាត់បង់ទីតាំងប្រវត្តិសាស្ត្រ «ឃ្លាំងកណ្តាល» មួយនេះ ដែលប្រៀបបានទៅនឹងការបាត់បង់នូវការចងចាំមួយផ្នែករបស់ប្រជាជនកម្ពុជា។ ប្រជាជនភាគច្រើនដែលរស់នៅក្បែរ «ឃ្លាំងកណ្តាល» គឺជាកសិករពីព្រោះសណ្ឋានដីនៅទីនេះ មានលក្ខណៈអំណោយផលល្អសម្រាប់ការដាំដុះ។ បន្ទាប់ពីខ្ញុំបានមើលទិដ្ឋភាព «ឃ្លាំងកណ្តាល» របស់ តាម៉ុក រួចហើយ ខ្ញុំក៏បានជួបអ៊ំស្រីម្នាក់ដែលកំពុងតែអង្គុយក្រងស្លឹកត្នោតនៅក្រោមដើមកន្ទួត នៅក្បែរផ្ទះឈើតូចល្មមរបស់គាត់។ អ៊ំស្រីបានបង្ហាញនូវទឹកមុខរួសរាយរាក់ទាក់មកកាន់ខ្ញុំ។ ខ្ញុំក៏បានចូលសួរសុខទុក្ខ និងបានណែនាំខ្លួនខ្ញុំទៅកាន់គាត់។ ឆ្លៀតឱកាសនេះដែរ ខ្ញុំក៏បានសាកសួរពីបទពិសោធន៍ជីវិតរបស់គាត់ដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ហើយគាត់បានរៀបរាប់ថា ៖

ខ្ញុំឈ្មោះ ឡាយ ណាត អាយុ៦១ឆ្នាំ មានស្រុកកំណើតនៅឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ មុនខ្មែរក្រហមឡើងកាន់អំណាច គ្រួសាររបស់ខ្ញុំពឹងផ្អែកតែលើរបរធ្វើស្រែចម្ការ។ ខ្ញុំនិងក្រុមគ្រួសារធ្វើស្រែចម្ការ រហូតដល់ខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ទោះបីខ្ញុំបានទទួលដំណឹងពីការរំដោះនេះក៏ដោយ ក៏សភាពការណ៍នៅក្រោយថ្ងៃរំដោះ គឺមិនទាន់មានសភាពធូរស្បើយដែរ។ ប្រជាជនដែលពេញកម្លាំងនៅភូមិមួយចំនួននៅក្នុងស្រុកជើងព្រៃ ត្រូវបានខ្មែរក្រហមដឹកជញ្ជូនយកទៅធ្វើការនៅតាមតំបន់ឆ្ងាយៗជាបន្តបន្ទាប់។ មិនយូរប៉ុន្មាន ខ្ញុំនិងប្រជាជនដែលរស់នៅក្នុងភូមិដំណាក់សង្កែ ក៏ត្រូវបានខ្មែរក្រហមជម្លៀសទៅធ្វើការនៅកងចល័ត ជីកប្រឡាយ និងលើកទំនប់។ ក្រោយមក ខ្ញុំនិងប្រជាជនរាប់រយនាក់ ត្រូវបាន


អតីតផ្ទះ ប៉ុល ពត និង ខៀវ សំផន

ខ្មែរក្រហមចាត់តាំងឲ្យលើកទំនប់ដីធំមួយនៅភូមិស្គន់។ ខ្ញុំបានចំណាយពេលវេលាជាច្រើនខែរស់នៅ និងធ្វើការងារនៅទីនោះ។ ការងាររបស់ខ្ញុំ គឺត្រូវសម្រុកធ្វើនៅរដូវប្រាំង និងឈប់សម្រាកនៅរដូវវស្សា ព្រោះមានទឹកជំនន់។ ការងារដឹកប្រឡាយ និងលើកទំនប់ គឺពិតជាមានការលំបាកខ្លាំងណាស់ ព្រោះពីមុនមកខ្ញុំមិនធ្លាប់ធ្វើការងារទាំងនេះទេ។ មិនត្រឹមតែប៉ុណ្ណោះ ខ្ញុំក៏ត្រូវទទួលរងនូវការស្តីបន្ទោសពីខ្មែរក្រហមជាញឹកញាប់ថែមទៀត ដោយខ្មែរក្រហមបានចោទប្រកាន់ខ្ញុំ និងប្រជាជនដទៃទៀតថា «ធ្វើការលាក់កម្លាំង ធ្វើការងារមិនពេញដៃ មិនពេញជើង»។ ការចោទប្រកាន់របស់ខ្មែរក្រហមនេះ មិនត្រឹមត្រូវទេ ព្រោះប្រជាជនទាំងអស់នៅក្នុងការដ្ឋានខិតខំធ្វើការយ៉ាងស្វិតស្វាញ ធ្វើការទាំងនឿយហត់ និងគ្មានពេលឈប់សម្រាកឡើយ។ ពេលនោះ ខ្ញុំ និងប្រជាជនដទៃទៀតទទួលបានត្រឹមតែបបរប៉ុណ្ណោះ។ ខ្ញុំ បានយកបបរដែលខ្ញុំទទួលបាន យកទៅរម្ងាស់លាយជាមួយប្រហុក ក្រពះជ្រូក និងបន្លែឲ្យបានកាន់តែច្រើន។ ការរម្ងាស់បែបនេះវាធ្វើឲ្យបបរក្លាយជាពណ៌ខ្មៅគួរឲ្យខ្ពើម។ ដោយការស្រេកឃ្លាន ខ្ញុំគ្មានជម្រើសនោះទេ ក្រៅពីហូបបបរបែបនេះដើម្បីឲ្យមានកម្លាំងធ្វើការតទៅទៀត។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើកងពេទ្យ ដើម្បីព្យាបាលអ្នកជំងឺទូទៅនៅតាមការដ្ឋាន សហករណ៍ និងព្យាបាលអ្នកជំងឺតាមភូមិៗ។ ដំណាក់កាលដំបូងខ្ញុំទទួលបានការបណ្តុះបណ្តាលពីគ្រូពេទ្យខ្មែរក្រហមម្នាក់ឈ្មោះ ស្រ៊ុន ក្នុងរយៈពេលមួយដ៏ខ្លី មានដូចជា ៖ ចាក់ថ្នាំលាងរបួស និងចាក់សេរ៉ូមឲ្យអ្នកជំងឺ។ មួយរយៈក្រោយមក ស្រ៊ុន ត្រូវបានខ្មែរក្រហមចាប់ខ្លួន ដោយចោទប្រកាន់ថា «មានទំនាក់ទំនង និងលួចថ្នាំយកទៅឲ្យខ្មាំង»។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានជួបគ្រូពេទ្យ ស្រ៊ុន ទៀតទេ។ ក្រោយមក ខ្ញុំបានបម្រើការងារនៅមន្ទីរពេទ្យមួយស្ថិតនៅក្នុងភូមិស្គន់។ នៅអំឡុងពេលនោះ ប្រជាជនបានគោរពស្រឡាញ់ខ្ញុំយ៉ាងខ្លាំង។ នៅគ្រាមួយ ប្រហែលជាម៉ោង៨ល្ងាចនៅរដូវវស្សា ខ្ញុំបានធ្វើដំណើរដោយថ្មើរជើង ដើម្បីទៅបើកថ្នាំពីមន្ទីរមួយដែលមានទីតាំងឆ្ងាយពីកន្លែងរបស់ខ្ញុំ។ នៅពេលទៅដល់ទីនោះ ខ្ញុំបានអង្គុយរង់ចាំមួយសន្ទុះ ប៉ុន្តែមិនឃើញនរណាធ្វើការទាល់តែសោះ។ ខណៈនេះ ខ្ញុំក៏បានឮចម្រៀងបដិវត្តន៍បន្លឺឡើង ដែលសំឡេងនោះស្ថិតនៅមិនឆ្ងាយពីមន្ទីរដែលខ្ញុំកំពុងរង់ចាំឡើយ។ ខ្ញុំមានការងឿងឆ្ងល់យ៉ាងខ្លាំង រួចហើយខ្ញុំក៏បានដើរចូលទៅក្នុងព្រៃដើម្បីតាមរកទីតាំងដែលចាក់ចម្រៀងនោះ។ លុះពេលខ្ញុំទៅដល់ ខ្ញុំបានប្រទះឃើញមនុស្សជាច្រើន ត្រូវបានខ្មែរក្រហមកំពុងវាយសម្លាប់ ដោយចាស់ៗ ត្រូវបានខ្មែរក្រហមវាយសម្លាប់នឹងត្បូងចប ចំណែកក្មេងៗអាយុត្រឹម៨ទៅ៩ខែ ឬ១ឆ្នាំ ត្រូវបានខ្មែរក្រហមបោកសម្លាប់នឹងគល់ឈើ ដែលទីតាំងសម្លាប់នោះស្ថិតនៅជិតវត្តស្គន់។ បន្ទាប់មកខ្មែរក្រហមបានយកសាកសពដែលខ្លួនសម្លាប់ទៅទម្លាក់ចូលក្នុងអណ្តូងនៅក្បែរនោះ។ ខ្ញុំពិតជាមានការតក់ស្លុតយ៉ាងខ្លាំង ពេលបានឃើញហេតុការណ៍ទាំងនេះ ហើយខ្ញុំក៏បានរត់គេចខ្លួនពីទីនោះយ៉ាងប្រញាប់ប្រញាល់។ ប្រសិនបើខ្ញុំមិនចាកចេញឲ្យទាន់ពេលវេលាទេ ខ្ញុំនឹងជួបប្រទះដោគវាសនាដូចប្រជាជនទាំងនោះជាក់ជាមិនខាន។ លុះពេលមកដល់មន្ទីរពេទ្យរបស់ខ្ញុំ ខ្ញុំបែរជាដេកមិនលក់ ព្រោះអារម្មណ៍របស់ខ្ញុំនៅនឹកឃើញពីសកម្មភាពនៃការសម្លាប់ទាំងនោះ ហើយបានដិតដាម និងលងបន្លាចខ្ញុំរហូតមកដល់បច្ចុប្បន្ន។

រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមត្រូវបានដួលរំលំ។ ពេលនោះ ខ្ញុំពិតជាមានការត្រេកអរយ៉ាងខ្លាំង ព្រោះខ្ញុំយល់ឃើញថា ប្រជាជនមានសិទ្ធិសេរីភាព និងរួចផុតពីការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយខ្ញុំក៏មានឱកាសមកជួបជុំក្រុមគ្រួសាររបស់ខ្ញុំនៅឯស្រុកកំណើតវិញដែរ។ បន្ទាប់ពីខ្មែរក្រហមដួលរលំ ខ្ញុំបានទៅរស់នៅស្រុកកំណើតរហូតដល់ឆ្នាំ២០០១ ទើបខ្ញុំបានសម្រេចចិត្តមករស់នៅក្នុងទឹកដីអន្លង់វែង ខេត្តឧត្តរមានជ័យ តាមរយៈប្អូនប្រុសរបស់ខ្ញុំ ដែលបានមករស់នៅស្រុកអន្លង់វែងមុនខ្ញុំ។ *ស្វួត វិចិត្រ*

# ខ្ញុំហៀបនឹងជាប់ទោសដោយសារក្រមា

សិល្បៈបានផ្តល់ឲ្យអ្នកទស្សនានូវតថភាពសង្គមមួយ មិនតែប៉ុណ្ណោះ ក៏ត្រូវបានប្រើដើម្បីព្យាបាលរបួសផ្លូវចិត្តដែរ។ ទម្រង់សិល្បៈល្ខោននិយាយនេះបានចូលមកក្នុងប្រទេសកម្ពុជារវាងឆ្នាំ១៩៤៨និង១៩៤៥។ តាមរយៈការសម្តែងសិល្បៈបែបថ្មី ដោយបានលើកយករឿងរ៉ាវប្រវត្តិសាស្ត្រពិតរបស់ជនរងគ្រោះគឺជាកាផ្តល់នូវខ្លឹមសារ តម្លៃអប់រំ និងបង្កើតឲ្យមានការត្រិះរិះពិចារណាទៅលើប្រវត្តិសាស្ត្រដ៏ជូរចត់ដែលបានកើតឡើងសម្រាប់ក្មេងជំនាន់ក្រោយ។ ខ្ញុំធ្លាប់បានទស្សនាល្ខោននិយាយដែលមានចំណងជើងថា «ទម្លាយភាពស្ងៀមស្ងាត់»។ ល្ខោននិយាយនេះបានធ្វើឲ្យខ្ញុំដឹងរឿងរ៉ាវរបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់របបដ៏ឃោរឃៅ។ ប្រជាជនកម្ពុជាភាគច្រើនមានភាពបាក់ស្បាត មិនចង់និយាយនិងចែករំលែករឿងរ៉ាវឈឺចាប់របស់ខ្លួនឡើយ។ នៅពេលខ្ញុំទៅទស្សនាល្ខោននិយាយនេះ ខ្ញុំបានជួបអ៊ំស្រីម្នាក់ដែលគ្រួសាររបស់គាត់ត្រូវបានខ្មែរក្រហមចាត់ទុកថាជាប្រជាជនថ្មី។ ដោយសារសេចក្តីចង់ដឹងរបស់ខ្ញុំអំពីរបបខ្មែរក្រហម អ៊ំស្រីបានយល់ព្រមរៀបរាប់អំពីដំណើរជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហមដូចខាងក្រោម៖

ខ្ញុំឈ្មោះ អ៊ុំ សារុន ភេទស្រី អាយុ៥៩ឆ្នាំ។ ខ្ញុំកើតនៅភូមិអូរស្វាយចេក ឃុំបាយរាណ៍ ស្រុកទ្រាំង (កាលពីសង្គមចាស់) ខេត្តតាកែវ ដែលបច្ចុប្បន្នស្ថិតនៅសង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។ ឪពុករបស់ខ្ញុំឈ្មោះ អ៊ុំ សារិន និង ម្តាយឈ្មោះ ប៉ាង សួង។ ខ្ញុំជាកូនទី២នៅក្នុងគ្រួសារដែលមានជីវភាពសមរម្យ។ ឪពុករបស់ខ្ញុំមានមុខរបរជាគ្រូបង្រៀន ចំណែកម្តាយរបស់ខ្ញុំគឺជាមេផ្ទះ។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់១២នាក់។ ក្នុងចំណោមបងប្អូនទាំង១២នាក់របស់ខ្ញុំបានស្លាប់បាត់បង់អាយុជីវិតនៅក្នុងរបបខ្មែរក្រហមចំនួន៣នាក់ ក្នុងនោះមានឈ្មោះ អ៊ុំ សុផល, អ៊ុំ ថាវី និង អ៊ុំ សុភាព។ ប្អូនៗរបស់ខ្ញុំស្លាប់ដោយសារជំងឺហើម និងមិនមានអាហារសម្រាប់បរិភោគគ្រប់គ្រាន់។

ខ្ញុំបានរៀននៅសាលាបឋមសិក្សាអង្គមេត្រីចាប់ពីថ្នាក់ទី១២ដល់ថ្នាក់ទី៧។ បន្ទាប់មកនៅឆ្នាំ១៩៧០ ក៏កើតមានរដ្ឋ



អ៊ុំ សារុន នៅផ្ទះរបស់គាត់ស្ថិតនៅភូមិអូរស្វាយចេក ឃុំបាយរាណ៍ ស្រុកទ្រាំង(កាលពីសង្គមចាស់) ខេត្តតាកែវ ដែលបច្ចុប្បន្នស្ថិតនៅសង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ



ក្រមា

*ប្រហារទម្លាក់សម្តេច នរោត្តម សីហនុ។ គ្រួសាររបស់ខ្ញុំបានផ្លាស់មករស់នៅក្នុងភូមិចក ឃុំបារាយណ៍ ស្រុកទ្រាំង (កាលពីសង្គមចាស់) ខេត្តតាកែវ។ ខ្ញុំនៅតែរៀនបន្តដដែលព្រោះខ្ញុំចូលចិត្តរៀនសូត្រខ្លាំងណាស់ ហើយថែមទាំងមានការជួយជំរុញពីឪពុកខ្ញុំទៀតផង។ សង្គ្រាមចេះតែបន្តកើតមានជាហូរហែដែលបង្ខំចិត្តឲ្យខ្ញុំឈប់រៀននៅត្រឹមថ្នាក់ទី៥។ ខ្ញុំ និងគ្រួសារមិនអាចគេចទៅទីណាបានទេដូច្នេះមានតែរង់ចាំស្ថានការណ៍ដែលនឹងមកដល់នាពេលខាងមុខ។*

*នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាន់កាប់ភូមិរបស់ខ្ញុំ។ គ្រួសាររបស់ខ្ញុំត្រូវបានចាត់ទុកថាជាប្រជាជនថ្មីព្រោះគ្រួសារខ្ញុំមានបងប្អូនជម្លៀសមកពីភ្នំពេញ។ ខ្មែរក្រហមគិតថា គ្រួសារខ្ញុំជាប់ទាក់ទងជាមួយពួកមូលធន។ បន្ទាប់មក គ្រួសារខ្ញុំត្រូវបានជម្លៀសឲ្យរស់នៅខាងលិចវត្តលាយបូរ។ គ្រួសាររបស់ខ្ញុំបានធ្វើការនៅជិតៗភូមិ ហើយអាចត្រឡប់មករស់នៅជុំគ្នាបាន។ ម្តាយខ្ញុំខិតខំធ្វើការខ្លាំងណាស់ទោះបីជាគាត់មានកូនខ្ចីក៏ដោយ។ គាត់គ្មានអាហារហូបដើម្បីមានទឹកដោះសម្រាប់ប្អូនរបស់ខ្ញុំបៅឡើយ។ មិនយូរប៉ុន្មានប្អូនប្រុសរបស់ខ្ញុំឈ្មោះ សុភាព បានស្លាប់ដោយសារគ្មានទឹកដោះបៅ។ ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមស្នើចេញទៅ ព្រោះខ្មែរក្រហមសង្ស័យថាគាត់ជាអតីតគ្រូបង្រៀន។ ខ្ញុំគិតថាឪពុករបស់ខ្ញុំមិនអាចវិលត្រឡប់មកវិញទេ។ សំណាងល្អរយៈពេល១០ថ្ងៃក្រោយមក ខ្ញុំបានឃើញស្នាមញញឹមរបស់ឪពុកខ្ញុំម្តងទៀត។ ខ្ញុំបានលួចសួរឪពុកខ្ញុំថា «តើមិត្តបងហៅពុកទៅធ្វើអ្វី?» ប៉ុន្តែឪពុករបស់ខ្ញុំមិនបានឆ្លើយតបនឹងសំណួររបស់ខ្ញុំទេ។ គាត់តែងតែហាមខ្ញុំនៅពេលដែលខ្ញុំសួរគាត់។ រឿងនេះនៅតែធ្វើឲ្យខ្ញុំឆ្ងល់ទោះបីជារបបខ្មែរក្រហមដួលរលំទៅហើយ។ ខ្ញុំនៅតែព្យាយាមសួរគាត់ ប៉ុន្តែគាត់មិនប្រាប់ខ្ញុំទាល់តែសោះ។ ឪពុករបស់ខ្ញុំបានស្លាប់នៅឆ្នាំ១៩៩០។*

*នៅចុងឆ្នាំ១៩៧៥ គ្រួសារខ្ញុំបានផ្លាស់ទៅរស់នៅភូមិថ្មីមួយទៀត ឈ្មោះភូមិព្រៃរុនស្ថិតនៅឃុំស្រងែ ស្រុកទ្រាំង។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅកងកុមារដើរកាប់ដើមទន្រ្ទានខែត្រ រើសអាចម៍គោ និងធ្វើការងារផ្សេងៗតាមបញ្ជារបស់អង្គការ។ ខ្ញុំក៏បានដឹកប្រឡាយដែរ។ ខ្ញុំបានធ្វើការកងចល័តដែលយប់ត្រង់ណាខ្ញុំត្រូវសម្រាកនៅកន្លែងនោះ។ ខ្ញុំមិនមានកន្ទេលក្រាលដេកទេ គឺមានតែចំបើងក្រាលពីក្រោមប៉ុណ្ណោះ។ ពេលនោះខ្ញុំមានអារម្មណ៍ថាចំបើងជាកន្ទេលយ៉ាងកក់ក្តៅ។ នៅពេលមេឃភ្លៀងខ្ញុំមិនបានសម្រាកទេ។ ខ្ញុំបានក្រោកឡើងអង្គុយសំកុកបញ្ឈរជង្គង់ និងរង់ចាំហូតដល់ភ្លៀងរាំង។ ចំណែកម្តាយឪពុកខ្ញុំបានធ្វើការនៅកងផ្សេងពីខ្ញុំ។ ប្រជាជនកម្ពុជាក្នុងភូមិព្រៃរុនមានការរើសអើងយ៉ាងខ្លាំង ចំពោះប្រជាជនថ្មី។ ខ្ញុំចាំមិនភ្លេចទេចំពោះការមាក់ងាយពីប្រជាជនមូលដ្ឋានដែលនិយាយថា «ជីវិតប្រជាជនថ្មីមិនស្មើនឹងជីវិតសត្វឆ្កែមួយក្បាលផង»។ ពាក្យសម្តីទាំងនេះបានធ្វើឲ្យខ្ញុំមានចិត្តគុំកួនចំពោះប្រជាជនមូលដ្ឋាន។ ថ្ងៃមួយឪពុករបស់ខ្ញុំដើរតាមផ្លូវទៅធ្វើការក៏បានឃើញអ្នកមូលដ្ឋានដែលធ្លាប់ស្គាល់គ្នាដឹកព្រលឹត។ ពេលនោះឪពុកខ្ញុំបានលូកដៃទៅក្តិចព្រលឹតរបស់អ្នកមូលដ្ឋានដែលកំពុងដឹកតាមកង់ ប្រវែងប្រមាណជាពីរថ្នាំងដៃ អ្នកមូលដ្ឋាននោះមាក់ងាយ និងប្រមាថដល់អាយុជីវិតឪពុករបស់ខ្ញុំថែមទៀត។*

*នៅឆ្នាំ១៩៧៧ ភូមិព្រៃរុនគឺមានតែប្រជាជនមូលដ្ឋានរស់នៅប៉ុណ្ណោះ។ គ្រួសារខ្ញុំបានរស់នៅក្នុងភូមិមួយទៀតឈ្មោះភូមិក្រាំង ស្ថិតនៅក្នុងឃុំស្រងែ ស្រុកទ្រាំង។ ប្រជាជនដែលរស់នៅក្នុងភូមិក្រាំងភាគច្រើនជាប្រជាជន១៧មេសា ឬប្រជាជនថ្មី។ ខ្ញុំនៅក្នុងកងចល័តស្រុកទ្រាំង និងត្រូវធ្វើការឆ្ងាយពីផ្ទះ។ ខ្ញុំក៏បានដឹងថាគ្រួសាររបស់ខ្ញុំផ្លាស់មករស់នៅក្នុងភូមិក្រាំងដែរ។ ការងាររបស់ខ្ញុំកាន់តែមានភាពលំបាកថែមទាំងមិនអាចមកជួបឪពុកម្តាយទៀតផង។ ប្អូនប្រុសរបស់ខ្ញុំឈ្មោះ អ៊ុំ ថាវី បានស្លាប់ដោយសារជំងឺ។ មួយខែក្រោយមក ខ្ញុំបានទទួលដំណឹងតាមរយៈបងប្រុសរបស់ខ្ញុំថាគាត់បានជួបម្តាយរបស់ខ្ញុំនៅសហករណ៍។ បងប្រុសរបស់ខ្ញុំបាននិយាយថា ប្អូនប្រុសរបស់ខ្ញុំម្នាក់ទៀតឈ្មោះ អ៊ុំ សុផល បានស្លាប់ដោយសារជំងឺ និងមិនមានអាហារហូបគ្រប់គ្រាន់។*

ចំណែកប្អូនប្រុសរបស់ខ្ញុំម្នាក់ទៀតឈ្មោះ អ៊ុំ ពៅ ត្រូវបាន ម្តាយខ្ញុំយកទៅផ្ញើជាមួយយាយៗនៅសហករណ៍។ នៅពេល ដែលម្តាយរបស់ខ្ញុំមកពីធ្វើការវិញ ទើបគាត់យកប្អូនប្រុស របស់ខ្ញុំត្រឡប់មកផ្ទះវិញ។ ដោយសារការមើលថែមិនបានល្អ និងមិនមានអាហារហូបចុកគ្រប់គ្រាន់បានធ្វើឲ្យប្អូនប្រុស របស់ខ្ញុំមានជំងឺ។

នៅដើមឆ្នាំ១៩៧៨ ខ្ញុំបានទៅលើកទំនប់មួយស្ថិតនៅ ខាងលិចវត្តខ្វែង។ យប់មួយ ប្រធានកងរយម្នាក់បានស្រាយ ក្រមាដែលមានពណ៌សខ្មៅពីករបស់គាត់មកឲ្យខ្ញុំ នៅពេល ដែលគាត់ឃើញខ្ញុំកំពុងដេកខ្សៀន និងគ្មានអ្វីដណ្តប់។ យប់ នោះខ្ញុំបានដេកយ៉ាងកក់ក្តៅខ្លាំងណាស់។ នៅពេលក្រោក ទៅធ្វើការពេលព្រលឹមស្រាងៗ ខ្ញុំត្រូវបានប្រធានកងរបស់ ខ្ញុំឈ្មោះ វឿន និងប្រធានកងរយឈ្មោះសុខ លី ចោទប្រកាន់ខ្ញុំ លួចក្រមារបស់អង្គការ។ ខ្ញុំបានបដិសេដថា ខ្ញុំមិនបានលួចទេ ប៉ុន្តែប្រធានកងរបស់ខ្ញុំនៅតែមិនជឿ។ ប្រធានកងរបស់បាន ហៅខ្ញុំទៅប្រជុំហើយនិយាយថា ក្រមានេះមានតែប្រធានកង រយប៉ុណ្ណោះដែលមានប្រើ។ ខ្ញុំក៏បានលើកឡើងនៅក្នុងអង្គ ប្រជុំថា ខ្ញុំបានក្រមានេះមកពីប្រធានកងរយបានឲ្យមកខ្ញុំ។ ក្រោយមកប្រធានកងរបស់ខ្ញុំឈ្មោះ សុខ លី បានឲ្យនីរសារ របស់ខ្លួនទៅស៊ើបសួរពីប្រធានកងរយឈ្មោះ ផាត និងឈ្មោះ សឿន ដែលបានឲ្យក្រមាមកខ្ញុំ។ នៅពេលដែលដឹងថាខ្ញុំ មិន បានលួចក្រមា ប្រធានរបស់ខ្ញុំឈ្មោះ សុខ លី ក៏បានសុំក្រមា នោះពីខ្ញុំ។ ខ្ញុំបានឲ្យក្រមានោះទៅប្រធានកង ព្រោះខ្ញុំគិតថា ប្រសិនបើខ្ញុំមិនឲ្យទេប្រាកដណាស់ខ្ញុំអាចនឹងយកទៅរៀន សូត្រ។ នៅពេលខ្ញុំត្រឡប់មកធ្វើការវិញ មិត្តផាត និង មិត្តសឿន បានសួរខ្ញុំព្រោះមិនបានឃើញខ្ញុំប្រើក្រមាដែល គាត់ឲ្យ។ ខ្ញុំថាត្រូវបានប្រធានកង យកទៅបាត់ហើយ។ មិត្ត ផាត និង មិត្តសឿន បានទៅយកក្រមារបស់គាត់ពីប្រធាន កងឈ្មោះ សុខ លី វិញ។ មិត្តផាត និង មិត្តសឿន បានយក ក្រមាចាស់របស់គាត់មកឲ្យខ្ញុំប្រើ ហើយបានផ្តាំខ្ញុំថា មិត្ត កុំប្រើក្រមាថ្មីមួយនេះអី ព្រោះអាចមានគ្រោះថ្នាក់។ ខ្ញុំក៏បាន បញ្ចប់ការសន្ទនាជាមួយមិត្តផាត និង មិត្តសឿន ហើយធ្វើ ការបន្តទៀត។ រឿងក្រមាមិនទាន់បញ្ចប់ទេ។ នៅថ្ងៃបន្ទាប់ ប្រធានកងរបស់ខ្ញុំឈ្មោះ សុខ លី បានមករករឿងខ្ញុំថា បាន ទៅប្តឹងមិត្ត សឿន និង ផាត ឲ្យទៅយកក្រមាពីគាត់ ហើយ គំរាមខ្ញុំថែមទៀត។ នៅពេលនោះ កងរបស់ខ្ញុំត្រូវបានបង្ខំឲ្យ ធ្វើការងារយ៉ាងខ្លាំង។ ខ្ញុំធ្វើការរហូតដល់ម៉ោង១២យប់ដោយ ប្រធានកងមិនបានខ្វល់ពីការនឿយហត់របស់ខ្ញុំឡើយ។ ប្រធាន កងខ្វល់តែម្យ៉ាង គឺធ្វើយ៉ាងណាឲ្យសម្រេចទៅតាមផែនការ របស់អង្គការតែប៉ុណ្ណោះ។ កុមារដែលធ្វើការជាមួយខ្ញុំខ្លះដួល សន្លប់ និងស្លាប់នៅកន្លែងតែម្តង ព្រោះមិនបានសម្រាក និង មិនមានអាហារហូបគ្រប់គ្រាន់។ ដោយសារធ្វើការច្រើនម៉ោងជើងរបស់ខ្ញុំស្ពឹកមិនអាចធ្វើចលនាបាន។ ខ្ញុំបានពឹងតាម្នាក់ ឲ្យផ្សំថ្នាំឬសឈើឲ្យខ្ញុំផឹក ទើបស្ថានភាពជំងឺរបស់ខ្ញុំបានធូរ ស្បើយ។

នៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ទៅរកឪពុកម្តាយខ្ញុំ។ យើង បានជួបជុំគ្នា និងរត់ទៅជាមួយគ្នាដោយមិនមានគោលដៅ ច្បាស់លាស់ព្រោះខ្លាចកងទ័ពវៀតណាម។ យើងបានរត់ដល់ ភូមិត្រពាំងអំពិល ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។ យើង បានជួបកងទ័ពវៀតណាមនៅទីនោះ ហើយកងទ័ពវៀតណាម ក៏បានប្រាប់យើងឲ្យត្រឡប់មកភូមិកំណើតវិញ។

គ្រួសារខ្ញុំបានធ្វើដំណើរមកដល់ស្រុកកំណើតជីតាដែល ស្ថិតនៅខាងលិចថ្នល់រទេះភ្លើង។ យើងសម្រាកនៅទីនោះ រយៈពេល៣ថ្ងៃទើបបានត្រឡប់មកផ្ទះ។ នៅឆ្នាំ១៩៨០ ខ្ញុំ បានស្ម័គ្រចិត្តចូលជាសមាជិកក្រុមប្រឹក្សាឃុំ។ ខ្ញុំគិតថាខ្ញុំអាច ចូលរួមស្តារប្រទេសជាតិឡើងវិញតាមរយៈជួយសម្រួលធុរៈ ការងារផ្នែករដ្ឋបាលផ្សេងៗសម្រាប់ប្រជាជន។ រហូតមក ដល់ឆ្នាំ១៩៩៤ ខ្ញុំបានឈប់ធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ។ សព្វថ្ងៃ ខ្ញុំធ្វើស្រែចម្ការ ធ្វើជាចុងភៅក្នុងកម្មវិធីបុណ្យ និងពិធី មង្គលការផ្សេងៗ ប៉ុន្តែខ្ញុំក៏បានឆ្លៀតពេលជួយធ្វើការងារនៅ សាលាឃុំដែរ បើទោះបីជាខ្ញុំបានឈប់សម្រាកពីការងារនេះ ក៏ដោយ។

*ដារ៉ារដ្ឋ មេត្តា*

# សិក្ខាសាលាស្តីអំពី ៖ ប្រវត្តិសាស្ត្រខ្មែរក្រហម និងការផ្សះផ្សាជាតិ សម្រាប់សមាគមមគ្គុទ្ទេសក៏ទេសចរណ៍រាជធានីភ្នំពេញ

មគ្គុទ្ទេសក៏ទេសចរណ៍ គឺជាអ្នកពាំនាំសារដ៏សំខាន់ទៅកាន់មនុស្សជាច្រើនមកពីទីកន្លែងផ្សេងៗគ្នា។ សម្រាប់ប្រទេសកម្ពុជា ដែលជាប្រទេសមួយមានអរិយធម៌ដ៏ចំណាស់ គឺពិតជាត្រូវការបុគ្គលដែលមានសមត្ថភាព ដើម្បីចែករំលែកព័ត៌មានឲ្យបានច្បាស់លាស់អំពី វប្បធម៌ ប្រពៃណីទំនៀមទំលាប់ កេរដំណែលពីបុរាណដូចជារឿងរ៉ាវទាក់ទងនឹងប្រវត្តិនៃប្រាសាទបុរាណ ប្រវត្តិនៃតំបន់ទេសចរណ៍នានា ជាពិសេសប្រវត្តិសាស្ត្រខ្មែរក្រហម ដែលបានសម្លាប់មនុស្សជាង២លាននាក់យ៉ាងសាហាវព្រៃផ្សៃ និងត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ក្រោមកិច្ចសហការរបស់សមាគមមគ្គុទ្ទេសក៏ទេសចរណ៍រាជធានីភ្នំពេញ និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំសក្ខាសាលាស្តីអំពី៖របបខ្មែរក្រហមនិងការផ្សះផ្សា ស្ថិតនៅក្នុងវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស្ទឹករីត ដែលមានមគ្គុទ្ទេសក៏ទេសចរណ៍ចំនួន៧០នាក់ មកពីសមាគមន៍មគ្គុទ្ទេសក៏ទេសចរណ៍រាជធានីភ្នំពេញ បានមកចូលរួមស្វែងយល់អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងវិធីសាស្ត្រនៃការផ្សះផ្សា ការអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ។

សិក្ខាសាលាស្តីអំពី ៖ ប្រវត្តិសាស្ត្រខ្មែរក្រហម និងការផ្សះផ្សាជាតិ រៀបចំឡើងក្នុងគោលបំណងជំរុញឲ្យមគ្គុទ្ទេសក៏ទេសចរណ៍ទទួលបាននូវព័ត៌មានពីអ្នកជំនាញផ្ទាល់ដែលមានប្រភពច្បាស់លាស់ និងយល់ដឹងអំពីសិល្បៈនៃការពន្យល់ថែមទាំងមានសមត្ថភាពឆ្លើយសំណួរទៅកាន់ភ្ញៀវរបស់ខ្លួនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមបាន។ លោក ឈឹម ដារិន ប្រធាននៃសមាគមមគ្គុទ្ទេសក៏ទេសចរណ៍រាជធានីភ្នំពេញ បាននិយាយថា៖

ក្នុងនាមលោកគឺជាប្រធាននៃសមាគមមគ្គុទ្ទេសក៏ទេសចរណ៍រាជធានីភ្នំពេញ និងជាមគ្គុទ្ទេសក៍ភាសាអាឡឺម៉ង់ម្នាក់ លោកបានផ្តួចផ្តើមគំនិតបង្កើតសិក្ខាសាលានេះ និងចំណាយអស់រយៈពេលប្រហែលជិត២ឆ្នាំ ដើម្បីរៀបចំឲ្យសិក្ខាសាលានេះកើតឡើងបានដោយទទួលបានការជួយជ្រោមជ្រែង និងលើកទឹកចិត្តពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដោយសារតែការរៀបចំសិក្ខាសាលានៅមានកម្រិត គឺលោកបានរៀបចំសម្រាប់តែសមាជិករបស់សមាគមន៍ តែប៉ុណ្ណោះ ដែលមានអ្នកមកចុះឈ្មោះចូលរួមចំនួន៧០នាក់។ គោលគំនិតចម្បង ដែលនាំឲ្យលោកបង្កើតសិក្ខាសាលានេះឡើង គឺលោកចង់ឲ្យមគ្គុទ្ទេសក៏ទេសចរណ៍ទាំងអស់ពាំនាំពាក្យ និងនិយាយនូវអ្វីដែលជាការពិតទៅដល់ភ្ញៀវ ដូចដែលលោកធ្លាប់បានដឹងថា កន្លងមកមានការនិយាយអ្វីដែលជាការស្តាប់ឮតៗគ្នា និងចេញពីគំនិតបុគ្គលដែលហាក់បីដូចជានៅមានភាពស្រពិចស្រពិលនៅឡើយ។ លោក ឈឹម ដារិន ចង់ឲ្យមគ្គុទ្ទេសក៏ទេសចរណ៍ទាំងអស់ប្រើប្រាស់ព័ត៌មានជាលក្ខណៈផ្លូវការ និងប្រភពតែមួយដូចដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ក្នុងវគ្គសិក្ខាសាលានេះ លោកបានគិតថា វាគឺជាពេលវេលាមួយយ៉ាងខ្លីបំផុតចំពោះការពិភាក្សាគ្នាទៅលើប្រធានបទនៃរបបខ្មែរក្រហម ប៉ុន្តែ លោកសង្ឃឹមយ៉ាងមុតមាំថា មគ្គុទ្ទេសក៏ទេសចរណ៍ទាំងអស់អាចទទួលបានចំណេះដឹងថ្មី និងអាចពង្រឹងសមត្ថភាពរបស់ខ្លួនបានខ្លាំងជាងមុន។

កម្មវិធីនៃសិក្ខាសាលានេះ បានប្រារព្ធធ្វើឡើងនៅព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ ដោយមានកិច្ចស្វាគមន៍ និងការបើកកម្មវិធីជាផ្លូវការ ដែលមានវត្តមានរបស់លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជាវាគ្មិនកិត្តិយស។ លោកបណ្ឌិត លី សុខឃាង បានធ្វើបទបង្ហាញទៅលើប្រធានបទចំនួន២គឺបទបង្ហាញទី១) ស្តីអំពីការកើតឡើងនិងការដួលរលំនៃរបបខ្មែរក្រហម និងប្រធានបទទី២) និយាយអំពីការផ្សះផ្សាជាតិបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ហើយក៏មានការចាក់បញ្ចាំងកុនឯកសារ «គណៈប្រតិភូវៀតណាមអបអរជ័យជម្នះរបស់ខ្មែរក្រហមថ្ងៃទី២៧ កក្កដា ឆ្នាំ១៩៧៥» និង «គុកទួលស្លែង ឆ្នាំ១៩៧៩» ដែរ។

លោកបណ្ឌិតបានលើកឡើងថា ការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើ គឺជាកិច្ចការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដោយមិនបានយកពាក្យចចាមអារ៉ាម ឬការនិយាយតៗគ្នាមកសរសេរចងក្រងនោះទេ គឺផ្អែកសំខាន់ទៅលើឯកសារ។ លោកបណ្ឌិត លី សុខឃាង ក៏បានលើកយកកិច្ចការស្រាវជ្រាវចំនួនបីមកពិភាក្សាគឺ១) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ២) ប្រវត្តិសាស្ត្រអន្លង់វែង ៣)និងដំណើរការនៃការផ្សះផ្សានៅក្នុងប្រទេសកម្ពុជាឆ្នាំ១៩៧៩ដល់ឆ្នាំ២០០៧មុនពេលនៃការបង្កើតតុលាការខ្មែរក្រហម។ លោកបាននិយាយថា ការនិយាយអំពីរបបខ្មែរក្រហម គឺមិនមែននិយាយតែអំពីអតីតកាលនោះទេ ប៉ុន្តែវាគឺជាការនិយាយអំពីបច្ចុប្បន្នកាល។

ក្រៅពីការធ្វើបទបង្ហាញរបស់វាគ្មិន ក៏មានវគ្គសំណួរចម្លើយ និងការពិភាក្សាគ្នាដោយសេរីដែលមានមគ្គុទ្ទេសក៏ទេសចរណ៍ជាច្រើនបានលើកឡើងនូវសំណួរដែលភ្ញៀវធ្លាប់បានសួរ និងចម្លើយរបស់ខ្លួនផ្ទាល់មានដូចខាងក្រោម៖

១) តើកងកម្លាំងខ្មែរក្រហមចាប់ពីឆ្នាំ១៩៧២មកមានចំនួនប៉ុន្មាន?

២) តើហេតុអ្វីបានជាធ្វើឲ្យ ឌុច ដែលជាបញ្ញវន្តម្នាក់គិតថាកសិករអាចក្លាយទៅជាអ្នកស៊ើបការណ៍ឬជាខ្មាំងសត្រូវ?

៣) តើមូលហេតុអ្វីបានជានៅក្នុងរបបខ្មែរក្រហមសម្លាប់បញ្ញវន្ត?

៤) ហេតុអ្វីបានជា ខ្មែរក្រហមមានជម្លោះជាមួយនឹង



វៀតណាម?

៥) តើមូលហេតុអ្វីបានជាវៀតណាមវាយចូលមកក្នុងប្រទេសកម្ពុជា?

៦) តើយើងគួរតែប្រើពាក្យថា ឈ្លានពាន ឬពាក្យថា រំដោះ នៅពេលដែលវៀតណាមបានវាយចូលមកក្នុងប្រទេសកម្ពុជា?

៧) តើហេតុអ្វី បានជាក្នុងអំឡុងពេលនៃរបបខ្មែរក្រហម មិនមានការអន្តរាគមន៍ជួយពីប្រទេសផ្សេងៗ?

៨) តើមានការជីករណ្តៅនៅតាមភូមិពិតមែនដែរឬទេ? ដើម្បីអ្វី?

៩) ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯង?

១០) តើមានជនដៃដល់ចំនួនប៉ុន្មានដែលចូលរួមក្នុងអំពើប្រល័យពូជសាសន៍នៃរបបខ្មែរក្រហម?

១១) តើខ្មែរក្រហមប្រើវិធីសាស្ត្រដូចម្តេច ដើម្បីកំណត់ឲ្យដឹងថាអ្នកណាជាខ្មាំង?

១២) ហេតុអ្វីបានជាមានការបង្កើតតុលាការខ្មែរក្រហម បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម?



មគ្គុទ្ទេសក៍ទេសចរណ៍ផ្នែកភាសាបារាំងឈ្មោះ បូ សុភារី ភេទស្រី មានបទពិសោធន៍ធ្វើកិច្ចការងារជាអ្នកនាំភ្ញៀវទេសចរណ៍ ដែលនិយាយភាសាបារាំងអស់រយៈពេលប្រហែល ១១ឆ្នាំកន្លងមកបានរៀបរាប់ថា ៖

ចំពោះសិក្ខាសាលាស្តីអំពីៈ ប្រវត្តិសាស្ត្រខ្មែរក្រហមនិងការផ្សះផ្សាជាតិ គឺពិតជាមានសារសំខាន់យ៉ាងខ្លាំងចំពោះមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់ភាសាទាំងអស់ ព្រោះមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវនិយាយអ្វីដោយផ្អែកទៅលើព័ត៌មានផ្លូវការ និងច្បាស់លាស់មួយដើម្បីចែករំលែកទៅដល់ភ្ញៀវគ្រប់ជាតិសាសន៍ឲ្យដូចៗគ្នាដោយគ្មានភាពលម្អៀង និងក្លែងបន្លំ។ យើងចង់ប្រើប្រាស់ព័ត៌មានតែមួយ ដែលយោងពីស្ថាប័នស្រាវជ្រាវ ច្បាស់លាស់ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម។ សិក្ខាសាលានេះ គឺជាប្រភពធនធានដ៏សំខាន់ ដែលបានបង្ហាញឲ្យយើងដឹងអំពីអ្វីដែលយើងគួរតែនិយាយទៅកាន់ភ្ញៀវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ចំពោះបទពិសោធន៍ខ្ញុំផ្ទាល់ មុននឹងនិយាយដល់របបខ្មែរក្រហមទៅកាន់ភ្ញៀវ ខ្ញុំតែងតែរៀបរាប់ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ចាប់តាំងពីសម័យអាណានិគមនិយមបារាំងរហូតដល់របបខ្មែរក្រហមបានដួលរលំ គឺខ្ញុំចង់បង្ហាញឲ្យដឹងពីមូលហេតុច្បាស់លាស់។ ភ្ញៀវរបស់ខ្ញុំភាគច្រើនស្គាល់ប្រទេសកម្ពុជា គឺមិនមែនស្គាល់តែប្រាសាទអង្គរវត្ត រាជធានីភ្នំពេញនិងកន្លែងកម្សាន្តនានានោះទេ ប៉ុន្តែភ្ញៀវក៏បានស្គាល់ពីប្រទេសកម្ពុជាដោយសារពាក្យថាខ្មែរក្រហមដែរ។ សំណួរដែលភ្ញៀវតែងតែសួរមកកាន់ខ្ញុំនោះគឺ តើខ្មែរក្រហមគឺជានរណា? មូលហេតុអ្វីបានជាធ្វើឲ្យខ្មែរក្រហមអាចឡើងកាន់អំណាចបាន? តើរបបខ្មែរក្រហមដួលរលំយ៉ាងដូចម្តេច? និងតើយើងបានស្តារប្រទេសកម្ពុជាតាមវិធីសាស្ត្រណាបើយើងធ្លាប់ទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសារតែរបបខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំ? ខ្ញុំ ក៏ធ្លាប់ជួបប្រទះនឹងភាពលំបាកខ្លះក្នុងការនិយាយទៅកាន់ភ្ញៀវអំពីរបបខ្មែរក្រហមដែរ ដូចច្នេះហើយខ្ញុំគិតថាសិក្ខាសាលានេះ បានឆ្លើយតបទៅនឹងសំណួរដែលភ្ញៀវតែងតែសួរមកកាន់ខ្ញុំបានយ៉ាងច្រើន។

អ៊ិន សុដាវី

# អង្គជំនុំជម្រះសាលាដំបូង សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២

*(តពីលេខមុន)*

*១.៣.៦. សហឧក្រិដ្ឋកម្មរួម*

*៤២. អង្គជំនុំជម្រះយល់ឃើញថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥និងបន្ត យ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាមួយចំនួនមានគោលបំណងរួមក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមនៅកម្ពុជាឲ្យបានលឿនតាមរយៈ «មហាលោតផ្លោះ មហាអស្ចារ្យ» ដែលត្រូវបានបង្កើតឡើង ដើម្បីកសាង និងការពារប្រទេសពីខ្មាំង ហើយផ្លាស់ប្តូរប្រជាជនឲ្យក្លាយទៅជាសង្គមកម្មករ-កសិករ ដែលមានជាតិសាសន៍ខ្មែរតែមួយ។ គោលបំណងរួមនេះ ត្រូវបានអនុវត្តគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយបណ្តាញរដ្ឋបាលទាំងមូលរបស់បក្ស គឺលេខាភូមិភាគ តំបន់ ស្រុក និងថ្នាក់មូលដ្ឋាន និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការអនុវត្តយ៉ាងហោចណាស់គោលនយោបាយចំនួនប្រាំ។ គោលនយោបាយដែលត្រូវបានរៀបចំ និងអនុវត្តដើម្បីសម្រេចគោលបំណងរួម គឺ (១) ការផ្លាស់ទីលំនៅប្រជាជនម្តងហើយម្តងទៀតពីទីប្រជុំជន និងទីក្រុង ទៅកាន់តំបន់ជនបទ ព្រមទាំងពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត (២) ការបង្កើត និងដំណើរការសហករណ៍និងការដ្ឋានការងារ(៣) ការបង្កើតនិងដំណើរការមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឲ្យនៅដាច់ដោយឡែក និង «កម្ទេច» អ្នកដែលត្រូវបានគេចាត់ទុកថាជាប្រភេទខ្មាំងធ្ងន់ធ្ងរបំផុត និងដើម្បីអប់រំ «សមាសភាពមិនល្អ» (៤) ការកំណត់គោលដៅទៅលើក្រុមជាក់លាក់ រួមទាំង អ្នករដ្ឋការស៊ីវិល ទាហាន និងក្រុមគ្រួសាររបស់ពួកគេ និង (៥) ការចេញបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះយល់ឃើញថា គោលនយោបាយទាំងនេះមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងគោលបំណងរួម ហើយមានការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថាគោលបំណងរួមនេះមានលក្ខណៈឧក្រិដ្ឋ។*

*៤៣. អង្គជំនុំជម្រះយល់ឃើញទៀតថា គោលបំណងនេះគឺជាគោលបំណងរួមនៅក្នុងចំណោមមនុស្សជាច្រើន រួមទាំងមេដឹកនាំជាន់ខ្ពស់ ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ, សុន សេន និង វន វ៉េត (រហូតដល់ពេលចាប់ខ្លួននៅចុងឆ្នាំ១៩៧៨) ព្រមទាំងលេខាភូមិភាគ រួមទាំង តាម៉ុក,កែ ពក, កុយ ធួន(រហូតដល់ពេលមានការឃុំខ្លួនក្នុងផ្ទះនៅពាក់កណ្តាលឆ្នាំ១៩៧៦) ជូ ជេត (រហូតដល់មានពេលការចាប់ខ្លួននៅក្នុងខែមីនា ឆ្នាំ១៩៧៨) រស់ ញឹម (រហូតដល់មានពេលមានការចាប់ខ្លួននៅក្នុងឧសភា-ខែមិថុនា ឆ្នាំ១៩៧៨) និង សោ ភឹម (រហូតដល់ពេលធ្វើអត្តឃាតនៅខែមិថុនា ឆ្នាំ១៩៧៨)។ មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា បានត្រួតពិនិត្យផ្ទាល់ទៅលើការអនុវត្តគោលនយោបាយជាច្រើន និងបានប្រើប្រាស់ចារីផ្ទាល់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដើម្បីសម្រេចគោលបំណងរួមនេះ។ អង្គជំនុំជម្រះយល់ឃើញថាជាការត្រឹមត្រូវដែលថា សមាជិកសហឧក្រិដ្ឋកម្មរួមនេះ ត្រូវបានកំណត់ឲ្យទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងនេះ។*

***១.៤. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ***

*៤៤. នៅពេលនេះ អង្គជំនុំជម្រះពិនិត្យមើលការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន វិញម្តង។*

***១.៤.១. ការទទួលខុសត្រូវរបស់ នួន ជា***

៤៥. អង្គជំនុំជម្រះយល់ឃើញថា ក្នុងនាមជាបុគ្គលម្នាក់ ដែលមានតួនាទីនាំមុខក្នុងការកសាងមូលដ្ឋានគ្រឹះសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានចូលរួមសន្និបាតបក្ស និងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ចាប់ពីពេលចាប់ផ្តើមការធ្វើបដិវត្តន៍រហូតមកៗ នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាបក្សនៅក្នុងខែកញ្ញា ឆ្នាំ១៩៦០ ហើយបានបន្តកាន់មុខតំណែងនេះនៅគ្រប់ពេល ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យៗ គាត់ក៏ជាសមាជិកពេញសិទ្ធិមួយរូបផងដែរ ទាំងនៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនៗ នួន ជា បានចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗទាំងអស់ ហើយក៏ចូលរួមនៅក្នុងការសម្រេចចិត្តសំខាន់ៗទាំងអស់របស់បក្ស នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យៗ ពេញមួយរបបនេះ នួន ជា នៅតែជាឥស្សរជនដ៏សំខាន់មួយនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ដោយគាត់គឺជាបុគ្គលដៃស្តាំដ៏ស្មោះត្រង់របស់ ប៉ុល ពតៗ លើសពីនេះទៀត នួន ជា ត្រូវបានតែងតាំងឲ្យជំនួស ប៉ុល ពត ធ្វើជានាយករដ្ឋមន្ត្រីស្តីទី នៅពេលដែល ប៉ុល ពត សុំការអនុញ្ញាតសម្រាកជាផ្លូវការចាប់ពីខែកញ្ញា ឆ្នាំ១៩៧៦ រហូតដល់ខែកញ្ញាឆ្នាំ១៩៧៧ៗ ដោយសារតែតួនាទីខ្ពង់ខ្ពស់នៅក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នួន ជា ធ្វើការគ្រប់គ្រងលើសកម្មភាពទាំងអស់របស់បក្សដោយលើសពីតួនាទី និងការទទួលខុសត្រូវដែលត្រូវបានប្រគល់ឲ្យជាផ្លូវការនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទៅទៀតៗ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ នួន ជា និង ប៉ុល ពត មានអំណាចធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្សៗ ក្នុងឋានៈជាអនុលេខាបក្ស ការគ្រប់គ្រងរបស់គាត់មិនមែនមានត្រឹមតែការធ្វើសេចក្តីសម្រេចផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែមានរហូតដល់ខាងផ្នែករដ្ឋាភិបាល និងរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ រួមទាំង កិច្ចការយោធាផងដែរៗ ហេតុដូច្នេះហើយ អង្គជំនុំជម្រះជឿជាក់ថា នួន ជា មិនត្រឹមតែបានគាំទ្ររួមគ្នាលើគោលបំណងរួមប៉ុណ្ណោះទេ ប៉ុន្តែគាត់បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើត និងគ្រប់គ្រងលើដំណើរការនៃគោលបំណងរួមនោះដែរៗ

៤៦. ការគាំទ្ររបស់ នួន ជា លើគោលបំណងរួមដែលគាត់បានចូលរួមបង្កើតឡើង គឺមិនមានការប្រែប្រួលទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះៗ គាត់បានបន្តអនុវត្ត និងផ្សព្វផ្សាយពីគោលបំណងរួមនេះ ដោយភ្ជាប់យ៉ាងតឹងណែនទៅលើការអះអាងដែលត្រូវបានបង្កើតឡើងយ៉ាងប្រុងប្រយ័ត្នដោយបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការឃោសនា និងសកម្មភាពបណ្តុះបណ្តាលនានាៗ នួន ជា ទទួលខុសត្រូវជាចម្បងទៅលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការឃោសនា និងការអប់រំកសិករកម្មាភិបាលនិងសមាជិកបក្សផ្សេងទៀត ដោយផ្តោតជាពិសេសទៅលើគោលការណ៍សំខាន់ៗ និងគោលនយោបាយសេដ្ឋកិច្ចរបស់បក្សៗ នៅក្នុងតួនាទីនេះ នួន ជា បានថ្លែងសុន្ទរកថា និងដឹកនាំវគ្គរៀនសូត្រសម្រាប់កម្មាភិបាលមកពីតំបន់ផ្សេងៗទាំងនៅក្នុងក្រុងភ្នំពេញ និងនៅកន្លែងផ្សេងៗទៀតក្នុងប្រទេស រួមទាំងសហករណ៍ និងការដ្ឋានការងារផងដែរៗ នួន ជា គឺជាអ្នកនិពន្ធដ៏សំខាន់ម្នាក់នៃទស្សនាវដ្តីអប់រំឈ្មោះថា ទង់បដិវត្តន៍ ដែលជាឧបករណ៍ឃោសនាចម្បងរបស់បក្សក្នុងការផ្សព្វផ្សាយយ៉ាងទៀងទាត់នូវសុន្ទរកថាដែល ប៉ុល ពត, នួន ជា និង ខៀវ សំផន បានថ្លែងៗ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលអំឡុងពេលនោះមានការពិភាក្សាទៅលើយុទ្ធវិធីអំពីអ្វីដែលត្រូវលាតត្រដាង និងអ្វីដែលត្រូវរក្សាការសម្ងាត់ ហើយការរក្សាការសម្ងាត់គឺជាសមាសធាតុសំខាន់នៃការឃោសនាដ៏មានប្រសិទ្ធភាពមួយៗ នួន ជាទទួលខុសត្រូវ

ជាចម្បងទៅលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការឃោសនា និងអប់រំកសិករ កម្មាភិបាល និងសមាជិកបក្សផ្សេងទៀត ដោយផ្ដោតជាពិសេសទៅលើគោលការណ៍សំខាន់ៗ និង គោលនយោបាយសេដ្ឋកិច្ចរបស់បក្ស។ ការទទួលខុសត្រូវរបស់ នួន ជា ខាងផ្នែកឃោសនាការ និងបញ្ហាពាក់ព័ន្ធនឹងការអប់រំ រួមទាំងកិច្ចការវិន័យសីលធម៌របស់កម្មាភិបាល និងបញ្ហាសន្តិសុខផ្ទៃក្នុងផ្សេងទៀត ព្រមទាំងសភាពការណ៍ខ្មាំងជាទូទៅផងដែរ ដោយគាត់បានជំរុញឲ្យវ៉ៃកម្ទេច និងកម្ចាត់ខ្មាំង។ ដូចច្នេះអង្គជំនុំជម្រះជឿជាក់ថា តាមរយៈតួនាទីរបស់គាត់នៅក្នុងយុទ្ធនាការឃោសនា និងយុទ្ធវិធីផ្សេងៗ ក៏ដូចជាការបណ្ដុះបណ្ដាលកម្មាភិបាលទាំងមុន និងក្រោយខែមេសា ឆ្នាំ១៩៧៥ នួន ជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត និងផ្សព្វផ្សាយគោលបំណងរួមនេះ។

៤៧. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះយល់ឃើញថា ការចូលរួមចំណែករបស់ នួន ជា នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មមានលើសពីការបង្កើតគោលនយោបាយ ការអនុវត្ត និងការផ្សព្វផ្សាយគោលបំណងរួមតាមរយៈការឃោសនា និងការអប់រំ។ នួន ជា បានអនុវត្តគោលបំណងរួមដោយផ្ទាល់ និងបានចូលរួមយ៉ាងសកម្មក្នុងការបោសសម្អាតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ គាត់មិនត្រឹមតែជួយរៀបចំធ្វើការបោសសម្អាតភូមិភាគពាយព្យ ភូមិភាគកណ្ដាល (ឧត្តរចាស់) និងភូមិភាគបូព៌ាប៉ុណ្ណោះទេ គាត់ថែមទាំងបានចូលរួមដោយផ្ទាល់នៅក្នុងការត្រួតពិនិត្យទៅលើមន្ទីរសន្តិសុខ ស-២១ និងការបោសសម្អាតសមាជិកសំខាន់ៗរបស់បក្ស ដូចជា រស់ ញឹម ដែលជាលេខាភូមិភាគពាយព្យ ជាដើម។

៤៨. ទាក់ទងនឹងមន្ទីរសន្តិសុខស-២១ ឯកសារនាសម័យនោះ ជាពិសេស ចម្លើយសារភាពរបស់អ្នកជាប់ឃុំបង្ហាញថា ចាប់តាំងពីពេលមន្ទីរសន្តិសុខ ស-២១ ដំណើរការដំបូង នួន ជា បានដឹង និងចូលរួមនៅក្នុងការចាប់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់កម្មាភិបាលដែលត្រូវបានកំណត់ជាគោលដៅសម្រាប់ការបោសសម្អាត។ អង្គជំនុំជម្រះយល់ឃើញថាទៀតថា នួន ជា បានបំពេញតួនាទីជាអ្នកគ្រប់គ្រងផ្ទាល់លើ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចាប់ពីថ្ងៃទី ១៥ ខែសីហា ឆ្នាំ១៩៧៧ បន្ទាប់ពី សុន សេន បានចាកចេញទៅសមរភូមិ នៅភូមិភាគបូព៌ា រហូតដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅដើមខែមករា ឆ្នាំ១៩៧៩។ នៅក្នុងមុខនាទីនេះ នួន ជា បានជួបប្រជុំជាទៀងទាត់ជាមួយ ឌុច និងផ្ដល់ការណែនាំនានា រួមទាំងការណែនាំទាក់ទងនឹងអ្នកជាប់ឃុំសំខាន់ៗមួយចំនួន។ នួន ជា បានទទួល និងអានចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ហើយនៅពេលគាត់យល់ឃើញថាចាំបាច់ គាត់បញ្ជាឲ្យកែតម្រូវ។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា នួន ជា ស្ថិតនៅក្នុងចំណោមអ្នកដែលធ្វើសេចក្ដីសម្រេចចិត្តថាត្រូវចាប់ខ្លួននរណាខ្លះដើម្បីបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ នួន ជា បានបញ្ជាឲ្យសម្លាប់មនុស្សមួយក្រុមៗជាច្រើននាក់ដូចជា អ្នកទាំងឡាយដែលបានមកដល់មន្ទីរសន្តិសុខ ស-២១ ដោយសារតែការបោសសម្អាតភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨ និងអ្នកដែលត្រូវបានឃុំខ្លួនដោយផ្ទាល់នៅមន្ទីរសន្តិសុខ ស-២១ មុនពេលបោះបង់មន្ទីរនេះចោល ព្រមទាំងបុគ្គលជាក់លាក់មួយចំនួនទៀត។ ដោយសារតែកងទ័ពវៀតណាមបានសម្រុកចូលក្រុងភ្នំពេញភ្លាមៗ និងការបោះបង់ចោលមន្ទីរសន្តិសុខ ស-២១ ទាំងតក់ក្រហល់ នៅក្នុងខែមករា ឆ្នាំ១៩៧៩ មិនមានការប៉ះពាល់អ្វីទេទៅលើឯកសារផ្ទៃក្នុងរបស់មន្ទីរនេះដែលរៀបរាប់លម្អិតអំពីដំណើរការមន្ទីរសន្តិសុខ ដោយឯកសារទាំងនោះស្ថិតនៅទីកន្លែងដដែល។ ក្រោយមក នួន ជា បានស្ដីបន្ទោស ឌុច ដោយសារតែមិនបានបំផ្លាញឯកសារទាំងនោះចោល។ *(តទៅលេខក្រោយ)*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

# ការអន្តរាគមន៍របស់កងទ័ពវៀតណាម ដើម្បីផ្តួលរំលំរបបខ្មែរក្រហមគឺជាការការពារខ្លួន

«វៀតណាម បានវាយលុកចូលមកក្នុងប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨ ដើម្បីផ្តួលរំលំរបបខ្មែរក្រហមក្នុងគោលបំណងចម្បងមួយគឺការពារសុវត្ថិភាពរបស់ខ្លួន» នេះគឺជាការឆ្លើយតបរបស់លោកស្រីបណ្ឌិត ហ័ង ធីហុងង៉ា គឺជាសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ ដែលជាសាកលវិទ្យាល័យជាតិនៃប្រទេសវៀតណាមស្ថិតនៅក្នុងទីក្រុងហាណូយ ចំពោះសំណួររបស់អ្នកចូលរួមសន្និសីទស្តីអំពីវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន និងសាស្ត្រាចារ្យសាកលវិទ្យាល័យដែលពិភាក្សាអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ នៅក្នុងសន្និសីទនេះ លោកស្រីបណ្ឌិត ហ័ង ធីហុងង៉ា បានលើកយកសំណួរស្រាវជ្រាវចំនួន៣មកបកស្រាយគឺ ទី១) ហេតុអ្វីបានជាកងទ័ពស្ម័គ្រចិត្តវៀតណាមរួបរួមជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាទម្លាក់របបខ្មែរក្រហមចេញពីអំណាច? ទី២) តើប្រតិបត្តិការយោធារបស់កងទ័ពស្ម័គចិត្តវៀតណាមប្រព្រឹត្តទៅយ៉ាងណាដូចម្តេចដើម្បីផ្តួលរំលំរបបខ្មែរក្រហម និងទី៣) តើកងទ័ពស្ម័គ្រចិត្តវៀតណាមបានធ្វើអ្វីខ្លះបន្ទាប់ពីខ្លួនបានផ្តួលរំលំរបបខ្មែរក្រហមនៅលើទឹកដីកម្ពុជា?

លោកស្រីបណ្ឌិតក៏បានបន្ថែមទៀតថា កងទ័ពស្ម័គ្រចិត្តវៀតណាមបង្ខំចិត្តប្រឆាំងនឹងរបបខ្មែរក្រហម ដោយសារតែខ្មែរក្រហមបានចូលមកវាយលុកក្នុងប្រទេសវៀតណាមមុន ដោយបានចល័តកងទ័ពចំនួន១០កងពលដើម្បីវាយប្រហារចូលទៅតាមខេត្តមួយចំនួននៅក្បែរព្រំដែននៃប្រទេសវៀតណាម និងមានការសម្លាប់រង្គាល នៅបាជុកក្នុងខែមេសា ឆ្នាំ១៩៧៨។ ការចូលមកវាយរំដោះប្រទេសកម្ពុជានេះ ក៏មានការស្នើសុំពីភាគីកម្ពុជាដែរ ព្រោះកងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាមិនមានកម្លាំងគ្រប់គ្រាន់ ដើម្បីផ្តួលរំលំរបបខ្មែរក្រហមទេ ហើយវៀតណាមក៏មានបំណងចង់គាំទ្រសន្តិភាពក្រៅប្រទេសជាមួយប្រជាជនកម្ពុជាដែរ។

ប្រធានបទរបស់លោកស្រីបណ្ឌិត ហ័ង ធីហុងង៉ា បានធ្វើឲ្យសាស្ត្រាចារ្យជាច្រើនចាប់អារម្មណ៍ និងសួរសំណួរជាទៅកាន់លោកស្រីវិញ ៖

១) សូមលោកស្រីបង្ហាញអំពីភាពអវិជ្ជមានរបស់កងទ័ព និងរដ្ឋាភិបាលវៀតណាមចំពោះប្រទេសកម្ពុជាអំឡុងពេលនៃការផ្តួលរំលំរបបខ្មែរក្រហម?
២) តើមូលហេតុអ្វីបានជាខ្មែរក្រហមវាយលុកចូលទៅក្នុងខេត្តមួយចំនួននៅក្នុងប្រទេសវៀតណាម?
៣) តើវៀតណាមបានដកកងទ័ពទាំងស្រុងដែរឬទេនៅក្នុងឆ្នាំ១៩៨៩?
៤) តើប្រទេសវៀតណាមទទួលបានផលប្រយោជន៍អ្វីខ្លះចំពោះការជួយប្រទេសកម្ពុជាឲ្យរួចផុតពីរបបខ្មែរក្រហម?
៥) តើលោកស្រីមានអំណះអំណាងយ៉ាងដូចម្តេចនៅពេលដែលលោកស្រីនិយាយថា ខ្មែរក្រហមបានវាយលុកចូលទៅក្នុងប្រទេសវៀតណាមមុន?
៦) ហេតុអ្វីបានជាកងទ័ពវៀតណាមមិនវាយបំផ្លាញខ្មែរក្រហមទាំងស្រុងនៅពេលនោះ?
៧) តើលោកស្រីមានយោបល់ដូចម្តេចដែរចំពោះបញ្ហាកោះត្រល់ និងដែនដីនៃប្រទេសកម្ពុជានោះ?

បន្ថែមទៅលើការឆ្លើយតបសំណួរខាងលើ លោកស្រីបណ្ឌិត ក៏បានលើកយកសុភាសិតមួយមកបកស្រាយថា «មិត្តល្អជួយគ្នាក្នុងគ្រាក្រ»។ លោកស្រីបានបន្តថា នៅក្នុងដំណើរការប្រវត្តិសាស្ត្រ គឺតែងតែមានចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានកើតឡើង ប៉ុន្តែយើងត្រូវមើលត្រឡប់ទៅអតីតកាលវិញដើម្បីអភិវឌ្ឍន៍ប្រទេសទាំងពីរទៅថ្ងៃអនាគត ដោយជៀងសវាងការសង្កត់ធ្ងន់ពីចំណុចអវិជ្ជមានទាំងស្រុង ដើម្បី

ទប់ស្កាត់ការកើតឡើងនៃជម្លោះ។

ប្រទេសវៀតណាមនិងប្រទេសកម្ពុជា គឺជាប្រទេសដែលមានព្រំប្រទល់ជាប់គ្នា។ ប្រទេសទាំងពីរធ្លាប់មានបញ្ហាប្រវត្តិសាស្ត្រ និងទឹកដីបានកើតឡើងតាំងពីយូរយាណាស់មកហើយ ហើយបានរហូតដល់សព្វថ្ងៃ។

វត្តមានរបស់កងទ័ពវៀតណាម នៅចន្លោះពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ត្រូវបានបកស្រាយ និងយល់ឃើញខុសៗគ្នាពីសំណាក់អ្នកស្រាវជ្រាវ និងប្រជាជនកម្ពុជា រួមទាំងប្រជាជនវៀតណាមដែរ។ រឿងរ៉ាវទាំងអស់នេះនៅតែបន្តជាការសង្ស័យ និងត្រូវបានលើកយកពិភាក្សា។

ត្រឡប់មើលទៅលើស្ថានភាពនៅក្នុងអំឡុងសង្គ្រាមវៀតណាម កងទ័ពវៀតណាមខាងជើងបានចូលមករស់នៅលើទឹកដីនៃប្រទេសកម្ពុជា ព្រមទាំងបានប្រើប្រាស់កំពង់ផែព្រះសីហនុដែលបណ្តាលឲ្យសហរដ្ឋអាមេរិក ធ្វើការទម្លាក់គ្រាប់បែកមកលើដែនដីនៃប្រទេសកម្ពុជាក្នុងគោលបំណងបំផ្លាញជម្រកកងទ័ពវៀតណាមខាងជើង ដែលបានសម្ងំលាក់ខ្លួននៅក្នុងប្រទេសកម្ពុជា (បើយោងទៅតាម World Peace Foundation, Cambodia: U.S. bombing, civil war & Khmer Rouge, August 7, 2015)។ ចំណងមិត្តភាពរវាងប្រទសកម្ពុជា និងប្រទេសវៀតណាម នៅតែមានជាបន្តបន្ទាប់ ជាពិសេសនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ដែលមានគណៈប្រតិភូវៀតណាមមួយក្រុមបានចូលមកទស្សកិច្ច និងអបអរជ័យជម្នះរបស់យោធាខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧៥ (ខ្សែភាពយន្តឯកសាររបស់វៀតណាមៈដំណើរទស្សនកិច្ចនៅក្នុងរបបខ្មែរក្រហមនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៥)។ ប៉ុន្តែទំនាក់ទំនងប្រទេសទាំងពីរ បានផ្លាស់ប្តូរទៅតាមរបត់នយោបាយរបស់ប្រទេសទាំងពីរ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយចូលមកក្នុងប្រទេសកម្ពុជាដើម្បីផ្តួលរំលំរបបខ្មែរក្រហម និងបន្តរស់នៅលើទឹកដីនៃប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៨៩។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ប្រទេសកម្ពុជាបានខិតខំអភិវឌ្ឍន៍ប្រទេសជាតិដែលត្រូវបានខ្មែរក្រហមបំផ្លិចបំផ្លាញស្ទើតែគ្មានសល់ឡើងវិញ ដោយបាតដៃទទេស្អាត។ ការបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់ក្មេងៗជំនាន់ក្រោយ និងការបណ្តុះបណ្តាលសាស្ត្រាចារ្យ និងគ្រូៗ អំពីប្រវត្តិសាស្ត្រនេះ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា តាមរយៈការចូលរួមកសាងសន្តិភាព ការផ្សះផ្សា និងការថែរក្សាប្រវត្តិសាស្ត្រដើម្បីការពារកុំឲ្យមានការកើតឡើងវិញនៃអំពើប្រល័យពូជសាសន៍។ វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន និងសាស្ត្រាចារ្យកម្រិតសាកលវិទ្យាល័យ ដើម្បីពិភាក្សាអំពី «អំពើប្រល័យពូជសាសន៍នៅកម្ពុជា» ត្រូវបានរៀបចំឡើងជាលើកទី៣ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំយុវជន និងកីឡា។ សន្និសីទនេះ មានការអញ្ជើញចូលរួមពីលោកជំទាវ ទន់ សាអុឹម អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា សាស្ត្រាចារ្យជំនាញផ្នែកប្រវត្តិសាស្ត្រមកពីសាកលវិទ្យាល័យនានាទូទាំងប្រទេសកម្ពុជា និងវាគ្មិនជាតិ និងអន្តរជាតិ ដូចជា លោក ឡាយ សួនចៀន ការធារីនៃស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា, សាស្ត្រាចារ្យ ម៉ីលតុន អូស្បន អ្នកនិពន្ធសៀវភៅ, សាស្ត្រាចារ្យ ភីអូត្រ អូស្តាហ្សឹស្គី អតីតសាកលវិទ្យាធិការរងនៃសាលាសេដ្ឋកិច្ចវ័រសរ, លោកស្រីបណ្ឌិត ហ័ង ធីហុងង៉ា, លោក នីកូឡា គាំចាន់ សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, លោកស្រី ខេលី វ័តសុន នាយកកម្មវិធីអប់រំរបស់វិទ្យាស្ថានសិទ្ធិមនុស្ស, លោកគ្រីស្តូហ្វ័រ ឌៀរីង អ្នកប្រឹក្សាយោបល់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក សាយមិន ព្យែរ ប្រធានផ្នែកកិច្ចការនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានរបស់សហភាពអឺរ៉ុបប្រចាំនៅកម្ពុជា, លោកស្រី អ៊ុង វណ្ណា អ្នកនិពន្ធសៀវភៅ «ព្រលឹងមាសម្តាយ», លោក ម៉ន ម៉ៅ និង លោក យាន រ៉ាំ មកពីខេត្តឧត្តរមានជ័យ គឺជាដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

*អ៊ិន សុដាវី*

# កេរដំណែលរបស់ជនភៀសខ្លួនឥណ្ឌូចិន នៅប្រទេសហ្វីលីពីន

កេរដំណែលជាច្រើនរបស់ជនភៀសខ្លួនឥណ្ឌូចិន ត្រូវបានបន្សល់ និងតម្កល់ទុកនៅក្នុងសារមន្ទីរសាបាង ស្ថិតនៅក្នុងបរិវេណជំរំភៀសខ្លួនម៉ូរ៉ុង ទីក្រុងបាតាអាន ប្រទេសហ្វីលីពីន។ សារមន្ទីរនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាកេរដំណែលដែលធ្លាប់បានប្រើប្រាស់ក្នុងទសវត្សរ៍ទី៨០ ដោយជនភៀសខ្លួនឥណ្ឌូចិន រួមមាន ឡាវ វៀតណាម និងកម្ពុជា។ កេរដំណែលទាំងនោះ មានដូចជា ៖ ភួយ ចានឆ្នាំងសម ស្លាបព្រា កែវ កៅអី ម៉ាស៊ីនអង្គុលីលេខ និងសៀវភៅរាប់រយពាន់ក្បាល។ សារមន្ទីរសាបាង បានខិតខំប្រឹងប្រែងប្រមែប្រមូលកេរដំណែលទាំងនេះ យកមកថែរក្សាក្នុងគោលបំណងដាក់តាំងបង្ហាញដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ


ទូកដែលជនភៀសខ្លួននៅឥណ្ឌូចិនជិះចូលមកប្រទេសហ្វីលីពីន

ចូលទស្សនា ព្រោះវាជាផ្នែកមួយនៃការចងចាំអំពីប្រវត្តិសាស្ត្រដែលធ្លាប់បានកើតឡើង ចន្លោះទសវត្សរ៍ទី៧០ និងពេញមួយទសវត្សរ៍ទី៨០។ ជនភៀសខ្លួនទាំងនេះ បានរត់ភៀសខ្លួននៅអំឡុងឆ្នាំ១៩៧៩ ដោយគេចវេះពីសង្គ្រាមដែលបានកើតឡើងនៅក្នុងប្រទេសរបស់ខ្លួន ហើយវិបត្តិជនភៀសខ្លួននៅកម្ពុជាក៏បានកើតមានឡើងជាមួយនឹងលំហូរនៃជនភៀសខ្លួនក៏បានបន្តកើនឡើង។ ក្រោយមក ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានរៀបចំបង្កើតជំរំភៀសខ្លួនជាច្រើន ដើម្បីផ្តល់ជាទីជម្រកដល់ជនភៀសខ្លួនឥណ្ឌូចិនរាប់សែននាក់ឲ្យស្នាក់នៅបណ្តោះអាសន្នស្របពេលដែលជនភៀសខ្លួនទាំងនោះ កំពុងរត់គេចពីសង្គ្រាមនៅក្នុងឆ្នាំ១៩៧៩ និងពេញមួយទសវត្សរ៍ទី៨០។ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ក៏បានរៀបចំបង្កើតជំរំភៀសខ្លួនមួយមានឈ្មោះថា «មជ្ឈមណ្ឌលរៀបចំជនភៀសខ្លួនហ្វីលីពីន» ក្នុងចំណោមជំរំភៀសរបស់ខ្លួនជាច្រើនផ្សេងទៀត។

ដោយសារតែភាពចលាចលនយោបាយបានផ្ទុះឡើងនៅប្រទេសវៀតណាម ឡាវ និងកម្ពុជា ចាប់ពីឆ្នាំ១៩៧៥ ជនភៀសខ្លួនឥណ្ឌូចិនរាប់ពាន់នាក់ បានរត់ភៀសខ្លួនដោយទូក និងដោយថ្មើរជើងដើម្បីស្វែងរកសិទ្ធិជ្រកកោននៅក្នុងបណ្តាប្រទេសក្បែរនោះ។ ជាការឆ្លើយតប រដ្ឋាភិបាលហ្វីលីពីនក៏បានផ្តល់កន្លែងដល់មជ្ឈមណ្ឌលរៀបចំជនភៀសខ្លួន ដែលមានការគាំទ្រពីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) នៅឆ្នាំ១៩៧៩។ មជ្ឈមណ្ឌលរៀបចំជនភៀសខ្លួនហ្វីលីពីននេះ មានទីតាំងស្ថិតនៅម៉ូរ៉ុង (Morong) ទីក្រុងបាតាអាន (Bataan) ប្រទេសហ្វីលីពីន។ មជ្ឈមណ្ឌលរៀបចំជនភៀសខ្លួនត្រូវបានបង្កើតឡើងនៅថ្ងៃ

ទី២១ ខែមករា ឆ្នាំ១៩៨០។ ក្រោយមក មជ្ឈមណ្ឌលនេះបានទទួលជនភៀសខ្លួនឥណ្ឌូចិនជាលើកដំបូង ដើម្បីបន្តដំណើរឆ្ពោះទៅតាំងទីលំនៅថ្មីនៅប្រទេសទីបី។ នៅក្នុងអំឡុងពេលស្នាក់អាស្រ័យអស់រយៈពេលប្រាំមួយខែ ទៅប្រាំបីខែ ជនភៀសខ្លួនត្រូវបានផ្ដល់ការឧបត្ថម្ភជាមូលដ្ឋាន ដូចជា ទឹកស្បៀង សេវាថែទាំសុខភាព សេវាសង្គម និងទទួលបានការបណ្ដុះបណ្ដាលភាសាបរទេស និងអំពីវប្បធម៌របស់ប្រទេសហ្វីលីពីន។ ខណៈពេលដែលចំណាយមូលធននិងប្រតិបត្តិការប្រចាំឆ្នាំ ត្រូវបានផ្ដល់ដោយឧត្ដមស្នងការអង្គការសប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNCHR) ដែលពេលនោះប្រទេសហ្វីលីពីនផ្ដល់ដីដែលមានទំហំសរុប៣៦៥ហិកតានិងមានចម្ងាយ១៨២គីឡូម៉ែត្រពីទីក្រុងម៉ានីល។ ប្រទេសហ្វីលីពីនបានផ្ដល់ឧបករណ៍ប្រើប្រាស់ផ្សេងៗដល់បុគ្គលិក និងសន្តិសុខរបស់មជ្ឈមណ្ឌលនេះ។ មជ្ឈមណ្ឌលរៀបចំជនភៀសខ្លួនបានផ្ទុកជនភៀសខ្លួនឥណ្ឌូចិនរហូតដល់១៨.០០០នាក់ និងមានផ្ទះសរុបចំនួន២៨៥ខ្នង ចែកចេញជាដប់សង្កាត់។ នៅក្នុងមជ្ឈមណ្ឌលនេះមានមន្ទីរពេទ្យ បណ្ណាល័យស្រាវជ្រាវ មជ្ឈមណ្ឌលវិជ្ជាជីវៈ សាលារៀននិងសំណង់ប្រាសាទបុរាណខ្មែរ។

ក្រោយមក ឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានបង្កើត និងអនុម័តច្បាប់ស្ដីពីជនភៀសឥណ្ឌូចិនអាចទៅរស់នៅប្រទេសទីបី រួមមាន ៖ សហរដ្ឋអាមេរិក ប្រទេសអូស្ត្រាលី ប្រទេសកាណាដា និងបណ្ដាប្រទេសនៅអឺរ៉ុប។ មានប្រជាជនកម្ពុជាមួយចំនួនបានបន្តដំណើរឆ្ពោះទៅរស់នៅប្រទេសទីបី រហូតមកដល់បច្ចុប្បន្ននេះ។

ហួ ថុន



បណ្ណាល័យដែលជនភៀសខ្លួនខ្មែរធ្លាប់មកចូលអានសៀវភៅ

# ការចងចាំនៅតែមាន តម្រូវការនៃយុត្តិធម៌នៅតែបន្ត ចំពោះរបបខ្មែរក្រហម

*កន្លងផុតទៅអស់រយៈពេល៤០ឆ្នាំ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ប្រទេសកម្ពុជាបានខិតខំអភិវឌ្ឍន៍ខ្លួនយ៉ាងសន្សឹមៗតាមរយៈការផ្សាភ្ជាប់ពីរឿងរ៉ាវប្រវត្តិសាស្ត្រ និងពេលវេលាបច្ចុប្បន្នសម្រាប់ដំណើរការកសាងប្រទេសនាពេលអនាគតកាល។ ទោះបីជាសព្វថ្ងៃ ប្រទេសកម្ពុជា ទទួលបានសន្តិភាពពេញលេញមួយពីរបបខ្មែរក្រហមយ៉ាងណាក៏ដោយ ក៏ប្រទេសនេះនៅតែមានភារកិច្ចដោះស្រាយវិបត្តិអតីតកាលរបស់ខ្លួនដែលនៅសេសសល់។ អំឡុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាបានស៊ូទ្រាំចំពោះការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងររួមមាន ការធ្វើទារុណកម្ម ការបង្ខំឲ្យធ្វើការងារលើសកម្លាំង ការអត់ឃ្លាន និងជំងឺ ដែលជាមូលហេតុបណ្តាលឲ្យប្រជាជនស្លូតត្រង់ប្រមាណ ២លាននាក់បានស្លាប់បាត់បង់ជីវិតយ៉ាងអយុត្តិធម៌ ខណៈពេលដែលប្រជាជនប្រមាណ៥លាននាក់ទៀត បានបន្តរស់រានមានជីវិតយ៉ាងសោកសង្រេង។ រហូតដល់បច្ចុប្បន្ននេះ ប្រជាជនដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើន នៅតែបន្តទទួលរងសម្ពាធយ៉ាងធ្ងន់ធ្ងរពីបទពិសោធន៍អតីតកាលដែលបានបន្តឡើងនៅក្នុងខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។*

*ឥទ្ធិពលនៃរបបខ្មែរក្រហម ក៏បានធ្វើឲ្យប្រជាជនកម្ពុជាជាច្រើនមានសេចក្តីក្លាហានតស៊ូ និងចូលរួមជាមួយតុលាការខ្មែរក្រហម ដើម្បីស្វែងរកយុត្តិធម៌។ អំឡុងឆ្នាំ២០០៧ មានប្រជាជនកម្ពុជាប្រមាណ១.៧៥០នាក់ (យោងតាមតួរលេខរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) បានដាក់ពាក្យបណ្តឹងទៅកាន់តុលាការខ្មែរក្រហម ដើម្បីស្វែងរកយុត្តិធម៌សម្រាប់ខ្លួនឯង សាច់ញាតិដែលបានបាត់បង់ជីវិត និងសង្គមទាំងមូលដែលទទួលរងខ្ទេចខ្ទាំ ខណៈពេលដែលជនរងគ្រោះជាច្រើននាក់ទៀតស្ទាក់ស្ទើរមិនដឹងថាតើគួរតែដោះស្រាយវិបត្តិរបស់ខ្លួនដោយរបៀបណា។ អំឡុងពេលជាង១០ឆ្នាំនៃដំណើរការរបស់តុលាការខ្មែរក្រហម ប្រជាជនកម្ពុជាបានអត់ធ្មត់យ៉ាងស្ងៀមស្ងាត់ និងរង់ចាំស្តាប់ចំពោះការសម្រេចចិត្តពីតុលាការខ្មែរក្រហមក្នុងការកាត់ទោសមេដឹកនាំនៃរបបខ្មែរក្រហម។ ទន្ទឹមអំឡុងពេលនៃការរង់ចាំ ជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ក៏បានបាត់បង់ជីវិតមុនពេលទទួលបានយុត្តិធម៌ដោយសារតែភាពចាស់ជរានិងជំងឺ។*

*របបខ្មែរក្រហម បានបន្សល់ទុកនូវការចងចាំដ៏សោះកក្រោះមួយ ដែលមិនអាចលុបបំបាត់ចេញពីវិញ្ញាណ ឬអារម្មណ៍បាន ដែលការចងចាំទាំងអស់នេះដូនកាល គឺជាកម្លាំងចិត្ត និងសាក្សីដ៏សំខាន់បំផុតដើម្បីស្រាយបំភ្លឺអំពីទង្វើដ៏ឃោរឃៅដែលមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តចំពោះប្រជាជនកម្ពុជានៅក្រោមការដឹកនាំរបស់ខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដែលកំពុងតែរស់នៅក្នុងខេត្តព្រៃវែង បានរៀបរាប់អំពីយុត្តិធម៌ដែលខ្លួនទទួលបានពីតុលាការខ្មែរក្រហម ដូចខាងក្រោម ៖*

*សែម សុភី ភេទស្រី សព្វថ្ងៃមានអាយុ៥៧ឆ្នាំ រស់នៅឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង បានរៀបរាប់ថា ៖*

*គ្រប់វិនាទីនៅក្នុងរបបខ្មែរក្រហម គឺជាពេលវេលាដ៏រន្ធត់ដែលដក់ជាប់នៅក្នុងបេះដូងរបស់ខ្ញុំជានិច្ច និងមិនអាចលុបចេញបានឡើយ។ ព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងនាពេលនោះ ហាក់បីដូចជាទើបតែកើតឡើងពីម្សិលមិញសម្រាប់ខ្ញុំ។ ការចងចាំអំពី*

របបខ្មែរក្រហម បានធ្វើបាបផ្លូវចិត្តរបស់ខ្ញុំ ដែលកាន់តែធ្វើឲ្យខ្ញុំទទួលរងភាពសោកសង្រេងបន្ថែមទៀត។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំគឺជាក្មេងស្រីជំទង់ម្នាក់ដែលមានអាយុត្រឹមតែ១៤ ប៉ុណ្ណោះ និងមានតួនាទីជាគ្រូបង្រៀនដល់ក្មេងៗ។ បន្ទាប់ពីឪពុករបស់ខ្ញុំ ត្រូវបានខ្មែរក្រហមចាប់យកទៅ ខ្ញុំត្រូវបានអង្គការឲ្យឈប់បង្រៀន និងប្តូរឲ្យទៅធ្វើការនៅក្នុងកងចល័តវិញ។ ការងារក្នុងកងចល័តពិតជាលំបាកខ្លាំងណាស់ ហើយខ្ញុំត្រូវបានបង្ខំឲ្យធ្វើការងារហួសកម្លាំងជាប្រចាំ ដូចជាលើកទំនប់ ជីកប្រឡាយ ដោយគ្មានអាហារហូបគ្រប់គ្រាន់ឡើយ។ ក្រោយមកទៀតបងប្រុសរបស់ខ្ញុំ ត្រូវបានខ្មែរក្រហមចាប់យកទៅនៅចុងឆ្នាំ១៩៧៦ និងមិនដែលឃើញគាត់ត្រឡប់មកវិញឡើយ។

នៅពេលដែលកងទ័ពវៀតណាមបានផ្តួលរំលំរបបខ្មែរក្រហម ខ្ញុំក៏មិនដែលធ្លាប់គិតថាចង់សងសឹកដែរ ព្រោះខ្ញុំដឹងថា វាគឺជារឿងមិនល្អ និងមិនអាចទៅរួចឡើយចំពោះការសងសឹក។ ប៉ុន្តែខ្ញុំបាននិយាយរឿងរ៉ាវដែលបានកើតឡើង និងហេតុការណ៍ទាំងឡាយដែលខ្ញុំបានដឹងនៅក្នុងរបបខ្មែរក្រហម ប្រាប់ដល់ក្មេងៗជំនាន់ក្រោយព្រោះខ្ញុំគិតថា នេះគឺជាវិធីសាស្ត្រមួយដ៏ល្អក្នុងការសងសឹកមេដឹកនាំខ្មែរក្រហម។

ចំពោះខ្ញុំ ពាក្យថាយុត្តិធម៌មានអត្ថន័យជ្រាលជ្រៅណាស់ គឺដើម្បីទទួលបានយុត្តិធម៌ មិនមែនត្រឹមតែជាការសន្យាថានឹងស្វែងរកយុត្តិធម៌ឲ្យនោះទេ ប៉ុន្តែត្រូវផលិតឲ្យចេញជាលទ្ធផលជាក់ស្តែងដូចទៅនឹងតុលាការខ្មែរក្រហម ដែលបានកាត់ក្តីមេដឹកនាំខ្មែរក្រហមពិតប្រាកដមែន។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ខ្ញុំបានដាក់ពាក្យបណ្តឹងដើម្បីស្វែងរកយុត្តិធម៌ជូនដល់ឪពុក និងបងប្រុសខ្ញុំដែលត្រូវបានខ្មែរក្រហមចាប់យកទៅ ប៉ុន្តែខ្ញុំគ្មានក្តីរំពឹងទុកទាល់តែសោះថានឹងទទួលបានលទ្ធផលមកវិញឡើយ។ បន្ទាប់ពីដាក់ពាក្យបណ្តឹងទៅកាន់តុលាការខ្មែរក្រហម ខ្ញុំតែងតែទន្ទឹងរង់ចាំមើល ដោយបានតាមដានអំពីសវនាការនៃសាលាក្តីខ្មែរក្រហមតាមរយៈការស្តាប់វិទ្យុ និងទូរទស្សន៍។ លទ្ធផលចុងក្រោយនៃការ



ឈួន រី ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតកំពុងអង្គុយមើលចៅនៅក្រោមផ្ទះ

កាត់ក្តីរបស់តុលាការខ្មែរក្រហម បានផ្តល់យុត្តិធម៌ដល់ខ្ញុំពិតប្រាកដមែន ទោះបីជាខ្ញុំមិនទាន់បានទទួលយុត្តិធម៌យ៉ាងពេញលេញមួយក៏ដោយ។

បន្ថែមពីលើយុត្តិធម៌ដែលទទួលបានពីការកាត់ក្តីមេដឹកនាំខ្មែរក្រហមពីតុលាការខ្មែរក្រហម ខ្ញុំក៏សូមសំណូមពរឲ្យមានសំណងបន្ថែមជាសមូហភាព ដូចជាការអភិវឌ្ឍន៍សហគមន៍ដែលខ្ញុំកំពុងតែរស់នៅបន្ថែមទៀតដើម្បីឲ្យទទួលបានការរស់នៅមួយ ដែលមានលក្ខណៈប្រសើរ ដែលជាផ្នែកមួយអាចជួយដោះស្រាយដល់បញ្ហាផ្លូវចិត្តដែលបានទទួលរងខ្ទេចខ្ទីដោយសារតែ

បទពិសោធន៍អតីតកាលដ៏គ្រោតគ្រាតទាំងអស់នោះ។

១) មិត្ត ផល្លា ភេទស្រី អាយុ៥៣ ឆ្នាំ រស់នៅឃុំដាច ស្រុកកំចាយមារ ខេត្តព្រៃវែងបាននិយាយថា «ខ្ញុំមិនធ្លាប់បានរំពឹងទុកថា ខ្ញុំអាចទទួលបានយុត្តិធម៌ពីទង្វើដែលមេដឹកនាំខ្មែរក្រហមបានបង្កឡើងចំពោះខ្ញុំដូចសព្វថ្ងៃនោះទេ»។ ខ្ញុំគឺជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម កាលពីរយៈពេល១០ឆ្នាំមុន ព្រោះខ្ញុំមានការឈឺចាប់ជាខ្លាំងចំពោះការបាត់បង់ឪពុក និងទារុណកម្មដែលខ្មែរក្រហមបាន



ខិន អ៊ាន គឺជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នៅក្នុងខេត្តព្រៃវែង

ធ្វើមកលើក្រុមគ្រួសាររបស់គាត់ និងប្រជាជនផ្សេងៗទៀត។

«ខ្ញុំពិតជាចង់ទៅមើលការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការខ្មែរក្រហមណាស់ ប៉ុន្តែគួរឲ្យសោកស្តាយដែលខ្ញុំមិនធ្លាប់បានទៅចូលរួម»។ ជំនួសឲ្យការចូលរួមក្នុងតុលាការខ្មែរក្រហមផ្ទាល់ ខ្ញុំបានតាមដានដំណើរការនៃការកាត់ក្តីមេដឹកនាំខ្មែរក្រហម តាមរយៈទូរទស្សន៍តែប៉ុណ្ណោះ ហើយខ្ញុំពិតជារីករាយណាស់ដែលតុលាការខ្មែរក្រហមបានជួយរកយុត្តិធម៌ឲ្យឪពុកនិងក្រុមគ្រួសាររបស់ខ្ញុំ។ សម្រាប់ខ្ញុំ ការកាត់ក្តីមេដឹកនាំខ្មែរក្រហមដាក់គុកមួយជីវិត គឺជាយុត្តិធម៌មួយដែលខ្ញុំទទួលបានត្រឹមតែមួយផ្នែកប៉ុណ្ណោះ។ ខ្ញុំចង់បានសំណងជាសមូហភាពបន្ថែមទៀត ដូចជា ផ្លូវថ្នល់ សាលារៀន និងមន្ទីរពេទ្យ ដែលខ្មែរក្រហមធ្លាប់បានបំផ្លិចបំផ្លាញចោល។ សម្រាប់ខ្ញុំ ពាក្យថាយុត្តិធម៌ គឺសំដៅដល់អ្វីៗដែលតុលាការខ្មែរក្រហមបានផ្តល់ឲ្យដោយកាត់ទោសទៅលើមេដឹកនាំខ្មែរក្រហមទាំងអស់នោះ។ ខ្ញុំធ្លាប់មានកំហឹងនៅក្នុងចិត្តយ៉ាងខ្លាំង ជួនពេលខ្លះខ្ញុំក៏ចង់សងសឹកចំពោះអ្នកដែលបានសម្លាប់ឪពុករបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចធ្វើបានឡើយ។ វត្តមានរបស់តុលាការខ្មែរក្រហម គឺជាអ្វីដែលខ្ញុំមិនធ្លាប់បានរំពឹងទុកទាល់តែសោះ ព្រោះបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ខ្ញុំ និងប្រជាជនដ៏ទៃទៀតខិតខំស្វះស្វែងធ្វើយ៉ាងណាបន្តជីវិតទៅមុខទៀត។

អំឡុងពេលនៃរបបខ្មែរក្រហម ខ្ញុំមានអាយុត្រឹមតែ១២ឆ្នាំ និងធ្វើការងារនៅក្នុងកងកុមារផលិតជី ហើយជួនពេលខ្លះ អង្គការបានបញ្ជូនខ្ញុំឲ្យទៅជីកប្រឡាយដែរ។ នៅក្នុងឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំបានបែកខ្ញែកគ្នាដោយសារតែខ្មែរក្រហមបានបំបែកឲ្យទៅរស់នៅកន្លែងផ្សេងៗពីគ្នា។ ជាអកុសល ឪពុករបស់ ខ្ញុំត្រូវបានខ្មែរក្រហមអាករសម្លាប់នៅខណៈពេលដែលគាត់ដើរស្វែងរកអាហារឲ្យសមាជិកក្រុមគ្រួសារ។ ខ្ញុំនិងក្រុមគ្រួសារបានវិលត្រឡប់មករស់នៅផ្ទះកំណើតរបស់ខ្លួនវិញ ប៉ុន្តែផ្ទះសម្បែងរបស់ខ្ញុំត្រូវបានបំផ្លាញចោលខ្ទេចខ្ទីដែលស្ថិតក្នុងសភាពមួយមិនអាចរស់នៅបានឡើយ។ នាពេលនោះ សមាជិកគ្រួសារម្នាក់ៗមានតួនាទីផ្សេងៗគ្នា គឺអ្នកខ្លះដើរស្វែងរកចំណីអាហារ និងអ្នកខ្លះស្វែងរក

ជម្រកៗ ប្រជាជនដទៃទៀតក៏មិនខុសប្លែកពីក្រុមគ្រួសាររបស់ខ្ញុំដែរ។

២) ឈួន រី ភេទស្រី អាយុ៦៨ឆ្នាំ រស់នៅក្នុងស្រុកស្វាយអន្ទរ ខេត្តព្រៃវែងបានរៀបរាប់ថា៖

ខ្ញុំទទួលបានយុត្តិធម៌ ហើយបន្ទាប់ពីតុលាការខ្មែរក្រហមកាត់ទោសមេដឹកនាំខ្មែរក្រហមដាក់ក្នុងគុកអស់មួយជីវិត។ ខ្ញុំបានធូរស្បើយនៅក្នុងចិត្តច្រើនជាងមុនបើប្រៀបធៀបជាមួយនឹងរយៈពេល១០ឆ្នាំមុនដែលខ្ញុំតែងតែយំនៅពេលដែលខ្ញុំនិយាយរៀបរាប់ពីរឿងរ៉ាវជីវិតខ្ញុំនិងក្រុមគ្រួសារនៅក្នុងរបបខ្មែរក្រហមប្រាប់ទៅនរណាម្នាក់។ ខ្ញុំពិតជាចង់ទៅស្តាប់ការកាត់ទោសផ្ទាល់នៅតុលាការខ្មែរក្រហមណាស់ ប៉ុន្តែខ្ញុំមិនធ្លាប់បានទទួលឱកាសនេះទេ។ ទោះបីជាយ៉ាងណា ខ្ញុំបានតាមដានការកាត់ក្តីរបស់តុលាការខ្មែរក្រហមតាមរយៈទូរទស្សន៍ ហើយក៏បានធ្វើឲ្យខ្ញុំដឹងថាតើនរណាល្អ និងនរណាអាក្រក់។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានបង្ខំឲ្យធ្វើការងារលើសកម្លាំង និងមិនទទួលបានអាហារបរិភោគគ្រប់គ្រាន់នោះទេ។ នារាត្រីមួយ ខ្ញុំពិតជាភ័យតក់ស្លុតយ៉ាងខ្លាំងនៅពេលដែលខ្ញុំឮសូរសម្លេងមនុស្សស្រែកថា «អូយៗ» ពេលដែលត្រូវវាយសម្លាប់។ ជីវិតខ្ញុំស្ទើរតែបាត់បង់ ហើយខ្ញុំមិនធ្លាប់មានសង្ឃឹមថាមានជីវិតរស់នៅដល់សព្វថ្ងៃនេះទេបន្ទាប់ពីត្រូវបានខ្មែរក្រហមបញ្ជាឲ្យជីករណ្តៅកប់ខ្លួនឯងនោះ។ ប៉ុន្តែសំណាងល្អកងទ័ពវៀតណាមបានវាយចូលមករំដោះទាន់ពេលវេលា។ សាច់ញាតិរបស់ខ្ញុំចំនួន៥នាក់បានបាត់បង់ជីវិត ដែលក្នុងនោះប្អូនប្រុសរបស់ខ្ញុំម្នាក់ដែលត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើជាកងទ័ពមិនដែលឃើញត្រឡប់មកផ្ទះវិញនោះទេ។ រឿងរ៉ាវនៅពេលនោះគឺពិតជាល្វីងជូរចត់រកអ្វីប្រៀបផ្ទឹមមិនបានឡើយ។

៣) ឌិន អ៊ាន ភេទស្រី អាយុ៧៥ឆ្នាំ រស់នៅស្រុកស្វាយអន្ទរ ខេត្តព្រៃវែងនិយាយថា៖

ខ្ញុំ គឺជាស្ត្រីមេម៉ាយដែលចិញ្ចឹមបីបាច់កូនតែម្នាក់ឯងអស់រយៈពេល៤៥ឆ្នាំកន្លងមកហើយបន្ទាប់ពីប្តីរបស់ខ្ញុំបានស្លាប់នៅពេលដែលខ្ញុំកំពុងតែពពោះកូនដែលមានត្រឹមអាយុ៧ខែក្នុងរបបខ្មែរក្រហម។ បន្ទាប់មក សាច់-ញាតិរបស់ខ្ញុំ បានស្លាប់ជាបន្តបន្ទាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ ខ្ញុំរស់នៅនិងតស៊ូអត់ធ្មត់ដើម្បីកូន ហើយគ្មានយប់ណាមួយដែលខ្ញុំមិនយំនឹកអ្នករាល់គ្នាឡើយ។ ខ្ញុំបានខិតខំធ្វើការងារយ៉ាងខ្លាំងដើម្បីរក្សាជីវិតរស់ ទោះបីជាខ្ញុំទើបតែសម្រាលកូនមិនបានយូរប៉ុន្មានក៏ដោយ។ ភ្នែករបស់ខ្ញុំ ចាប់ផ្តើមស្រវាំង ព្រោះដោយសារតែខ្ញុំយំខ្លាំងពេលដែលខ្ញុំទើបតែបង្កើតកូនបានក្នុងរយៈពេលខ្លី។ ក្រោយមក នៅពេលដែលប្រទេសជាតិទទួលបានសន្តិភាពឡើងវិញ រឿងដែលខ្ញុំគិតដល់មុនគេនោះគឺការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ខ្ញុំនិងកូន។ ខ្ញុំស្ទើរតែមិនជឿថានឹងមានតុលាការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសឡើយ។ ខ្ញុំបានសម្រេចចិត្តប្តឹងទៅតុលាការ ដើម្បីឲ្យជួយបកស្រាយបំភ្លឺឲ្យបានច្បាស់ពីអ្វីដែលបានកើតឡើងនាពេលនោះ។ ខ្ញុំបានធ្វើដំណើរទៅតុលាការខ្មែរក្រហមដើម្បីចូលរួមស្តាប់សវនាការកាត់ទោស ហើយខ្ញុំក៏បានទៅទស្សនាគុកទួលស្លែង និងវាលពិឃាតជើងឯក ដែលពេលនោះហើយធ្វើឲ្យខ្ញុំកាន់តែជឿជាក់ថា ខ្មែរក្រហមបានសម្លាប់ប្រជាជនរបស់ខ្លួនអស់យ៉ាងច្រើន។ បន្ទាប់មកខ្ញុំកាន់តែចាប់អារម្មណ៍ចំពោះនីតិវិធីដំណើរការកាត់ក្តីរបស់តុលាការខ្មែរក្រហម ដែលជារឿយៗខ្ញុំបានមើលការកាត់ក្តីមេដឹកនាំខ្មែរក្រហមតាមទូរទស្សន៍។ កំហឹងរបស់ខ្ញុំចំពោះមេដឹកនាំខ្មែរក្រហមទាំងអស់នោះនៅតែមាន។ ទង្វើដ៏ព្រៃផ្សៃរបស់ខ្មែរក្រហម បានធ្វើឲ្យខ្ញុំនៅតែនឹកឃើញពីការបង់មនុស្សជាទីស្រឡាញ់របស់ខ្ញុំដែលគ្មានថ្ងៃវិលត្រឡប់មកវិញ។

ទោះបីជាយ៉ាងណា ខ្ញុំពិតជាទទួលបានយុត្តិធម៌គ្រប់គ្រាន់ពីលទ្ធផលនៃការកាត់ក្តីរបស់តុលាការខ្មែរ

ក្រហមដែលខ្ញុំមិនធ្លាប់បានរំពឹងទុកពីមុនទាល់តែសោះ ព្រោះការកាត់ក្ដីនេះ អាចបញ្ជាក់ច្បាស់ឲ្យខ្ញុំដឹងថា នរណាជាអ្នកបង្កឡើងនូវបញ្ហាទាំងអស់នេះ យ៉ាងពិតប្រាកដ។ សព្វថ្ងៃ ខ្ញុំមិនចង់បានអ្វីបន្ថែមទៀតទេ គឺខ្ញុំសុំត្រឹមតែសេចក្ដីសុខ និងសន្តិភាព។ ខ្ញុំតែងតែនិយាយប្រាប់នូវរឿងរ៉ាវរបស់ខ្ញុំទៅដល់ក្មេងៗជំនាន់ក្រោយ ដើម្បីកុំឲ្យក្មេងៗចូលធ្វើនយោបាយខុសក្នុងពេលអនាគត។

៤) ហៃ សុខឃៀង ភេទប្រុស អាយុ៥៩ឆ្នាំ រស់នៅឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែងបានចែករំលែកបទពិសោធន៍របស់គាត់ថា៖

ខ្ញុំគាំទ្រ ជាមួយនឹងការកាត់ក្ដីរបស់តុលាការខ្មែរក្រហមទៅលើមេដឹកនាំខ្មែរក្រហម ព្រោះខ្ញុំចង់ចូលរួមស្វែងរកយុត្តិធម៌ និងថែរក្សាទុកប្រវត្តិសាស្ត្រដ៏ជូរចត់នេះដល់ក្មេងៗជំនាន់ក្រោយ ដើម្បីឲ្យចេះថ្លឹងថ្លែងអំពីការគ្រប់គ្រងប្រទេស ពីសម័យកាលមួយទៅសម័យកាលមួយបន្តទៀត។ ខ្ញុំគិតថាប្រសិនបើខ្ញុំមានឱកាសក្នុងការបកស្រាយ ខ្ញុំនឹងមិនភ័យខ្លាចឬស្ទាក់ស្ទើរក្នុងការរៀបរាប់ការពិតអំពីរឿងរ៉ាវដែលខ្ញុំបានដឹងដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមឡើយ។ ខ្ញុំធ្លាប់បានតាមដានការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមការចាក់ផ្សាយនៅក្នុងទូរទស្សន៍ ព្រោះខ្ញុំគិតថា ការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសនេះ គឺពិតជាមានអត្ថប្រយោជន៍ដល់ទាំងប្រជាជន និងសង្គមកម្ពុជាទាំងមូល។

ចំពោះខ្ញុំ ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនខ្មែរតាមរយៈការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺបានចូលរួមចំណែកក្នុងការការពារអំពើប្រល័យពូជសាសន៍បែបនេះកើតឡើងម្ដងទៀត ដូចជា ការចាញ់បោកមេដឹកនាំខ្មែរក្រហម និងការវិលត្រឡប់មកកាន់អំណាចឡើងវិញដោយក្រុមកុម្មុយនីស្ត ដូចជា ប៉ុល ពត ជាដើម។

*អ៊ុន សុដាវី*



សកម្មភាពដើមបណ្ដឹងកំពុងផ្ដល់បទសម្ភាសន៍ដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា

# កំណត់ត្រាប្រវត្តិសាស្ត្រ៖ ទំនាក់ទំនងរវាងប្រទេសសិង្ហបុរី និងកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

សិង្ហបុរី ដែលជាទូទៅប្រជាជនកម្ពុជា ហៅថា «សាំងហ្គាពួរ» គឺជាប្រទេសមួយដែលបានចាប់ផ្តើមភ្ជាប់ទំនាក់ទំនងការទូត និងទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងរបបកម្ពុជាប្រជាធិតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ តបតាមការអញ្ជើញរបស់រដ្ឋាភិបាលនៃប្រទេសសិង្ហបុរី, អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ រួមដំណើរដោយកម្មាភិបាលជាន់ខ្ពស់ចំនួន៦រូបទៀត បានធ្វើដំណើរទស្សនកិច្ចផ្លូវការនៅប្រទេសសិង្ហបុរី ចំនួន ៤ថ្ងៃចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧។

ក្នុងរយៈពេលស្នាក់នៅប្រទេសសិង្ហបុរី អៀង សារី ត្រូវបានទទួលស្វាគមន៍ដោយរដ្ឋមន្ត្រីការបរទេសសិង្ហបុរី ស៊ីនណាតហាមបី រ៉ាចារ៉ាតណាម (Sinathamby Rajaratnam) និងរដ្ឋមន្ត្រីវប្បធម៌វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ចេក យឺន ថុង (Jek Yeun Thong)។ អៀង សារី ក៏បានចូលជួបសម្តែងការគួរសមជាមួយប្រធានាធិបតី បេនចាមីន សៀរើស (Benjamin Sheares) និងនាយករដ្ឋមន្ត្រី លី ក្វាន់ យូ (Lee Kuan Yew)។



រូបទី៣រាប់ពីស្តាំ ៖ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ជួបជាមួយរដ្ឋម

នៅក្នុងជំនួបនោះ រដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរបានផ្លាស់ប្តូរទស្សនៈស្តីអំពីទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិជាអន្តរជាតិ។ រដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរក៏បានសម្តែងនូវភាពរីករាយបន្ទាប់ពីបានតភ្ជាប់ទំនាក់ទំនងការទូត, ទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យសិង្ហបុរី និងបន្តពង្រីកទំនាក់ទំនងនេះថែមទៀតនៅពេលខាងមុខ។

នៅចន្លោះពីថ្ងៃទី១១ ដល់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៨ គណៈប្រតិភូសេដ្ឋកិច្ចនៃប្រទេសសិង្ហបុរីបានមកធ្វើទស្សនកិច្ចផ្លូវការនៅប្រទេសកម្ពុជា។ គណៈប្រតិភូនេះដឹកនាំដោយ លោក លី ជីអុង ហ្យាម (Lee Chiong Giam) ប្រធាននាយកដ្ឋានសេដ្ឋកិច្ចនៃក្រសួងការបរទេសសិង្ហបុរី។ ទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូនៃប្រទេសសិង្ហបុរី រួមមាន វ៉ាន់ រិត ប្រធានគណៈកម្មាធិការពាណិជ្ជកម្ម, ឡូញ ប្រធានគណៈកម្មាធិការនេសាទរដ្ឋ និង នី កន ប្រធានពិធីការ នៃក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ។

នៅថ្ងៃទី១២-១៤ ខែឧសភា ឆ្នាំ១៩៧៨ កម្មាភិបាលនៅក្រសួងការបរទេសកម្ពុជាបានជូនគណៈប្រតិភូ នៃប្រទេសសិង្ហបុរីទៅទស្សនាអង្គរវត្ត ក្នុងខេត្តសៀមរាប។ ក្នុងពេលធ្វើដំណើរតាមផ្លូវ គណៈប្រតិភូនៃប្រទេសសិង្ហបុរីក៏បានចូលទស្សនាទំនប់១មករា (ការដ្ឋានទំនប់១មករា គឺជាទីតាំងបទឧក្រិដ្ឋមួយក្នុងចំណោមទីតាំងបទឧក្រិដ្ឋជាច្រើនទៀតនៅក្នុងសំណុំរឿង០០២/២ នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា) និងទីរួមខេត្តកំពង់ធំ (ទីតាំងមន្ទីរតំបន់៤៣)។ នៅខេត្តសៀមរាបគណៈប្រតិភូនៃប្រទេសសិង្ហបុរីទស្សនាបារាយទឹកថ្លា ទីតាំងរណ្តៅគ្រាប់បែក, លេណដ្ឋានការពារនៅជុំវិញខេត្តសៀមរាប។ នៅទីបញ្ចប់គណៈប្រតិភូនៃប្រទេសសិង្ហបុរីបានទស្សនាប្រាសាទបាយ័ន្តនិងប្រាសាទអង្គរវត្ត។

នៅថ្ងៃបន្ទាប់ គឺថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨ អៀង សារី, វ៉ាន់ រិត និង ឡូញ បានទទួលជួបជាមួយគណៈប្រតិភូនៃប្រទេសសិង្ហបុរីនៅភ្នំពេញ។ នៅខណៈពេលនោះ អៀង សារី បានផ្តាំផ្ញើសួរសុខទុក្ខរដ្ឋមន្ត្រីការបរទេសសិង្ហបុរី។ កម្ពុជាប្រជាធិបតេយ្យ និងសិង្ហបុរីក៏បានបង្ហាញនូវអារម្មណ៍សប្បាយរីករាយចំពោះកិច្ចពិភាក្សាដែលបានបង្កើតឡើងនៅដំណាក់កាលទី១ គឺទំនាក់ទំនាក់សេដ្ឋកិច្ច ពាណិជ្ជកម្មរវាងកម្ពុជាប្រជាធិបតេយ្យ និងសិង្ហបុរី ដោយបង្កើតឲ្យមានការដោះដូរពាណិជ្ជកម្ម ទំនាក់ទំនងដឹកជញ្ជូនជើងទឹក និងទូរគមនាគមន៍។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៨ វ៉ាន់ រិត និង ឡូញ បានចូលរួមជូនដំណើរគណៈប្រតិភូសេដ្ឋកិច្ចនៃប្រទេសសិង្ហបុរីត្រឡប់ទៅប្រទេសវិញ។

យោងតាមឯកសារបញ្ជីពាណិជ្ជកម្មរបស់កម្ពុជា



ន្ត្រីក្រសួងសន្តិសុខប្រទេសគុយបា អេកូ ហ្គីហ្គូ វ៉ុលដេស ឆ្នាំ១៩៧៦

ប្រជាធិបតេយ្យ ដែលបានបន្សល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ គឺមានកប៉ាល់ដឹកទំនិញយ៉ាងហោចណាស់ចំនួន២គ្រឿង បានដឹកប្រេងម៉ាស៊ីន, គ្រឿងបន្លាស់រថយន្ត និងទំនិញផ្សេងៗទៀតពីប្រទេសសិង្ហបុរីចូលមកផែកំពង់សោមៗ ចំនួនទំនិញសរុបប្រមាណជាបីពាន់ប្រាំពីរយហាសិបតោន និងមានតម្លៃជាងមួយលានប្រាំមួយសែនដុល្លារសហរដ្ឋអាមេរិក។

វ៉ាន់ រិត អតីតប្រធានគណៈកម្មាធិការពាណិជ្ជកម្ម ដែលបានផ្តល់បទសម្ភាសន៍ដល់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ២០០៣ បានឲ្យដឹងថាកម្ពុជាប្រជាធិបតេយ្យបានទិញប្រេងម៉ាស៊ីនពីប្រទេសសិង្ហបុរីរាប់ម៉ឺនធុងមកគរនៅក្នុងឃ្លាំងនៅភ្នំពេញ។ វ៉ាន់ រិត បានឲ្យដឹងទៀតថា ខ្មែរក្រហមមានប្រាក់កម្ចីពីចិនចំនួន១៨០លានយន់និង២០លានដុល្លាសហរដ្ឋអាមេរិក ហើយលុយទាំងនោះ ត្រូវបានទុកនៅក្នុងធនាគាររបស់ចិន។ ខ្មែរក្រហមបានទូទាត់លុយសងឲ្យភាគីសិង្ហបុរីតាមរយៈធនាគារ ចិន។

ហែម លីសៀង អតីតនីរសារផ្ទាល់របស់ ឡូញ ប្រធានគណៈកម្មាធិការនេសាទរដ្ឋប្រចាំនៅកំពង់សោម បានឲ្យដឹងថា ខ្មែរក្រហមបានលក់ផលនេសាទសមុទ្ររួមមានត្រីធំៗ, បង្គា, ក្តាម និងមឹក រាប់រយតោនទៅឲ្យភាគីសិង្ហបុរី។ លីសៀង បានបន្តថា នៅខណៈពេលដែលខ្មែរក្រហមបានត្រឡប់មកពីនេសាទម្តងៗ គឺខ្មែរក្រហមបានណាត់ឲ្យភាគីសិង្ហបុរី បើកកប៉ាល់ចូលមកទទួលយកផលនេសាទនៅផែកំពង់សោម។ លីសៀង បានបញ្ជាក់ថា ខ្មែរក្រហមក៏បានផ្ញើត្រីសមុទ្រធំៗ, បង្គា, ក្តាម និងមឹកស្រស់ៗ ជូនមេដឹកនាំខ្មែរក្រហមនៅមន្ទីរ ៨៧០ ជាទៀងរាល់សប្តាហ៍។

បន្ទាប់ពីខ្មែរក្រហមបានដួលរលំ នៅឆ្នាំ១៩៧៩ ប្រទេសសិង្ហបុរីនៅតែបន្តមានទំនាក់ទំនងការទូត និងជួយឧបត្ថម្ភគាំទ្រក្រុមខ្មែរក្រហមដែលបានភៀសខ្លួនទៅព្រំដែនកម្ពុជា-ថៃ ដើម្បីរៀបចំអង្គការចាត់របស់ខ្លួនក្នុងការតស៊ូប្រឆាំងនឹងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម រហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

នៅឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជា និងអង្គសហប្រជាជាតិបានចាប់ផ្តើមដំណើរការអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម (មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ) ចំពោះការបាត់បង់អាយុជីវិតប្រជាជនប្រមាណ ២លាននាក់ដោយសារការអត់អាហារ, ការធ្វើការងារហួសកម្លាំង, ឈឺគ្មានថ្នាំព្យាបាល និងការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ប្រទេសជាច្រើនបានចូលរួមផ្តល់ជាថវិកា និងសម្ភារផ្សេងៗ ដើម្បីជួយដល់ដំណើរការកាត់ក្តី។ ប្រទេសសិង្ហបុរី គឺជាប្រទេសដែលមានសេដ្ឋកិច្ចធំទី៤ ក្នុងចំណោមប្រទេសអាស៊ាន និងមានប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ (GDP Per Capital) ចំនួនជាង៦ម៉ឺនដុល្លាសហរដ្ឋអាមេរិក គឺខ្ពស់បំផុតនៅក្នុងចំណោមប្រទេសអាស៊ាន និងស្ថិតនៅចំណោមប្រទេសទាំង១០នៃពិភពលោកដែលប្រជាជនមានចំណូលខ្ពស់ជាងគេ ប៉ុន្តែប្រទេសសិង្ហបុរីមិនបានចូលរួមវិភាគទានដល់ដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម នៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាទេ បើទោះបីប្រទេសសិង្ហបុរីធ្លាប់មានទំនាក់ទំនងការទូត និងទំនាក់ទំនងពាណិជ្ជកម្មជាមួយរបបកម្ពុជាប្រជាធិតេយ្យ (របបខ្មែរក្រហម) ១៩៧៥ - ១៩៧៩ យ៉ាងណាក៏ដោយ។

*ឡុង ដានី*

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*(តពីលេខមុន)*

ចាន់ សុទ្ធី ហៅ ចាន់ បូរ មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅមុខកំពូល ខេត្តកណ្តាល ជាកូនរបស់ពូ ចាន់ យឹម និងមីង សារ៉ាយ ផាត ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីររការកោង ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៧ បន្ទប់តូច ៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ចាន់ សុទ្ធី ហៅ ចាន់ បូរ ត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃ១៤ ខែមករា ឬខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦។

ចាន់ សួន មានអាយុ៤០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃនប់ ខេត្តកំពត (បច្ចុប្បន្ន ខេត្តព្រះសីហនុ) ជាកូនរបស់អ៊ំចាន់ឡឹកនិងអ៊ំស្រីជុំគឹមមានប្រពន្ធឈ្មោះជាមុំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រៃបន់ ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ១១។ ចាន់សួន ត្រូវបានខ្មែរក្រហមចាប់បញ្ជូនខ្លួនមកដល់គុកទួលស្លែងនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២៦ ខែឆ្នាំដដែល បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល ២០ ថ្ងៃ។

ចាន់ សឿង ហៅ សាត មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូយាននិងមីងស៊ឹមជាយុទ្ធនារីពេទ្យព៩៨ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៦ បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល ៧១ ថ្ងៃ។

ចាន់ ស្រ៊ាង ហៅ ជិត មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៧ អតីតគ្រូបង្រៀន មានស្រុកកំណើតនៅក្រូចឆ្មារ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ចាន់ ស្រ៊ឹម និងអ៊ំស្រី យ៉ាង ឡេង មានប្រពន្ធឈ្មោះ ម៉ឹង យូឡេង ហៅ ភិន មានកូនប្រុស៣នាក់ និងកូនស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់ចាម ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ រ បន្ទប់ធំ ០៥ បន្ទប់តូច ៦។ ខ្មែរក្រហមចាប់បញ្ជូនខ្លួន ចាន់ ស្រ៊ាង មកដល់គុកទួលស្លែងនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ និងសម្លាប់ចោលនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល ២៩៥ ថ្ងៃ។

ចាន់ ស្រ៊ីន ហៅ ថៃ មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់ពូហេង និងមីង អ៊ុន យុទ្ធនារីពេទ្យកងពល៣១០ មានប្ដីឈ្មោះ អ៊ុត អុន ហៅ អ៊ុត ណន មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ០៣ បន្ទប់តូច ៩។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាន់ ហឿន ហៅ ភី មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូវ័ត្ន អ៊ឹម និងមីង ហាង មានប្រពន្ធឈ្មោះ ស៊ិន ហៅ ហ៊ិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅប្រាំងចំរេះ ថ្ងៃទី២១ខែកញ្ញា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ យ បន្ទប់ធំ ៣ បន្ទប់តូច ៤។ ខ្មែរក្រហមចាប់ខ្លួន ចាន់ ហឿន បញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៧៨ ថ្ងៃ។

ចាន់ អួន ហៅ សុវ៉ែន អនុកងវរយនៃកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចាប ចាន់ ហៅ ង៉ែត មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទោងខេត្តកំពង់ធំដាកូនរបស់ពូ ម៉ៅញ ចាប និងមីង ផាត់ អែម យុទ្ធជនកងពល៣១០ មានប្រពន្ធឈ្មោះ វ៉ា រន មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាប ដិន ហៅ ចន មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះអណ្ដែត ខេត្តតាកែវ ដាកូនរបស់ពូ ចាប ជន និងមីង មិន ឡាប់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ចាប ដិន នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។

ចាប ធិន ហៅ សាម មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅជីក្រែង ខេត្តសៀមរាប ដាកូនរបស់ពូ ចាប រឹប និងមីង ដែក ថន លេខាវរៈសេនាតូច កងពល៣១០ មានប្រពន្ធឈ្មោះ អែម មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ចាប ធិន នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល ៨៣ ថ្ងៃ។

ចាប ប៊ុនធឿន មានអាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីតគ្រូបច្ចេកទេសអគ្គិសនីកម្ពុជា មានស្រុកកំណើតនៅភ្នំពេញ ដាកូនរបស់អ៊ំ ចាប ហួត និងអ៊ំស្រី សុក អឿ ត្រូវមានខ្មែរក្រហមចាប់ខ្លួននៅពោធិ៍ចិនតុង ថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៧ បន្ទប់ធំ ២៤។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចាប សុខឡេង ហៅ ជូ មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកណ្ដាលស្ទឹង ខេត្តកណ្ដាល ដាកូនរបស់ពូ ស្រុន និងមីង មួយ កម្មករតម្បាញ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រតម្បាញ ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាលូ ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។

ចិក សាមុត ហៅ ពេជ សាមុត មានអាយុ៣៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំចាយមារ ខេត្តព្រៃវែង ដាកូនរបស់អ៊ំ ពេជ ចិក និងអ៊ំស្រី ភេម ណាំ មានប្រពន្ធឈ្មោះ យ៉ាណៃហួរ ហៅ រី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបឹងត្របែក ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ៥ បន្ទប់តូច ៣។ ខ្មែរក្រហមសម្លាប់ ចិក សាមុត នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល ១៨ ថ្ងៃ។

ចិន ញឹម អាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅត្រាំកក់ ខេត្តតាកែវ ដាកូនរបស់ពូ ចិន ញឹម និងមីង ទុំ ង៉ែត មានប្រពន្ធឈ្មោះ ចិន ញ៉ាំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រៃនប់ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១១។ ខ្មែរក្រហមបញ្ជូន ចិន ញឹម មកដល់គុកទួលស្លែងនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែឆ្នាំដដែល។

ចិន លាង ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចិន ស៊ា ហៅ ហាន មានអាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅរំដួល ខេត្តស្វាយរៀង ដាកូនរបស់អ៊ំ

ចិន ហាវ និងអ៊ុំស្រី សោម ខៃ មានប្រពន្ធឈ្មោះ ញ៉ែម ដាត ហៅ មល្ល័ត្ត ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៥ បន្ទប់តូច ៤។ ខ្មែរក្រហមសម្លាប់ ចិន ស៊ា នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦។

ចិន ស៊ុយ មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៦ (ស្រុកខ្សាច់កណ្ដាល) ខេត្តកណ្ដាល ជាកូនរបស់ពូ អ៊ុំ សុក និងមីង ចិន សុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចិន សាត អនុលេខាមន្ទីរ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅប្រាំងចំរេះពាណិជ្ជកម្មក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូនចិន សាត មកដល់គុកទួលស្លែងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចិន ឡឹង មានអាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅដង្កោ ខេត្តកណ្ដាល ជាកូនរបស់ពូ ចិន សុក និងមីង ប៉ៅ ហ៊ួន កម្មករអគ្គីសនី ឯកទេសបណ្ដាញ មានប្រពន្ធឈ្មោះ ទី ផុន មានកូនស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅសហជីបផ្សារតូច ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៥ បន្ទប់តូច ៣។ ខ្មែរក្រហមសម្លាប់ ចិន ឡឹង នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៣០ ថ្ងៃ។

ចិន លូន ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។

ចឹក យ៉ន ហៅ អែម មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់ពូ មិន នំ និងមីង ចឹក ប៊ិន ប្រធាននារី មន្ទីរ ក៩ មានប្ដីឈ្មោះ ហៀប សារ៉ន ហៅ សេន មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ ក៩ តាឡី ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ចឹក យ៉ន នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៦ ថ្ងៃ។ ប្ដីឈ្មោះ ហៀប សារ៉ន ហៅ សេន ត្រូវបានខ្មែរក្រហមចាប់ខ្លួនបញ្ជូនមកគុកទួលស្លែងនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ មុនប្រពន្ធ ២ ថ្ងៃ ហើយសម្លាប់ចោលនៅថ្ងៃដែលប្រពន្ធត្រូវបានចាប់ខ្លួននិងបញ្ជូនមកដល់គុកគឺថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។

ចឹង យ៉ាងឡា ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។

ចឹង យឹងក្វេ ជនជាតិ យួន (វៀតណាម) ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ចឹង យឹងក្វេ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦។

ចឹង វ៉ាំងយី ជនជាតិ យួន (វៀតណាម) ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចុង យូម៉េង ហៅ ហ៊ាង មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ ចុង មួន ម៉ឺល និងមីង ណៃ គីម យុទ្ធជនដឹក(ជញ្ជូន) ជើងទឹក មានប្រពន្ធឈ្មោះ ហេង លី ហៅ ណើមានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយសម្លាប់នៅថ្ងទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៤ ថ្ងៃ។

ចេង ស៊ីយ៉ុមប៊ិន អតីតទាហានសក្តិ៥ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រះវិហារក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូន ចេង ស៊ីយ៉ុមប៊ិន មកដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦

បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧៩ ថ្ងៃ។

ចេង ស៊ុនលី ហៅ ភ័ស មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅដើមព្រៃ ខេត្តកំពង់ចាម ជាកូនរបស់ពូ ខោល ចេង និងមីង ឈុន ចេង យុទ្ធនារីពេទ្យកងពល៣១០ មានប្តីឈ្មោះ ជ័យ សំអុល ហៅ សូ មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ២។ ខ្មែរក្រហមសម្លាប់ ចេង ស៊ុនលី នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៨ ថ្ងៃ។ ប្តីឈ្មោះ ជ័យ សំអុល ហៅ សូ ត្រូវបានខ្មែរក្រហមចាប់ខ្លួនមុនប្រពន្ធគឺនៅថ្ងៃទី១២ ហើយសម្លាប់ចោលក្រោយប្រពន្ធគឺនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧។

ចេង ហ៊ួរ ហៅ សុខ មានអាយុ៤០ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតវិស្វករក្បេត្រសាស្ត្រផ្នែកគគ្គា-រុក្ខា ស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ចេង ទៀង ហៅ ពាង និងអ៊ំស្រី ចាង ហ៊ាង មានប្រពន្ធឈ្មោះ ឈរ ស៊ីណាព្យ មានកូនប្រុស១នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០២ បន្ទប់ធំ ៩។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ចេង ហ៊ួរ ត្រូវបានឯកសារខ្លះសរសេរឈ្មោះថា ចេង ហួន, ចេង ហួម ឬ ចេង គួរ។ ចេង ហ៊ួរ ត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកពីព្រះនេត្រព្រះ ដល់គុកទួលស្លែងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ ១៩៧៦។

ចេង ហុកជី ទាហានសក្តិ២ មកពីប្រទេសបារាំង ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់ខ្លួន ចេង ហុកជី នៅតាឡី បញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល ១៧ ថ្ងៃ។

ចេវ ខុន ហៅ ដែក មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់ពូ ច្រឹក និងមីង យឹន មានប្រពន្ធឈ្មោះ យឹម កាន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២៩ ថ្ងៃ។

ចេវ ធុន ហៅ ម៉ុន យុទ្ធជនវរៈសេនាធំ កងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ចេវ ធុន មកដល់គុកទួលស្លែងនៅថ្ងៃទី៩ ឬ ២២ ខែកញ្ញា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចែ ចើន ហៅ ធី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ៥០២ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ចែ ចើន មកដល់គុកទួលស្លែងនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០ ថ្ងៃ។

ចែក គឹមឈឿន មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅពារាំង ខេត្តព្រៃវែង ជាកូនរបស់ពូ ម៉ាង និងមីងអ៊ំ សេងត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣០ខែឧសភា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១០ បន្ទប់ធំ ២។ ខ្មែរក្រហមបញ្ជូន គឹមឈឿន ដល់គុកទួលស្លែងនៅថ្ងៃទី១៥ ខែមិថុនាឆ្នាំ១៩៧៦ និសម្លាប់ចោលនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៨៥ ថ្ងៃ។

ចែត ឆេង មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីត

និស្សិតចម្រៀងនៃវង់ មានស្រុកកំណើតនៅខ្សាច់កណ្តាល ខេត្តកណ្តាល ជាកូនរបស់ពូ ផែត ឆោម និងមីង អ៊ិ យាន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គីសនីផ្សារតូច ថ្ងៃទី១២ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ២។ ខ្មែរក្រហមចាប់បញ្ជូន ចែត ឆេង មកដល់គុកទួលស្លែងនៅថ្ងៃទី៤ ឬ ២០ ខែកុម្ភៈ ឆ្នាំ ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចែម វណ្ណ ហៅ ភិន មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ ចែម និងមីង ទូច យុទ្ធជនដឹកជញ្ជូន ពេទ្យ ៣៩៨ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេទ្យ៣៩៨ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៦០ ថ្ងៃ។

ចៅ ម៉ាត់ ហៅ ដរា មានអាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតគ្រូខ្មែរលក់ថ្នាំ មានស្រុកកំណើតនៅស្វាយទង ខេត្តមាត់ជ្រូក ជាកូនរបស់អ៊ំ ចៅ ដាន់ និងអ៊ំស្រី នាង យាល់ មានប្រពន្ធឈ្មោះ នាង រី មានកូនប្រុស២នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅគីរីវង្ស ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូនចៅម៉ាត់ទៅដល់គុកទួលស្លែងនៅថ្ងៃបន្ទាប់ និងសម្លាប់ចោលនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល ១៨៩ ថ្ងៃ។

ចៅ រ៉ូ មានអាយុ៤៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្វាយទង ខេត្តមាត់ជ្រូក ជាកូនរបស់អ៊ំ ណុន និងអ៊ំស្រី ណន មានប្រពន្ធឈ្មោះ នាង ហាន មានកូនប្រុស៣នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅក្បាលដំរី តំបន់២៥ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ៣ បន្ទប់តូច ៤។ ខ្មែរក្រហមសម្លាប់ ចៅ រ៉ូ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

ចៅ សឿង មានអាយុ៣៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្វាយទង ខេត្តមាត់ជ្រូក កម្ពុជាក្រោម ជាកូនរបស់អ៊ំ ចៅ សាំ និងអ៊ំស្រី នាង សំ មានប្រពន្ធឈ្មោះ ភាន មានកូនប្រុស១នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃនៅពោធិ៍ចិនតុងភ្នំពេញ ទី២០ ខែមិថុនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៥ បន្ទប់ធំ ១។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ចៅ សឿង មានឈ្មោះហៅផ្សេងទៀតថា សេង សេន ត្រូវបានខ្មែរក្រហមបញ្ជូនខ្លួនមកដល់គុកទួលស្លែងនៅថ្ងៃទី២៩ ខែសីហា ឬថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧។

ចៅស៊ុំ សត្ថា មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតសនិស្សិតថ្នាក់បរិញ្ញាឆ្នាំទី១ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់ពូ ចៅ ស៊ុំ និងមីង គង់ កោលិនី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ អ២៥ ថ្ងៃទី៧ខែកក្កដា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៩ ខែឆ្នាំដដែល។

ច្រឹករស់ហៅរ៉ាវណ្ណ មានអាយុ៣៨ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្តាល ជាកូនរបស់អ៊ំ ញឹប ច្រឹក និងអ៊ំស្រី សំ មានប្រពន្ធឈ្មោះ ឆេង ទង មានកូនប្រុស២នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំបន់២៥ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥។ ខ្មែរក្រហមបញ្ជូនខ្លួន ច្រឹក រស់ មកដល់គុកទួលស្លែងនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៥ ឬថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦។

(តទៅលេខក្រោយ)

ភាន់ ថាន់ពៅដារ៉ា និង ឡុង ដានី



កៅអីសម្រាប់ជនភៀសខ្លួនឥណ្ឌូចិនអង្គុយរៀននៅជំរំបណ្តុះបណ្តាលជនភៀសខ្លួនក្នុងប្រទេសហ្វីលីពីន


**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 235, August 2019 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.